ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២០-២០២៤



## មាតិកា


**បុព្វកថា** ............ iii

**អារម្ភកថា** ............ v

**អក្សរកាត់** ............ vii

**សេចក្តីសង្ខេប** ............ viii

**១- សាវតារ** ............ ១

១.១- ច្បាប់និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ............ ២

១.២- ផែនការសកម្មភាពអន្តរស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ............ ៣

១.៣- ការពាក់ព័ន្ធក្នុងតំបន់អំពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ............ ៤

១.៤- ផលផលសមុទ្រ ............ ៥

១.៥- បញ្ហានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៧

១.៦- ការរៀបចំគ្រប់គ្រងផលផល ............ ១០

១.៧- ក្របខ័ណ្ឌនិងវិសាលភាពនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ............ ១២

**២- គោលបំណងនិងយុទ្ធសាស្ត្រ** ............ ១២

២.១- គោលបំណង ............ ១២

២.២- យុទ្ធសាស្ត្រ ............ ១៣

**៣-ផែនការសកម្មភាពនិងកាលវិភាគអនុវត្តសកម្មភាពក្នុងវិស័យច្បាប់និងវិស័យពាក់ព័ន្ធ** . ១៤

៣.១- វិសាលភាព ............ ១៤

៣.២- ផែនការសកម្មភាព ............ ១៥

១- ការទទួលខុសត្រូវរបស់រដ្ឋ ............ ១៥

២- ការទទួលខុសត្រូវរបស់កម្ពុជា ក្នុងនាមជារដ្ឋម្ចាស់ផ្ទែរ ............ ១៥

៣- ការទទួលខុសត្រូវរបស់កម្ពុជា ក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិ ............ ២៥

៤- វិធានការរដ្ឋម្ចាស់កំពង់ផែ ............ ២៧

៥- វិធានការទាក់ទងនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ ............ ២៩

៦- កិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ និងប្រទេសផ្សេងទៀត ដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ............ ៣០

៧- លក្ខខណ្ឌតម្រូវពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ............ ៣១

៨- ការរាយការណ៍ ............ ៣២

**៤- គម្រោងចំណាយ** ..................................................................................................................... ៣៣
**៥- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** .......................................................................................... ៤៨
**៦- សេចក្តីសន្និដ្ឋាន** ...................................................................................................................... ៤៨
ឧបសម្ព័ន្ធ១: ការចុះបញ្ជីនាវា និងការផ្តល់លិខិតអនុញ្ញាតនាពេលបច្ចុប្បន្ន ..................................... ៤៩
ឧបសម្ព័ន្ធ២: សកម្មភាពជាក់លាក់ សម្រាប់អនុវត្តរយៈពេល៣ឆ្នាំនៃផែនការសកម្មភាពស្តីពីការបង្ការ ទប់ស្កាត់ និងការលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ២០២០-២០២២ .................................................................... ៥១
១- សេចក្តីផ្តើម ............................................................................................................ ៥១
២- ផែនការសកម្មភាព ..................................................................................................... ៥១
ក- សកម្មភាពអាទិភាព សូចនាករសំខាន់ៗ និងស្ថាប័នអនុវត្ត ........................................ ៥១
ខ- ផែនការសកម្មភាពអាទិភាពលម្អិត៣ឆ្នាំរំកិល ............................................................ ៥២
១- ការទទួលខុសត្រូវរបស់រដ្ឋ .................................................................................... ៥២
២- ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ឆ្នេរ ............................................ ៥៤
៣- ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិ .......................................... ៦០
៤- វិធានការរបស់រដ្ឋម្ចាស់កំពង់ផែ .............................................................................. ៦២
៥- វិធានការទាក់ទងនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ ......................................... ៦៤
៦- កិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់និងប្រទេសផ្សេងទៀត ដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ...... ៦៤
៧- លក្ខខណ្ឌតម្រូវពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ............................................. ៦៥
៨-ការរាយការណ៍ ..................................................................................................... ៦៥
គ- តារាងសកម្មភាពអាទិភាព សូចនាករ និងស្ថាប័នទទួលខុសត្រូវ ..................................... ៦៧
ឃ- តារាងសកម្មភាពនិងថវិកា .................................................................................... ៧៧
**សន្ទានុក្រម** ............................................................................................................................ ៨៦
**ឯកសារយោង** ......................................................................................................................... ៨៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលជារបៀបវារៈគោលនយោបាយសង្គមនិងសេដ្ឋកិច្ចសម្រាប់នីតិកាលទី៦នៃរដ្ឋសភាដែលជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលដោយបានបង្ហាញពីសមិទ្ធផលដ៏ត្រចះត្រចង់ កំណត់បញ្ហាប្រឈម និងកាលានុវត្តភាពនានាតាមគោលការណ៍អាទិភាវូនីយកម្មសម្រាប់កម្ពុជាដែលបានឆ្លងកាត់ដោយជោគជ័យឈានចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច មានចំណូលទាបក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥កន្លងទៅ និងឆ្ពោះទៅសម្រេចគោលដៅប្រកបដោយមហិច្ឆតាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នាឆ្នាំ២០៥០។

ប្រាកដណាស់ថា ក្នុងបរិបទបច្ចុប្បន្ននេះ ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតជាបញ្ហាដ៏ធ្ងន់ធ្ងរនៅក្នុងវិស័យជលផលពិភពលោក ដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រងអភិរក្សនិងនិរន្តរភាពធនធានជលផលយូរអង្វែង។ ស្ថានភាពបែបនេះបាននាំឱ្យបាត់បង់ទាំងឱកាសសង្គម និងសេដ្ឋកិច្ចរយៈពេលខ្លីនិងវែងដែលបណ្តាលឱ្យបាត់បង់នូវប្រាក់ចំណូលសម្រាប់សហគមន៍តំបន់ឆ្នេរ និងសេដ្ឋកិច្ចរដ្ឋតំបន់ឆ្នេរទាំងមូល ព្រមទាំងបង្កផលប៉ះពាល់អវិជ្ជមានលើសន្តិសុខស្បៀងនិងកិច្ចការពារបរិស្ថានផងដែរ។

ជាការឆ្លើយតប ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតឆ្នាំ២០២០-២០២៤នេះ ត្រូវបានរៀបចំឡើងផ្អែកលើផែនការសកម្មភាពអន្តរជាតិ ផែនការសកម្មភាពថ្នាក់តំបន់ និងគោលការណ៍ណែនាំរបស់អាស៊ាន លេខាធិការដ្ឋានអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ស្តីពីការបង្ការ ការនាំចូលផល ផលិតផលជលផលពីសកម្មភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ចូលទៅក្នុងខ្សែច្រវាក់ផលិតកម្ម។

គោលបំណងនៃផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតគឺដើម្បីប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដោយអនុវត្តវិធានការដ៏ទូលំទូលាយ មានប្រសិទ្ធភាព តម្លាភាព និងដើម្បីផ្តល់ប្រសិទ្ធភាពពេញលេញនូវការអនុវត្តបទប្បញ្ញត្តិដែលជាផ្នែកសំខាន់នៃកម្មវិធីគ្រប់គ្រងជលផល។

ផែនការសកម្មភាពជាតិនេះ ត្រូវបានរៀបចំឡើងដោយមានសកម្មភាពសំខាន់ៗដូចជា ការកែសម្រួលលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងវិស័យជលផល ការរៀបចំនិងអនុម័តផែនការត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ ការបណ្តុះបណ្តាលអ្នកអង្កេតការណ៍និងមន្ត្រីអធិការកិច្ចកំពង់ផែនេសាទ កាតព្វកិច្ចធ្វើរបាយការណ៍ និងការកត់ត្រាប្រព័ន្ធតាមដាននាវានេសាទជាដើម។

អត្ថប្រយោជន៍ដែលទទួលបានពីផែនការសកម្មភាពជាតិនេះរួមមាន ការកាត់បន្ថយការនេសាទខុសច្បាប់ ការធានាសុខុមាលភាពផលស្តុកត្រីនិងការកើនឡើងផលនេសាទ ការបង្កើនប្រាក់ចំណេញដែលនាំឱ្យជីវភាពប្រជានេសាទប្រសើរឡើង ការកាត់បន្ថយជម្លោះរវាងអ្នកនេសាទខ្នាតតូច មធ្យម និងខ្នាតធំ ការកាត់បន្ថយការចំណាយលើការល្បាត និងការកើនឡើងទីផ្សារនិងឱកាសធ្វើពាណិជ្ជកម្ម។ មិនតែប៉ុណ្ណោះ ផែនការសកម្មភាពជាតិនេះ គឺជាការបង្ហាញអំពីឆន្ទៈរបស់ប្រទេសកម្ពុជាក្នុងការចូលរួមទប់ស្កាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតជាមួយសហគមន៍អាស៊ាននិងអន្តរជាតិ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្រេចអនុម័តដាក់ចេញជាផ្លូវការនូវផែនការសកម្មភាពជាតិនេះសម្រាប់អនុវត្តទូទាំងប្រទេសដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ វិស័យឯកជន សហគមន៍ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីប្រើប្រាស់ជាមធ្យោបាយគន្លឹះក្នុងការដោះស្រាយនូវបញ្ហាប្រឈមទាំងឡាយដូចបានរៀបរាប់ខាងលើ។

ខ្ញុំសូមថ្លែងអំណរគុណដល់អ្នករួមចំណែកទាំងអស់ ចំពោះការខិតខំប្រឹងប្រែងក្នុងការជួយរាជរដ្ឋាភិបាលឱ្យសម្រេចបាននូវឯកសារផែនការសកម្មភាពជាតិដ៏មានសារសំខាន់នេះ ហើយខ្ញុំមានក្តីសង្ឃឹមនិងរំពឹងថាស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសដៃគូអភិវឌ្ឍ ប្រាកដជានឹងចូលរួមគាំទ្រការអនុវត្តផែនការសកម្មភាពជាតិនេះឱ្យមានប្រសិទ្ធភាពនិងសម្រេចបានលទ្ធផលដូចការគ្រោងទុក ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីផលប្រយោជន៍ជាតិមាតុភូមិនិងប្រជានេសាទ ឆ្លើយតបទៅនឹងចក្ខុវិស័យនិងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។

ថ្ងៃ អង្គារ ៨កើត ខែ ស្រាពណ៍ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២០

**ហ៊ុន សែន**

# អារម្ភកថា

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ដាក់ចេញនូវគោលនយោបាយជាយុទ្ធសាស្ត្រ គោលនយោបាយអភិវឌ្ឍតាមវិស័យ និងវិធានការជាក់ស្តែង តាមគោលការណ៍អាទិភាវូនីយកម្ម សម្រាប់អនុវត្តចាប់ពីឆ្នាំ២០១៩ទៅ ដែលជាត្រីវិស័យតម្រង់ទិសសកម្មភាពនានារបស់រដ្ឋាភិបាល ក្នុងការបំពេញភារកិច្ចបម្រើជាតិឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ស៊ីជម្រៅរបស់ជាតិ និងប្រជាជនយើង។

ក្នុងបរិបទនេះដែរ ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ត្រូវបានទទួលស្គាល់ថាជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏ធ្ងន់ធ្ងរជាច្រើន ដែលធ្វើឱ្យប៉ះពាល់ដល់ការនេសាទនៅលើពិភពលោក និងជាឧបសគ្គដ៏ចម្បងក្នុងការសម្រេចបាននូវការនេសាទប្រកបដោយចីរភាពនៅទូទាំងពិភពលោក។ តាមការប៉ាន់ប្រមាណបង្ហាញថាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត មានបរិមាណប្រហែលមួយភាគបី(១/៣) នៃបរិមាណផលនេសាទសរុបនៅក្នុងការនេសាទសំខាន់ៗមួយចំនួន។ ជាមួយគ្នានេះដែរ តាមការស្រាវជ្រាវនិងវាយតម្លៃ នាពេលថ្មីៗនេះបានបង្ហាញថា ព្រះរាជាណាចក្រកម្ពុជាបានខាតបង់ផលនេសាទសមុទ្រចំនួនពី ២៦ ៥០០ ទៅ ៣៧ ៥០០តោន ដែលមានតម្លៃស្មើនឹង២៧ ទៅ៥៦លានដុល្លារអាមេរិក។

ភាពចាំបាច់នៃការរៀបចំឱ្យមានជាផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឆ្នាំ២០២០-២០២៤ នេះឡើង គឺដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកំពុងកើតឡើងនេះ ក្រោមគំនិតផ្តួចផ្តើមមួយចំនួនដែលបានបង្កើតឡើងទាំងនៅសកលលោកនិងនៅថ្នាក់តំបន់ ដើម្បីគាំទ្រដល់ការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ បច្ចុប្បន្ននេះ មានលិខិតតុបករណ៍អន្តរជាតិជាច្រើនដូចជា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ឆ្នាំ១៩៨២ កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ក្រមប្រតិបត្តិសម្រាប់ការធ្វើនេសាទដោយទទួលខុសត្រូវរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទ ខុសច្បាប់គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត គោលការណ៍ណែនាំឱ្យអនុវត្តដោយស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ដើម្បីធានាដល់ការនេសាទខ្នាតតូចប្រកបដោយនិរន្តរភាព នៅក្នុងបរិបទសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ(ឆ្នាំ២០១៥) និងផែនការសកម្មភាពអន្តរជាតិដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ ដោយឡែក នៅតំបន់អាស៊ីអាគ្នេយ៍ មានផែនការសកម្មភាពថ្នាក់តំបន់ដើម្បីលើកកម្ពស់ការនេសាទប្រកបដោយការទទួលខុសត្រូវរួមទាំងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងតំបន់ និងគោលការណ៍ណែនាំសម្រាប់ទប់ស្កាត់ការនាំចូលផល ផលិតផលជលផលពីសកម្មភាពនេសាទ ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតចូលទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ សម្រាប់ដោះស្រាយបញ្ហាថ្នាក់តំបន់របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍។

ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដោយនាវានេសាទជាតិនិងនាវានេសាទបរទេសនៅក្នុងដែនសមុទ្រកម្ពុជា ជាហេតុធ្វើឱ្យមានការនេសាទហួសកម្រិតលើធនធានដែលមាន។ ការនេសាទហួសកម្រិតនេះ នាំទៅរកការកើនឡើងនូវសកម្មភាពខុសច្បាប់ដែលមិនអាចគ្រប់គ្រងបាន ដោយសារតែមានភាពកម្សោយនូវការតាមដាន ត្រួតពិនិត្យ និងអង្កេត។ កន្លងមក នាវានេសាទ និងនាវាដឹកជញ្ជូនឬនាវាគាំទ្រមួយចំនួនដែលបំពាក់ទង់ជាតិកម្ពុជាត្រូវបានរាយការណ៍ថាជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

នៅក្នុងតំបន់ដែលគ្រប់គ្រងដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់មួយចំនួន។ ទោះជាយ៉ាងនេះក្តីរាជរដ្ឋាភិបាលកម្ពុជាបានលុបចោលនូវការចុះបញ្ជីនាវានេសាទ និងនាវាផ្ទេរផលនេសាទនៅលើផ្ទៃសមុទ្រទាំងអស់ ដែលបានប្រើប្រាស់ទង់ជាតិកម្ពុជា និងបានចុះបញ្ជីដោយក្រុមហ៊ុនកូរ៉េខាងត្បូងឈ្មោះកូស្វូស។ វិធានការនេះមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦មក។

ក្នុងបរិការណ៍នេះ ផែនការសកម្មភាពអន្តរជាតិ និងផែនការសកម្មភាពថ្នាក់តំបន់ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត បានអំពាវនាវឱ្យរដ្ឋនានាបង្កើតផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ ជាការឆ្លើយតបក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្កើតផែនការសកម្មភាពជាតិនេះដោយឆ្លងកាត់ការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអន្តរស្ថាប័ននិងអង្គភាពពាក់ព័ន្ធទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិសម្រាប់ដឹកនាំ គ្រប់គ្រងសកម្មភាពប្រយុទ្ធប្រឆាំង និងទប់ស្កាត់បទល្មើសនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១៨ ចំនួនពីរលើកគឺក្នុងខេត្តកំពតនិងខេត្តកែប។ ក្នុងឆ្នាំ២០១៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រជុំពិគ្រោះយោបល់ផ្ទៃក្នុងជាមួយអង្គភាពពាក់ព័ន្ធ បន្ទាប់មកបានប្រជុំពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងចុងក្រោយប្រជុំពិគ្រោះយោបល់ជាមួយអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី។

ជារួម ផែនការសកម្មភាពជាតិដែលបានរៀបចំនេះ គឺបានលើកឡើងនូវសកម្មភាពជាច្រើនដែលនឹងត្រូវអនុវត្ត ដើម្បីប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ក្នុងដែនសមុទ្រកម្ពុជា និងបានបញ្ជាក់អំពីតម្រូវការកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងសកលលោក ក្នុងគោលបំណងទទួលបានប្រសិទ្ធភាពនូវការប្រយុទ្ធប្រឆាំងទៅនឹងអ្វីដែលជាបញ្ហានៅក្នុងតំបន់និងសកលលោក។ ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឆ្នាំ២០២០-២០២៤ ត្រូវបានរៀបចំឡើងដោយមានឯកសារអមចំនួនពីរគឺ ទី១ សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលការណ៍គន្លឹះក្នុងការគ្រប់គ្រងជលផលសមុទ្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងទី២ ផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រឆ្នាំ២០២០-២០២៤។

យើងសង្ឃឹមថា ជាមួយនឹងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត វិស័យជលផលសមុទ្ររបស់កម្ពុជា ប្រាកដជារួមចំណែកបន្ថែមដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រដ្ឋាភិបាលសម្រាប់វិស័យជលផល ជាពិសេសដើម្បីជាប្រយោជន៍ដល់អ្នកនេសាទនិងភាពកក់ក្តៅរបស់សហគមន៍នេសាទដែលពឹងផ្អែកលើធនធានជលផលសមុទ្រសម្រាប់ជីវភាពរស់នៅរបស់ពួកគេនៅក្នុងសហគមន៍តំបន់ឆ្នេរ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# អក្សរកាត់

APEC Asian Pacific Economic Cooperation កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក

APFIC Asia Pacific Fisheries Commission គណៈកម្មាធិការជលផលអាស៊ីប៉ាស៊ីហ្វិក

AMS ASEAN Member State រដ្ឋសមាជិកអាស៊ាន

ASSDP Agricultural Sector Strategic Development Plan ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម

ASEAN Association of South East Asian Nations សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

CFi Community Fishery សហគមន៍នេសាទ

CITES Convention of International Trade in Endangered Species of Wild Fauna and Flora អនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

EC European Commission គណៈកម្មការអឺរ៉ុប

EEZ Exclusive Economic Zone តំបន់សេដ្ឋកិច្ចផ្ដាច់មុខ

FAO Food and Agriculture Organization of the United Nations អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

FAO CCRF FAO Code of Conduct for Responsible Fisheries ក្រមប្រតិបត្តិរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិសម្រាប់ការនេសាទដោយការទទួលខុសត្រូវ

FiA Fisheries Administration រដ្ឋបាលជលផល

IPOA-IUU International Plan of Action to Prevent, Deter and Eliminate Illegal, Unregulated and Unreported Fishing ផែនការសកម្មភាពអន្តរជាតិស្ដីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

IUU Fishing Illegal, Unregulated and Unreported Fishing ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

MAFF Ministry of Agriculture, Forestry and Fisheries ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

MCS Monitoring, Control and Surveillance ការតាមដាន ត្រួតពិនិត្យ និងការអង្កេត

MoU Memoranda of Understanding អនុស្សរណៈនៃការយោគយល់

MPWT Ministry of Public Works and Transport ក្រសួងសាធារណការ និងដឹកជញ្ជូន

NACA Network of Aquaculture Centres in Asia and the Pacific បណ្ដាញមជ្ឈមណ្ឌលវារីវប្បកម្មនៅអាស៊ីនិងប៉ាស៊ីហ្វិក

NPOA-IUU National Plan of Action to prevent, deter and eliminate Illegal, Unreported and Unregulated Fishing ផែនការសកម្មភាពជាតិស្ដីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

NSDP National Strategic Development Plan ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

PSMA Port State Measurements Agreement វិធានការរដ្ឋម្ចាស់កំពង់ផែ

RFMOs Regional Fisheries Management Organizations អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់

RPOA-IUU Regional Plan of Action to to Prevent, Deter and Eliminate Illegal, Unreported, and Unregulated Fishing ផែនការសកម្មភាពថ្នាក់តំបន់ ស្ដីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

SEAFDEC South East Asian Fisheries Development Centre មជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍

SPFF Strategic Planning Framework for Fisheries ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល

UNCLOS United Nations Convention on the Law of the Sea អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ

UNFSA United Nations Fish Stock Agreement កិច្ចព្រមព្រៀងស្ដីពីផលស្តុកត្រីនៃអង្គការសហប្រជាជាតិ

VMS Vessel monitoring system ប្រព័ន្ធតាមដាននាវានេសាទ

# សេចក្តីសង្ខេប

ជាច្រើនឆ្នាំកន្លងមកនេះ វិស័យជលផលកម្ពុជា បានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់នូវការងារនិងជីវភាពរស់នៅដល់ប្រជាពលរដ្ឋក្រីក្រ ក៏ដូចជាសន្តិសុខស្បៀង ផលិតផលក្នុងស្រុកសរុប (GDP) និងសម្រាប់ដោះដូររូបិយប័ណ្ណបរទេស។ ផលនេសាទសមុទ្រដែលបានរួមចំណែកក្នុងផលនេសាទសរុបមានការកើនឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០០៨ ហើយបរិមាណផលចាប់មានប្រមាណជាង១២០ ០០០តោនក្នុងឆ្នាំ២០១៧។ ផលិតផលនេសាទសមុទ្រត្រូវបានគេប៉ាន់ប្រមាណថាមានតម្លៃប្រហែលពី២០០-៣០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ គិតនៅកន្លែងផែនេសាទនិងផែឡើងផលនេសាទ។ វិស័យជលផលបានរួមចំណែកពី៦-៨ភាគរយនៃផលិតផលក្នុងស្រុកសរុប។

ទោះជាយ៉ាងនេះក្តី ធនធានជលផលសមុទ្រនៃប្រទេសកម្ពុជាត្រូវបានទទួលរងការគំរាមកំហែងដោយការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត (IUU Fishing)។ បច្ចុប្បន្ននេះ ការនេសាទខុសច្បាប់ត្រូវបានគេទទួលស្គាល់ជាបញ្ហាសកល ហើយជាបញ្ហាធ្ងន់ធ្ងរដែលប៉ះពាល់ដល់ធនធានជលផលពិភពលោក និងជាឧបសគ្គចម្បងក្នុងការរក្សាឱ្យបាននូវនិរន្តរភាពនៃធនធានជលផល។ តាមការប៉ាន់ប្រមាណបានឱ្យដឹងថាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតមានចំនួនមួយភាគបី (១/៣) នៃផលនេសាទសរុបនៅក្នុងវិស័យជលផល។ ការប៉ាន់ប្រមាណក្នុងពេលថ្មីៗនេះបានបង្ហាញថាកម្ពុជាមានការខាតបង់ពី២៦៥០០-៣៧៥០០តោន ដែលមានតម្លៃស្មើនឹង២៧-៥៦លានដុល្លារអាមេរិក។

សហគមន៍អន្តរជាតិបានទទួលស្គាល់ពីតម្រូវការសកម្មភាពកម្រិតសកល តំបន់ និងជាតិក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ចាប់តាំងពីចុងទសវត្សឆ្នាំ១៩៩០។ ជាលទ្ធផល ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត (IPOA-IUU) ត្រូវបានរៀបចំនៅក្នុងឆ្នាំ២០០០។ នៅតំបន់អាស៊ីអាគ្នេយ៍ ការរៀបចំផែនការសកម្មភាពថ្នាក់តំបន់ (RPOA-IUU) គឺដើម្បីជំរុញការនេសាទប្រកបដោយទទួលខុសត្រូវ រួមមានការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងតំបន់ និងគោលការណ៍ណែនាំរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ក្នុងក្របខ័ណ្ឌអាស៊ាន (ASEAN-SEAFDEC) ស្តីពីការការពារការនាំចូលនៃផល ផលិតផលជលផលពីសកម្មភាពនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាតទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ដើម្បីដោះស្រាយបញ្ហានៅក្នុងតំបន់។

ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត (NPOA-IUU Fishing) ដែលបានរៀបចំឡើង ដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាលកម្ពុជាថា ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតគឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរកម្រិតថ្នាក់ជាតិនិងអន្តរជាតិទៅលើធនធានជលផលសមុទ្រ។ បញ្ហាទាំងនេះរួមមានការនេសាទគ្មានការអនុញ្ញាត ដោយនាវានេសាទក្នុងស្រុក និងក្រៅស្រុកដែលនាំឱ្យមានការនេសាទហួសកម្រិត បណ្តាលឱ្យកើនឡើងនូវសកម្មភាពនេសាទខុសច្បាប់ដែលពិបាកក្នុងការគ្រប់គ្រងដោយសារតែការតាមដាន ត្រួតពិនិត្យ និងការអង្កេត (MCS) នៅមានកម្រិត។ កន្លងមកមានរបាយការណ៍ជាច្រើនបង្ហាញថានាវានេសាទ នាវាដឹកជញ្ជូន និងនាវាផ្គត់ផ្គង់មួយចំនួនដែលប្រើទង់

ជាតិកម្ពុជា ជានាវាខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ (RFMOs)។ រាជរដ្ឋាភិបាលកម្ពុជាបានលុបចោល នូវការចុះបញ្ជីនាវានេសាទ និងនាវាផ្ទេរផលនេសាទនៅលើផ្ទៃសមុទ្រទាំងអស់ ដែលបានប្រើប្រាស់ទង់ជាតិកម្ពុជា និងបានចុះបញ្ជីដោយក្រុមហ៊ុនកូរ៉េខាងត្បូងឈ្មោះកូសួស។ វិធានការនេះមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦មក។

ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតបានណែនាំនូវវិធានការជាច្រើនដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ ផែនការសកម្មភាពជាតិនេះ ត្រូវបានតាក់តែងឡើងដោយអនុលោមតាមគោលការណ៍ណែនាំនៃផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

**តារាងខាងក្រោមគឺជាផែនការសកម្មភាពអាទិភាពនិងពេលវេលាសម្រាប់អនុវត្ត**

ផែនការសកម្មភាពជាអាទិភាពនេះគឺផ្អែកលើលទ្ធភាពថវិការបស់រាជរដ្ឋាភិបាល និងថវិកាតាមរយៈកម្មវិធីសម្រាប់អភិវឌ្ឍវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នសមាសភាគការនេសាទ (CAPFish Capture) ដែលនឹងទទួលបានមូលនិធិពីសហភាពអឺរ៉ុប។ ប្រសិនបើការផ្តល់មូលនិធិមិនត្រូវបានអនុម័ត ផែនការសកម្មភាពទាំងនេះត្រូវកែសម្រួល។ ផែនការសកម្មភាពដែលភ្ជាប់ជាមួយផែនការសកម្មភាពជាតិនេះរួមមាន សូចនាករនៃការអនុវត្តសំខាន់ៗ ដែលអាចត្រូវបានប្រើសម្រាប់តាមដាន និងវាយតម្លៃការរីកចម្រើនឆ្លើយតបទៅនឹងសកម្មភាពរបស់ផែនការសកម្មភាពជាតិ។

| សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|
| រៀបចំបែបបទលិខិតរដ្ឋបាលក្នុងការស្នើសុំចូលជារដ្ឋសមាជិកនៃវិធានការរដ្ឋម្ចាស់កំពង់ផែ និងការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តីពីផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយរបស់អង្គការសហប្រជាជាតិ | ✓ | ✓ | | | |
| បន្តពិនិត្យឡើងវិញនិងធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល ព្រមទាំងកសាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដើម្បីបម្រើឱ្យវិស័យជលផលសមុទ្រ | ✓ | ✓ | ✓ | | |
| រៀបចំផែនការជាតិគ្រប់គ្រងជលផលសមុទ្រ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ | ✓ | ✓ | | | |
| កែសម្រួលប្រព័ន្ធប្រមូលទិន្នន័យនិងព័ត៌មានតាមកំពង់ផែ និងការវិភាគនានា | ✓ | ✓ | | | |
| កែសម្រួលប្រព័ន្ធព័ត៌មានជលផលនិងការប្រមូលទិន្នន័យសម្រាប់ការគ្រប់គ្រងនិងធ្វើសេចក្តីសម្រេចលើផ្នែកគោលនយោបាយ និងចែករំលែកជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | ✓ | ✓ | | | |

| | | | | | |
|---|---|---|---|---|---|
| ស្រាវជ្រាវ ចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតនាវានេសាទខ្នាតមធ្យម និងខ្នាតធំ | ✓ | ✓ | ✓ | | |
| ចុះបញ្ជីនិងផ្តល់ប័ណ្ណសម្គាល់នាវានេសាទខ្នាតតូច | ✓ | ✓ | ✓ | ✓ | ✓ |
| បន្តលើកកម្ពស់ការអនុវត្តច្បាប់មិនឱ្យមាននាវានេសាទថៃនិងវៀតណាមខុសច្បាប់ចូលនេសាទក្នុងដែនសមុទ្រកម្ពុជាដោយអនុវត្តកិច្ចសហប្រតិបត្តិការជាមួយប្រទេសថៃនិងវៀតណាម | ✓ | ✓ | ✓ | ✓ | ✓ |
| ឯកភាពលើវិធានការទូទៅស្តីពីការគ្រប់គ្រងនិងអភិរក្សជលផលនៅក្នុងតំបន់សមុទ្រទាមទារត្រួតគ្នានិងតំបន់ទឹកប្រវត្តិសាស្ត្រ | | ✓ | | | |
| ចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតដល់នាវាដឹកជញ្ជូនផល ផលិតផលជលផល និងមធ្យោបាយដឹកជញ្ជូនពាក់ព័ន្ធ ដើម្បីធ្វើការនាំចេញ | ✓ | ✓ | | | |
| បន្តរៀបចំ និងអនុវត្តផែនការត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ | ✓ | ✓ | | | |
| សហការក្នុងការវិភាគតម្លៃដាក់ទុន និងផលចំណេញ (ប្រសិទ្ធភាពសេដ្ឋកិច្ច) សម្រាប់ការបើកឱ្យមានការចុះបញ្ជីនាវានេសាទបរទេសឡើងវិញ | ✓ | | | | |
| ប្រសិនបើមានផលចំណូលសមស្រប រៀបចំប្រព័ន្ធចុះបញ្ជី និងកត់ត្រានាវានេសាទដែលប្រើប្រាស់ទង់ជាតិកម្ពុជា នេសាទក្នុងរដ្ឋដទៃឬនៅសមុទ្រអន្តរជាតិរួមទាំងវិធានការត្រួតពិនិត្យនិងអធិការកិច្ចដ៏មានប្រសិទ្ធភាព | | ✓ | | | |
| អនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែដោយកំណត់ និងរៀបចំកន្លែងឡើងផលនេសាទឬកំពង់ផែសម្រាប់នាវានេសាទបរទេស | ✓ | ✓ | | | |
| អនុម័តនិងសាកល្បងអនុវត្តកម្មវិធី "កម្រងឯកសារផលចាប់ត្រីរបស់អាស៊ាន និងលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍" | | ✓ | ✓ | ✓ | |

## ១- សាវតារ

ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ត្រូវបានទទួលស្គាល់ទូទាំងពិភពលោកថាជាបញ្ហាមួយក្នុងចំណោមបញ្ហាចម្បងៗដែលប៉ះពាល់ដល់និរន្តរភាពនៃវិស័យជលផល។ តាមការប៉ាន់ប្រមាណបានបង្ហាញថាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតទូទាំងពិភពលោកគិតជាទឹកប្រាក់សរុបប្រមាណពី១០-២៣ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ[១]។ ផលនេសាទខុសច្បាប់ដែលបានធ្វើនេសាទដោយនាវាបរទេសនៅក្នុងដែននេសាទសមុទ្រនៃរដ្ឋដទៃនៅក្នុងតំបន់អាស៊ី ត្រូវបានប៉ាន់ប្រមាណថាមានបរិមាណពី២,១-២,៥ លានតោន ដែលមានតម្លៃស្មើនឹង៣,៧-៥,២ ពាន់លានដុល្លារអាមេរិក។ យ៉ាងណាមិញ តាមការប៉ាន់ប្រមាណនាពេលថ្មីៗបានបង្ហាញថា កម្ពុជាខាតបង់ផលនេសាទ ប្រមាណពី២៦ ៥០០-៣៧ ៥០០តោន ដែលមានតម្លៃពី២៧-៥៦លានដុល្លារអាមេរិក[២]។

សកម្មភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត រួមមានការនេសាទដោយគ្មានការអនុញ្ញាតនៅក្នុងដែននេសាទសមុទ្រនៃរដ្ឋដទៃ ការរំលោភច្បាប់ជាតិនិងអន្តរជាតិ បទបញ្ញានិងបទប្បញ្ញត្តិនានាដែលចែងពីវិធានការបច្ចេកទេសឬគ្រប់គ្រងនាវាបរទេសដែលប្រើទង់ជាតិនៃប្រទេសដទៃទៀត ដែលមិនមានការអនុញ្ញាត គ្មានឯកសារត្រឹមត្រូវ និងក្នុងករណីខ្លះថែមទាំងមានគោលដៅចាប់ប្រភេទវារីសត្វដែលកំពុងរងគ្រោះ កំពុងរងការគំរាមកំហែងឬប្រភេទដែលត្រូវការពារ។ នៅក្នុងតំបន់មួយចំនួននៅលើពិភពលោក ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ក៏មានជាប់ពាក់ព័ន្ធជាមួយនឹងបទឧក្រិដ្ឋឆ្លងដែនលើលម្ហសមុទ្រដែរ ដូចជាការរត់ពន្ធមនុស្ស ការតាមដានកន្លែងនេសាទសត្វសមុទ្រ ការជួញដូរគ្រឿងញៀននិងអាវុធជាដើម។

ការកាត់បន្ថយការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត បានផ្តល់នូវសារប្រយោជន៍ជាច្រើនដូចជា ផលស្តុកនិងផលនេសាទកើនឡើង ការបង្កើនប្រាក់ចំណូលដល់ប្រជានេសាទខ្នាតតូច ការកាត់បន្ថយជម្លោះរវាងប្រជានេសាទខ្នាតតូចនិងអ្នកនេសាទខ្នាតធំ ការចំណាយតិចលើការល្បាត និងការបង្កើនឱកាសពាណិជ្ជកម្មសម្រាប់កម្ពុជាទទួលបានការផ្តល់សិទ្ធិនាំចេញផល ផលិតផលជលផល ទៅកាន់បណ្តាប្រទេសសមាជិកសហភាពអឺរ៉ុប ឧទាហរណ៍ ការដកចេញនូវ "កាតក្រហម" នៃការដាក់ទណ្ឌកម្មពីការនាំចេញផល ផលិតផលជលផលចេញពីកម្ពុជាទៅកាន់សហភាពអឺរ៉ុប។

ក្នុងតំបន់និងលើសកលលោក មានគំនិតផ្តួចផ្តើមជាច្រើន សម្រាប់ការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក មានគំនិតផ្តួចផ្តើមសំខាន់ៗចំនួនបីគឺ ផែនការសកម្មភាពអន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ផែនការសកម្មភាពថ្នាក់តំបន់ដើម្បីជំរុញការអនុវត្តការនេសាទប្រកបដោយការទទួលខុសត្រូវ រួមទាំងការប្រយុទ្ធប្រឆាំងនឹងការនេសាទ ខុសច្បាប់គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងតំបន់ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ គោលការណ៍ណែនាំរបស់អាស៊ានស្តីពីការបង្ការ ការនាំចូលផល ផលិតផលជលផលពីសកម្មភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ចូលទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់។ ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការ

នេសាទខុសច្បាប់គ្មានរបាយការណ៍និងគ្មានការអនុញ្ញាតរបស់កម្ពុជា ត្រូវបានបង្កើតឡើងដោយអនុលោមតាមគោលការណ៍ និងបទប្បញ្ញត្តិនានានៃផែនការសកម្មភាពនិងគោលការណ៍ណែនាំថ្នាក់តំបន់ និងអន្តរជាតិ។

## ១.១- ច្បាប់ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

### ច្បាប់ស្តីពីជលផលកម្ពុជាឆ្នាំ២០០៦

ច្បាប់ស្តីពីជលផលនៅកម្ពុជាក្រោយឆ្នាំ១៩៧៩ គឺជាក្រឹត្យច្បាប់ស្តីពីការគ្រប់គ្រងធនធានជលផលដែលបានចូលជាធរមាននៅខែមីនា ឆ្នាំ១៩៨៧។ បន្ទាប់មកច្បាប់ស្តីពីជលផលដែលកំពុងអនុវត្តមកទល់ពេលនេះបានចូលជាធរមាននៅក្នុងខែឧសភា ឆ្នាំ២០០៦។ បច្ចុប្បន្ន ច្បាប់នេះកំពុងស្ថិតក្រោមការពិនិត្យឡើងវិញ (មើលចំណុច ៣.២.១)។ ច្បាប់ជលផលមាន ១០៩មាត្រា ដែលក្នុងនោះរួមមាននិយមន័យ ការគ្រប់គ្រង ការធ្វើអាជីវកម្មធនធានជលផល (មាត្រា៣០-៣៨) ការធ្វើអាជីវកម្មធនធានជលផលសមុទ្រ (មាត្រា៤៥-៥២) ការចេញលិខិតអនុញ្ញាត (មាត្រា៧០-៧១) នីតិវិធីដោះស្រាយបទល្មើសជលផល (មាត្រា៧២-៨៥) ទោសប្បញ្ញត្តិ(មាត្រា៨៦-១០៤) និងការអនុវត្តសាលក្រមតុលាការ (មាត្រា១០៥-១០៧)។ ច្បាប់នេះមានចែងពីវិធានការគ្រប់គ្រងជាក់លាក់ដែលពាក់ព័ន្ធជាមួយនឹងឧបករណ៍នេសាទហាមឃាត់ក្នុងតំបន់ហាមឃាត់ (តំបន់បិទនេសាទចំពោះអួនអូស) ការបិទនេសាទតាមរដូវនិងទំហំក្រឡាមងអួន។

### ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣បច្ចុប្បន្ន បានបញ្ចូលកម្មវិធីកំណែទម្រង់វិស័យធំៗចំនួន៤ ដើម្បីលើកកម្ពស់អភិបាលកិច្ចៈ (១) ការប្រយុទ្ធប្រឆាំងអំពើពុករលួយ (២) ការធ្វើកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ (៣) ការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈរួមទាំងវិមជ្ឈការនិងវិសហមជ្ឈការ និង(៤) ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ក៏ដូចជាកម្មវិធីកំណែទម្រង់ផ្សេងៗទៀតរួមទាំងវិស័យជលផលផងដែរ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨ បានផ្តោតសំខាន់លើការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ជាពិសេសធនធានព្រៃឈើនិងធនធានជលផល ក្នុងគោលបំណងដើម្បីបង្កើនល្បឿនកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ដោយឡែកក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ បច្ចុប្បន្នភាពនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១៥-២០២៤ និងក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផលកម្ពុជា ដែលបានទទួលស្គាល់ថាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត គឺជាបញ្ហាសំខាន់មួយដែលត្រូវដោះស្រាយ។ ម្យ៉ាងទៀត ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១៥-២០២៤ គឺសំដៅពិសេសលើ "ការយកចិត្តទុកដាក់យ៉ាងសំខាន់លើការកសាងសមត្ថភាពនៅក្នុងរដ្ឋបាលជលផល ដើម្បីទប់ទល់នឹងនិន្នាការសកម្មភាពនេសាទខុសច្បាប់នៅក្នុងវិស័យជលផលទាំងមូល តាមរយៈការរៀបចំនិងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព"។ ការគាំទ្រនេះ គឺជាធាតុចូលមួយដ៏សំខាន់ដែលនឹងត្រូវផ្តល់ដល់វិស័យឯកជនឱ្យយល់កាន់តែប្រសើរជាងមុនអំពីបទប្បញ្ញត្តិនិងផលវិបាកនៃការមិនគោរពច្បាប់។

## ១.២- ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត បានផ្តល់ការណែនាំអំពីវិធានការនានាស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត រួមបញ្ចូលទាំងវិធានការណ៍ដែលបានអនុវត្ត តាមរយៈអង្គការគ្រប់គ្រងផលជលផលថ្នាក់តំបន់ឬក្រុមការងារនានាដែលបានបង្កើតឡើងដោយអនុលោមតាមច្បាប់អន្តរជាតិជាធរមាន។ ផែនការសកម្មភាពអន្តរជាតិនេះត្រូវបានអនុម័តជាឯកច្ឆន្ទ នាសម័យប្រជុំពេញអង្គលើកទី២៤ នៃគណៈកម្មការជលផលនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០០១ និងបានគាំទ្រដោយសម័យប្រជុំលើកទី១២០នៃក្រុមប្រឹក្សាអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០១។ សកម្មភាពសំខាន់មួយនៅក្នុងផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនេះ គឺជាការអំពាវនាវឱ្យរដ្ឋទាំងឡាយរៀបចំ និងអនុវត្តផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដើម្បីសម្រេចបាននូវគោលបំណងរបស់ផែនការសកម្មភាពអន្តរ-ជាតិដ៏មានសារៈសំខាន់នេះ និងដាក់បញ្ចូលសកម្មភាពនោះចូលជាផ្នែកមួយក្នុងគម្រោងថវិកា និងកម្មវិធីសម្រាប់គ្រប់គ្រងធនធានជលផលរបស់ខ្លួន។ លើសពីនេះទៅទៀត បទប្បញ្ញត្តិនៃផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតមួយចំនួនបានឆ្លុះបញ្ចាំងពីកាតព្វកិច្ចនានាដែលរដ្ឋជាច្រើនបានឯកភាពនិងអនុវត្ត តាមរយៈឯកសារគតិយុត្តដែលបានព្រមព្រៀងជាអន្តរជាតិ ព្រមទាំងអង្គការគ្រប់គ្រងផលជលថ្នាក់តំបន់ឬតាមរយៈច្បាប់ជាតិ។

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតគឺជា "ឯកសារគតិយុត្តដែលមិនមានកាតព្វកិច្ចតាមផ្លូវច្បាប់និងអនុវត្តដោយស្ម័គ្រចិត្ត"។ ផែន-ការសកម្មភាពនេះបានដកស្រង់ពីឯកសារគតិយុត្តអន្តរជាតិសំខាន់ៗ និងឯកសារគតិយុត្តស្តីពីជលផលដែលបានឯកភាពជាឯកច្ឆន្ទសម្រាប់ការលើកកម្ពស់ការអនុវត្តការនេសាទប្រកបដោយការទទួលខុសត្រូវ (ប្រអប់ទី១)។

**ប្រអប់ទី១: ឯកសារគតិយុត្តអន្តរជាតិពាក់ព័ន្ធ សម្រាប់បង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត**

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២ (កម្ពុជាពុំទាន់ចូលជាភាគីនៅឡើយទេ)
- កិច្ចព្រមព្រៀងដើម្បីជំរុញការអនុវត្តតាមវិធានការគ្រប់គ្រងនិងអភិរក្សអន្តរជាតិ ដោយនាវានេសាទនៅសមុទ្រអន្តរជាតិឆ្នាំ១៩៩៤
- កិច្ចព្រមព្រៀងទាក់ទងនឹងការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយឆ្នាំ(១៩៩៥) កិច្ចព្រមព្រៀងផលស្តុកត្រីរបស់អង្គការសហប្រជាជាតិ

- កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតឆ្នាំ២០០៩ កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ
- ក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល(១៩៩៥)
- គោលការណ៍ស្ម័គ្រចិត្តសម្រាប់និរន្តរភាពការនេសាទខ្នាតតូច នៅក្នុងបរិបទសុវត្ថិភាពស្បៀងនិងការកាត់បន្ថយភាពក្រីក្រ
- ផែនការសកម្មភាពអន្តរជាតិរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ សម្រាប់ការគ្រប់គ្រងនិងអភិរក្សឆ្លាមឆ្នាំ១៩៩៩ និងការគ្រប់គ្រងសមត្ថភាពនេសាទឆ្នាំ១៩៩៩។

**១.៣- បញ្ហាក្នុងតំបន់ពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត**

ផែនការសកម្មភាពថ្នាក់តំបន់ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៃតំបន់អាស៊ីអាគ្នេយ៍ ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយការព្រួយបារម្ភរបស់បណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍អំពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនេះ។ ផែនការនេះត្រូវបានអនុម័តដោយរដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌូនេស៊ី អូស្ត្រាលី ប្រ៊ុយណេ កម្ពុជា ម៉ាឡេស៊ី ប៉ាពូអាស៊ីណូវែលហ្គីណេ ហ្វីលីពីន សិង្ហបុរី ថៃ ទីម័រខាងកើត និងប្រទេសវៀតណាមនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៧ នៅកោះបាលី។ ក្របខ័ណ្ឌផែនការសកម្មភាពថ្នាក់តំបន់ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតមានមូលដ្ឋានផ្អែកលើផែនការសកម្មភាពអន្តរជាតិនេះជាចម្បង ប៉ុន្តែសកម្មភាពរបស់ផែនការសកម្មភាពថ្នាក់តំបន់ស្តីពីការបង្ការ ទប់ស្កាត់ និង លុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលបានអនុម័ត គឺមានភាពទូលំទូលាយដោយមិនត្រឹមតែលើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនោះទេ ហើយក៏មានរួមបញ្ចូលទាំងការអភិរក្សធនធានជលផលនិងបរិស្ថានរបស់វា ការគ្រប់គ្រងសមត្ថភាពនេសាទ និងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត នៅក្នុងតំបន់សមុទ្រចិនខាងត្បូង ឈូងសមុទ្រថៃ សមុទ្រ Sulu-Sulawesi (សមុទ្រ Celebes) និងសមុទ្រ Arafura-Timor ផងដែរ។

ម៉្យាងទៀត គោលការណ៍ណែនាំអាស៊ាន-លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ សម្រាប់បង្ការការនាំចូលផល ផលិតផលជលផលពីសកម្មភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតចូលទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ បានបង្ហាញពីសកម្មភាពដែលអាចអនុវត្តបាននាពេលអនាគតនៅក្នុងតំបន់អាស៊ានក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតមាន:

១-គ្រប់គ្រងសកម្មភាពនេសាទនៅក្នុងរដ្ឋដែលជាសមាជិកអាស៊ានដោយ:

- ត្រួតពិនិត្យការធ្វើនេសាទតាមរយៈប្រព័ន្ធចុះបញ្ជីនិងការផ្តល់អាជ្ញាបណ្ណត្រឹមត្រូវ
- ធ្វើបច្ចុប្បន្នភាពច្បាប់និងបទប្បញ្ញត្តិនានា
- ត្រួតពិនិត្យនាវានេសាទ

- អនុវត្តប្រព័ន្ធតាមដាននាវានេសាទក្នុងករណីដែលអាចធ្វើបាន
- លើកកម្ពស់វិធីសាស្ត្រគ្រប់គ្រងតាមបែបសហគមន៍នេសាទ។

២-រៀបចំបទប្បញ្ញត្តិនានាសម្រាប់ការផ្ទេរផលនេសាទក្នុងសមុទ្រនិងការឡើងផលនេសាទនៅតាមព្រំដែន។

៣-បង្ការការលួចចូលនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋនានានៃបណ្តារដ្ឋដែលជាសមាជិកអាស៊ាន។

៤-ត្រួតពិនិត្យការធ្វើនេសាទនិងការធ្វើពាណិជ្ជកម្មខុសច្បាប់ចំពោះប្រភេទត្រីដែលរស់នៅក្នុងតំបន់ផ្កាថ្ម ត្រីលម្អ និងប្រភេទវារីសត្វនានាដែលជិតផុតពូជ។

## ១.៤- ផលផលសមុទ្រ

អស់រយៈពេលជាច្រើនឆ្នាំមកនេះ វិស័យជលផលកម្ពុជា បានរួមចំណែកយ៉ាងសំខាន់ដល់ការងារនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ក៏ដូចជាសន្តិសុខស្បៀង ផលិតផលក្នុងស្រុកសរុប និងតុល្យភាពសម្រាប់ការដោះដូររូបិយប័ណ្ណបរទេស។ ជលផលកម្ពុជាផ្តល់ការងារពេញម៉ោង ក្រៅម៉ោង និងការងារតាមរដូវកាលដល់ប្រជាពលរដ្ឋប្រមាណ៦លាននាក់។ ត្រីផ្តល់ប្រូតេអ៊ីនមានប្រមាណ៨០ភាគរយនៃប្រូតេអ៊ីនសាច់សត្វនៅក្នុងរបបអាហារប្រចាំថ្ងៃនិងជាប្រភពវីតាមីននិងសារធាតុចិញ្ចឹមដ៏ចាំបាច់ទៀតផង។ ផល ផលិតផលជលផលសមុទ្រមានតម្លៃប្រមាណពី២០០ ទៅ៣០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ដោយគិតនៅកន្លែងផែឡើងផលនេសាទ។ ការប្រមូលផលនេសាទសរុប ការកែច្នៃ និងការធ្វើពាណិជ្ជកម្ម បានរួមចំណែកពី៦-៨ភាគរយនៃផលិតផលក្នុងស្រុកសរុប។ តម្លៃនៃការនាំចេញផលនេសាទ មានប្រមាណច្រើនជាង១០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ លើសពីនេះ ការនាំចេញជាផ្លូវការនូវបរិមាណផលផលសមុទ្រយ៉ាងច្រើនជាពិសេសត្រី បង្គា និងមឹកដែលមានតម្លៃខ្ពស់ត្រូវបាននាំចេញតាមច្រកព្រំដែនទៅកាន់ប្រទេសថៃ និងប្រទេសវៀតណាមដោយគ្មានរបាយការណ៍[៣]។

ផលផលសមុទ្រកម្ពុជាមានការអភិវឌ្ឍយឺតយ៉ាវបន្តិច បើប្រៀបធៀបទៅនឹងផលផលទឹកសាបកម្ពុជានិងផលផលសមុទ្រនៃប្រទេសថៃដែលជាប្រទេសជិតខាង។ ទោះជាយ៉ាងនេះក្តី ផលនេសាទ មានការកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេលជាង១៥ឆ្នាំចុងក្រោយនេះ។ ស្ថិតិរបស់រដ្ឋបាលជលផល បានបង្ហាញថាផលនេសាទសមុទ្របានកើនឡើងបី (៣) ដង ចាប់ពី៣៦ ០០០តោនក្នុងឆ្នាំ២០០០ កើនដល់១២១ ២៥០តោននៅឆ្នាំ២០១៧[៤]។ ផលផលិត ផលផលផលឡើងផែហាក់ដូចជាមានប្រមាណតែ១២០ ០០០តោនប៉ុណ្ណោះ។ វិស័យជលផលសមុទ្របានចូលរួមចំណែកប្រមាណ២០ភាគរយនៃផលនេសាទសរុប។ របាយការណ៍នាពេលថ្មីៗ បានបង្ហាញថាផលនេសាទខ្នាតតូច ជាពិសេសការនេសាទត្រីជាលក្ខណៈគ្រួសារមិនមានរបាយការណ៍ហើយផលនេសាទសមុទ្រសរុបអាចមានបរិមាណលើសពី ២០០ ០០០ តោន[៥]។

គួរកត់សម្គាល់ថា ការកើនឡើងនូវផលនេសាទជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០០០ បានបង្ហាញថាក្នុងចំណោមសមត្ថភាពនេសាទ ដែលបានកើនឡើងក្នុងរយៈពេលដូចគ្នាក៏មានការកើនឡើងដូចគ្នាផងដែរនូវចំនួន និងទំហំនាវានេសាទ និងពេលវេលាដែលអ្នកនេសាទចំណាយដើម្បីធ្វើនេសាទ។ តាមការវាយតម្លៃការនេសាទសមុទ្រកម្ពុជានាពេលថ្មីៗនេះ បានបង្ហាញឱ្យឃើញនូវការនេសាទហួសកម្រិតដោយនាវានេសាទកម្ពុជា និងបរទេស។

យោងតាមលទ្ធផលនៃការធ្វើជំរឿននាវានេសាទសមុទ្រឆ្នាំ២០១៨ដោយរដ្ឋបាលជលផល[៧] នាវានេសាទសមុទ្រសរុបមានចំនួន៧ ៥៥២គ្រឿង។ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង នាវានេសាទសមុទ្រត្រូវបានបែងចែកជា៥ក្រុម ដូចមាននៅក្នុងតារាងខាងក្រោម៖

តារាងទី១.ការចាត់ថ្នាក់នាវានេសាទសមុទ្រជា៥ក្រុមតាមប្រវែងបណ្តោយសរុបនៅតាមបណ្តាខេត្តតំបន់ឆ្នេរ

| **ការចាត់ថ្នាក់តាមប្រវែងនាវា(ម៉ែត្រ)** | **កោះកុង** | **ព្រះសីហនុ** | **កំពត** | **កែប** | **សរុប** |
|---|---|---|---|---|---|
| ≥ ២៤ | ១០ | ០ | ០ | ០ | ១០ |
| ១៨ - < ២៤ | ៦៧ | ៤២ | ៦ | ០ | ១១៥ |
| ១២ - < ១៨ | ៧០៦ | ៨៨៨ | ៣១១ | ៣០៤ | ២ ២០៩ |
| ៦ - < ១២ | ១ ៧២៧ | ១ ៥៥៩ | ៧១៨ | ២៩០ | ៤ ២៩៤ |
| < ៦ | ៨៨៦ | ៣៤ | ៤ | ០ | ៩២៤ |
| **សរុប** | **៣ ៣៩៦** | **២ ៥២៣** | **១ ០៣៩** | **៥៩៤** | **៧ ៥៥២** |

សម្គាល់: អ្នកនេសាទភាគច្រើនគឺនាវានេសាទអួនអូស។

ចំនួននាវានេសាទពីប្រទេសជិតខាងដែលកំពុងនេសាទនៅក្នុងដែននេសាទសមុទ្រកម្ពុជា ត្រូវបានរាយការណ៍ថាមានចំនួនច្រើន។ នៅក្នុងដែនសមុទ្រដែលមានវិវាទនិងដែនទឹកប្រវត្តិសាស្ត្រ នាវានេសាទប្រទេសជិតខាងកម្ពុជាបានប្រកាសថាពួកគេធ្វើនេសាទនៅក្នុងដែនទឹករបស់ខ្លួន ប៉ុន្តែព័ត៌មានជាច្រើនបានឱ្យដឹងថា នាវាទាំងនោះបានលួចចូលនេសាទក្នុងដែនសមុទ្រកម្ពុជាដែលមិនមែនជាដែននេសាទមានវិវាទ។ នាវានេសាទបរទេសទាំងនោះ ប្រើឧបករណ៍នេសាទដូចជា អួនអូស អួនហ៊ុម និងលបមឹកជាដើម ប៉ុន្តែមានរបៀបនេសាទខ្លះដែលពួកគេប្រើគឺខុសច្បាប់របស់កម្ពុជា ដូចជាការនេសាទដោយអួនអូសគូ ការនេសាទប្រើភ្លើង និងប្រើអគ្គិសនីឆក់ភ្ជាប់ជាមួយអួនអូស។ល។ ផលប៉ះពាល់នៃការនេសាទទាំងនេះទៅលើធនធានជលផលកម្ពុជានិងជីវភាពរស់នៅរបស់សហគមន៍នេសាទតំបន់ឆ្នេរមិនត្រូវបានវាយតម្លៃទេ។

អ្នកនេសាទសមុទ្រអាចនេសាទបានពេញមួយឆ្នាំហើយអាចធ្វើការផ្លាស់ប្តូរវិធីសាស្ត្រនេសាទតាមរដូវកាល។ យោងតាមទិន្នន័យរបស់រដ្ឋបាលជលផលក្នុងឆ្នាំ២០១៥ បរិមាណត្រីជី(សម្រាប់ធ្វើចំណីសត្វ) មានចំនួន៣៨ភាគរយធៀបទៅនឹងផលនេសាទសរុប[៨]។ ក្រៅពីនោះ មានពពួកបង្គា ពពួកមឹក ត្រីកាកឹម និងពពួកក្តាមសេះ។ ផលនេសាទដូចជាពពួកងាវនិងសិប្បីសត្វផ្សេងទៀតក៏មានបរិមាណច្រើនដែរ។ ក្នុងចំណោមពួកត្រីដែលមានតម្លៃសេដ្ឋកិច្ចដូចជា ពពួកត្រីក្រហម ត្រីកាំគួច ត្រីគន្ធុយរឹង ត្រីបេកា បបែល ត្រីឆ្ពោង និងពពួកត្រីខ្យាច់ គឺជាប្រភេទត្រីដែលនេសាទបានញឹកញាប់បំផុត។ តាមការវាយតម្លៃបានបង្ហាញថា ប្រហែល២០ភាគរយនៃផលនេសាទ មានប្រភេទត្រីមួយចំនួនដូចជា ពពួកត្រីស្រោមដាវ ត្រីអង្រែ ត្រីអាំងកឹយ ត្រីក្បក ឆ្លាម ត្រីស្រកាទន់ក្រហម ពពួកត្រីខ្ទឹង ត្រីចាបត្រីចោរ ត្រីគន្ធុយរឹង ត្រីកាំគួច និងពពួកត្រីប្រម៉ាជាដើម។ ដោយឡែក ក្តាមថ្ម បង្កងកណ្តូប ពពួកងាវដូចជា គ្រំឆ្លិតនិងសិប្បីសត្វផ្សេងទៀតក៏រាប់បញ្ចូលក្នុងផលនេសាទផងដែរ។

រីឯការផ្ទេរផលនេសាទពីនាវាមួយទៅនាវាមួយទៀត ត្រូវបានធ្វើនៅតាមកន្លែងឡើងផលនេសាទមួយចំនួនជាពិសេស តំបន់នៅជាប់ព្រំដែន ដោយនាំចេញផលនេសាទទាំងនោះទៅកាន់ប្រទេសជិតខាង។ ការផ្ទេរផលនេសាទពីនាវានេសាទកម្ពុជាទៅនាវានេសាទបរទេស និងការដឹកជញ្ជូនផលនេសាទដោយនាវានេសាទខុសច្បាប់ដែលធ្វើនេសាទនៅដែនសមុទ្រកម្ពុជាទៅក្រៅប្រទេសត្រូវបានរាយការណ៍។ ក្រៅពីនេះមានការលើកឡើងដោយ

នាយកដ្ឋានជលផលនៃប្រទេសថៃបានឱ្យដឹងថា មាននាវានេសាទសម្រាប់ផ្ទេរផលនេសាទរបស់ថៃមួយចំនួនមានចំណុះលើសពី៦០តោនធ្វើប្រតិបត្តិការក្រៅដែនទឹករបស់ប្រទេសថៃ[៥] ប៉ុន្តែចំនួនទូកនេសាទដែលធ្វើប្រតិបត្តិការនៅសមុទ្រកម្ពុជាមិនត្រូវបានដឹង។ ត្រីដែលបានចាប់ដោយនាវាទាំងនោះ ភាគច្រើនត្រូវដឹកតាមផ្លូវគោគឆ្ពោះទៅកាន់ទីផ្សារកម្ពុជា ទៅកាន់ប្រទេសថៃ និងវៀតណាម។

### ១.៥- បញ្ហានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ជលផលសមុទ្រកម្ពុជាមានលក្ខណៈបើកចំហ និងគ្មានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពដើម្បីដាក់កម្រិតលើសមត្ថភាពធ្វើនេសាទឱ្យស្ថិតក្នុងកម្រិតនិរន្តរភាពទេ។ ទោះបីជាមានច្បាប់និងបទប្បញ្ញត្តិមួយចំនួនដើម្បីត្រួតពិនិត្យសកម្មភាពខុសច្បាប់ទាំងនេះក៏ដោយ ក៏នៅមិនទាន់មានការគោរពឬអនុវត្តតាមប្រកបដោយប្រសិទ្ធភាពដែរ។

ព្រំដែនសមុទ្ររវាងកម្ពុជានិងថៃនៅភាគខាងជើង និងប្រទេសវៀតណាមនៅភាគខាងត្បូង គឺពុំទាន់មានការឯកភាពគ្នានៅឡើយ។ ដែននេសាទសមុទ្រជាប់ព្រំប្រទល់ជាមួយថៃនិងវៀតណាមមិនទាន់កំណត់ច្បាស់លាស់ទេ ដែលជាកត្តានាំឱ្យមានការពិបាកក្នុងការគ្រប់គ្រងជលផល។ តំបន់នេះកំពុងបង្កឱ្យមានការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅកម្ពុជា។

ព័ត៌មានលម្អិតស្តីពីការរៀបចំការគ្រប់គ្រងជលផលសមុទ្រត្រូវបានរៀបរាប់ក្នុងផ្នែកទី១.៦ ខាងក្រោមនេះ។

អត្ថន័យសង្ខេបនៃបញ្ហាសំខាន់ៗស្តីពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតត្រូវបានបញ្ជាក់នៅក្នុងប្រអប់ទី "២ក" និង "២ខ" ខាងក្រោម៖

**ប្រអប់ទី២ "ក": បញ្ហាសំខាន់ៗនៃការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងដែននេសាទសមុទ្រកម្ពុជា**

- **ទូកនេសាទកម្ពុជា**
  - ទូកនេសាទបានកើនឡើង
  - ទូកនេសាទស្ទើរតែទាំងអស់មិនទាន់បានចុះបញ្ជី និងគ្មានលិខិតអនុញ្ញាត
  - ទូកនេសាទអួនអូសលួចនេសាទនៅក្នុងតំបន់ចាប់ពីឆ្នេរដល់ខ្សែបន្ទាត់ជម្រៅទឹក២០ម៉ែត្រ
  - ទូកនេសាទអួនអូស បានបំផ្លិចបំផ្លាញទីជម្រកវារីសត្វ(ស្មៅសមុទ្រនិងផ្កាថ្ម)
  - ឧបករណ៍នេសាទមួយចំនួន មានក្រឡាតូចជាងកម្រិតអប្បបរមា សម្រាប់អួន មង និងមងក្ដាម ដែលកំណត់ក្នុងច្បាប់ស្តីពីជលផល
  - ការប្រើឧបករណ៍ហាមឃាត់ (គ្រឿងផ្ទុះ ថ្នាំពុល ឈិបយន្ត អួនអូសអគ្គិសនី និងលបកន្ទុយកណ្ដុរ)
  - ទូកនេសាទអួនអូសធំៗនៅក្នុងតំបន់ស្មៅសមុទ្រ មានស្លាបចក្រធំៗនិងអួនអូសវែងនិងក្រឡាតូចៗ។
- **នាវានេសាទបរទេស**
  - នាវាបរទេស នេសាទដោយគ្មានកិច្ចព្រមព្រៀងជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - នាវាបរទេស នេសាទដោយគ្មានអាជ្ញាបណ្ណពីរដ្ឋម្ចាស់ទង់ជាតិរបស់ពួកគេ
  - នាវានេសាទថៃដែលអាចជានាវាខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឡើងផលនេសាទក្នុងដែកម្ពុជា

- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ (អួនអូសគូ អួនអូសអគ្គិសនី និងនេសាទដោយប្រើភ្លើង)។

○ **ប្រជានេសាទកម្ពុជា**

- ផ្ទេរផលនេសាទនិងដឹកជញ្ជូនផលនេសាទដែលអាចបានមកពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ទៅប្រទេសថៃនិងប្រទេសវៀតណាម
- នាំចេញផលនេសាទ ដែលអាចបានមកពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ទៅប្រទេសថៃ និងប្រទេសវៀតណាម
- បំផ្លិចបំផ្លាញជម្រករបស់វារីជាតិ (ឧទាហរណ៍ ព្រៃកោងកាង ផ្កាថ្ម ស្មៅសមុទ្រ)។

**ប្រអប់ទី២ "ខ" : បញ្ហាសំខាន់ៗនៃការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត នៅក្នុងដែននេសាទ សមុទ្ររបស់រដ្ឋដទៃ និងក្នុងសមុទ្រអន្តរជាតិ**

**ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត**

នាវាដាក់ទង់ជាតិកម្ពុជា "ទង់ជាតិដែលងាយរកបាន" ត្រូវបានដាក់នៅក្នុងបញ្ជីនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត របស់អង្គការគ្រប់គ្រងផលផលថ្នាក់តំបន់(កាតក្រហម)។

**មូលហេតុនៃបញ្ហានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងដែនសមុទ្ររួមមាន:**

- មូលហេតុនៃបញ្ហាសំខាន់ៗមាន: (១) បទប្បញ្ញត្តិនានាហួសសម័យ (២) ភាពទន់ខ្សោយក្នុងការសម្របសម្រួលទំនាក់ទំនងនិងការយល់ដឹង (៣) វិវាទការនេសាទនៅតាមតំបន់ព្រំដែន
- ការនេសាទហួសពីសមត្ថភាពនាវាមានចំនួនច្រើនពេក និងការនេសាទលើសកម្រិត
  - ការនេសាទបើកចំហ
  - ការចុះបញ្ជីនិងការផ្តល់លិខិតអនុញ្ញាតគ្មានប្រសិទ្ធភាព
  - មិនដឹងចំនួននាវានេសាទថៃ និងវៀតណាម នៅក្នុងដែននេសាទសមុទ្ររបស់កម្ពុជា
  - ភាពទន់ខ្សោយនៃវិធានការតាមដាន ត្រួតពិនិត្យ និងអង្កេត និងការអនុវត្ត
  - ថវិកានិងធនធានមនុស្សមិនគ្រប់គ្រាន់សម្រាប់ការការត្រួតពិនិត្យនិងធ្វើអធិការកិច្ចមិនមានប្រសិទ្ធភាព
  - នាវាល្បាតមិនសូវមានប្រសិទ្ធភាព
  - អំពើពុករលួយ
  - កង្វះខាតនៃប្រព័ន្ធតាមដាននាវានេសាទ VMS និង GPS
  - គ្មានប្រសិទ្ធភាពក្នុងការដាក់ទណ្ឌកម្មឬការដាក់ពិន័យ។




**មូលហេតុនៃបញ្ហាខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងដែនសមុទ្ររបស់រដ្ឋជទៃនិងនៅក្នុងសមុទ្រអន្តរជាតិ**

កន្លងមក មានបញ្ហាការធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតជាច្រើនដែលបង្កឡើងដោយនាវានេសាទប្រើទង់ជាតិកម្ពុជានៅក្នុងសមុទ្រអន្តរជាតិ ប៉ុន្តែបច្ចុប្បន្នបញ្ហាទាំងនេះត្រូវបានបញ្ចប់។ ក្នុងឆ្នាំ១៩៩៤ កម្ពុជាបានរៀបចំការចុះបញ្ជីនាវារបស់ខ្លួនដែលមានឈ្មោះថា "សាជីវកម្មដឹកជញ្ជូនកម្ពុជា" មានមូលដ្ឋាននៅប្រទេសសិង្ហបុរី ហើយបានចាប់ផ្តើមឱ្យប្រើទង់ជាតិរបស់ខ្លួនទៅប្រទេសដទៃទៀត។ នៅក្នុងខែកក្កដា ឆ្នាំ២០០២ កម្ពុជាបានទទួលរងនូវការរិះគន់លើឆាកអន្តរជាតិស្តីពី "កំណត់ត្រាសុវត្ថិភាពរបស់កម្ពុជាលើផ្ទៃសមុទ្រ" ហើយរដ្ឋាភិបាលកម្ពុជា បានដកហូតសិទ្ធិអំណាចរបស់សាជីវកម្មដឹកជញ្ជូនកម្ពុជាក្នុងការផ្តល់សិទ្ធិចុះបញ្ជី ទៅឱ្យក្រសួងសាធារណការ និងដឹកជញ្ជូនវិញ។ ក្រសួងសាធារណការនិងដឹកជញ្ជូន ទទួលបានសិទ្ធិគ្រប់គ្រងការចុះបញ្ជីឈ្មោះបានត្រឹមតែ៦ខែប៉ុណ្ណោះ។ នៅខែកុម្ភៈ ឆ្នាំ២០០៣ រដ្ឋាភិបាលកម្ពុជាបានផ្តល់សិទ្ធិក្នុងការចុះបញ្ជីនិងផ្តល់ទង់ជាតិនាវាទៅឱ្យក្រុមហ៊ុនថ្មីមួយទៀតឈ្មោះកូស្មូសហើយក្រុមហ៊ុននេះបានរៀបចំការចុះបញ្ជីនាវាអន្តរជាតិរបស់កម្ពុជា។ ការចុះបញ្ជីអាចធ្វើបានតាមរយៈប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិក។ បន្ទាប់ពីទទួលបានសេចក្តីរាយការណ៍អំពីនាវា

ដែលប្រើទង់ជាតិកម្ពុជាធ្វើសកម្មភាពនេសាទខុសច្បាប់នៅក្នុងដែនរបស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ សហភាពអឺរ៉ុបបានជូនដំណឹងដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃកម្ពុជាថា សហភាពអឺរ៉ុបបានចាត់ទុកកម្ពុជាជា "ប្រទេសទីបីដែលមិនសហការក្នុងការប្រយុទ្ធប្រឆាំងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត" នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២។ សហភាពអឺរ៉ុបបានអនុម័តការរឹតបន្តឹងការធ្វើពាណិជ្ជកម្មផលនេសាទមកលើកម្ពុជា នៅខែមីនា ឆ្នាំ២០១៤ (IP/១៤/៣០៤) (កាតក្រហម)។

នៅក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជា បានលុបចោលកិច្ចសន្យារបស់ខ្លួនជាមួយក្រុមហ៊ុន ភូស្នូស។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានជូនដំណឹងដល់អង្គការសមុទ្រអន្តរជាតិថា "ប្រសិនបើអង្គការសមុទ្រអន្តរជាតិរកឃើញនាវាបរទេសណាដែលប្រើទង់ជាតិកម្ពុជានោះគឺជានាវាខុសច្បាប់" ។ ក្នុងឆ្នាំ២០១៥ នាវាបរទេសប្រហែល ១៩៤គ្រឿងធ្វើប្រតិបត្តិការដោយប្រើទង់ជាតិកម្ពុជា ប៉ុន្តែគិតត្រឹមខែតុលាឆ្នាំ២០១៧ កម្ពុជាមិនបានផ្តល់អាជ្ញាបណ្ណដល់នាវានេសាទបរទេសដែលប្រើទង់ជាតិកម្ពុជាឡើយ។ បច្ចុប្បន្ន កម្ពុជាកំពុងពិចារណាលើការបង្កើតប្រព័ន្ធចុះបញ្ជីនាវារបស់ខ្លួនសម្រាប់នាវាដែលមិនមែននេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតទៅនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋផ្សេងទៀតនៅសមុទ្រអន្តរជាតិ។

## ១.៦- ការរៀបចំគ្រប់គ្រងជលផល

**ស្ថាប័នចម្បងៗទទួលខុសត្រូវសម្រាប់ការងារគ្រប់គ្រង ការគោរព និងអនុវត្តច្បាប់**

**ការចុះបញ្ជីនាវានេសាទ:** ការចុះបញ្ជីនាវានៅតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃកម្ពុជា ត្រូវធ្វើឡើងដោយក្រសួងសាធារណការនិងដឹកជញ្ជូន ដែលក្នុងនោះនាយកដ្ឋាននាវាជំនួញសមុទ្រនិងមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តជាអ្នកទទួលខុសត្រូវក្នុងការចុះបញ្ជីនាវានេសាទ។ នាវានេសាទថ្មីតម្រូវឱ្យចុះបញ្ជី ហើយម្ចាស់នាវានឹងទទួលបានបណ្ណសម្គាល់នាវា។ លេខផ្លូវការឬលេខចុះបញ្ជីមានចុះនៅក្នុងបណ្ណសម្គាល់នាវានេសាទនិងមានអក្សរសម្គាល់ចំនួន២តួ និងលេខចំនួន៤ខ្ទង់ ដែលសម្គាល់តំបន់គ្រប់គ្រងតាមខេត្តតំបន់ឆ្នេរ។ ទោះជាយ៉ាងនេះក្តី ក្រសួងសាធារណការនិងដឹកជញ្ជូនពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចុះបញ្ជីនាវានេសាទតូចៗនៅកម្ពុជាឡើយ។ ជាលទ្ធផល មាននាវាតូចៗតិចតួចប៉ុណ្ណោះដែលត្រូវបានចុះបញ្ជីឬទទួលបានបណ្ណសម្គាល់។

**ការផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទ:** រដ្ឋបាលជលផល ទទួលខុសត្រូវចំពោះការចេញលិខិតអនុញ្ញាតឱ្យប្រើទូកនេសាទនិងឧបករណ៍នេសាទពាក់ព័ន្ធដែលដំណើរការនៃការត្រួតពិនិត្យ និងដោយមានការចុះហត្ថលេខាពីគ្រប់អង្គភាពត្រួតពិនិត្យទាំងអស់មានរយៈពេលយូរ (នីតិវិធីចុះបញ្ជីនិងការផ្តល់អាជ្ញាបណ្ណគឺមាននៅក្នុងឧបសម្ព័ន្ធ១)

**ការគ្រប់គ្រងធនធានជលផល ឧបករណ៍នេសាទ និងតំបន់នេសាទ:** តាមច្បាប់ស្តីពីជលផលឆ្នាំ២០០៦ រដ្ឋបាលជលផលស្ថិតក្រោមដែនសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគឺទទួលខុសត្រូវក្នុងការគ្រប់-គ្រងជលផលនិងធនធានជលផលដោយឈរលើមូលដ្ឋានគោលនយោបាយជលផលជាតិនិងច្បាប់ស្តីពីជលផល។ រដ្ឋបាលជលផលមាននាយកដ្ឋានចំនួន៧ វិទ្យាស្ថានស្រាវជ្រាវចំនួន៣ អធិការដ្ឋានរដ្ឋបាលជលផលចំនួន៥ ខណ្ឌរដ្ឋបាលជលផលចំនួន២៥ ផ្នែករដ្ឋបាលជលផលចំនួន៤៨ និងសង្កាត់រដ្ឋបាលជលផលចំនួន១៥៨ នៅតាមខេត្តនានា។ ចំពោះតំបន់ឆ្នេរ មានអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រចំនួន១ ក្នុងនោះមានខណ្ឌរដ្ឋបាលជលផល

ចំនួន៤ ផ្នែករដ្ឋបាលជលផលចំនួន៨ និងសង្កាត់រដ្ឋបាលជលផលចំនួន២២។ សហគ្រប់គ្រងត្រូវបានអនុវត្តតាមរយៈសហគមន៍នេសាទ ដោយសហគមន៍មូលដ្ឋានចូលរួមគ្រប់គ្រងនិងអភិវឌ្ឍជលផលជាលក្ខណៈគ្រួសារ។

ការតាមដាន ត្រួតពិនិត្យ និងអង្កេត ត្រូវបានអនុវត្តដោយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ ខណ្ឌរដ្ឋបាលជលផល ផ្នែករដ្ឋបាលជលផល និងសង្កាត់រដ្ឋបាលជលផល ប៉ុន្តែមធ្យោបាយត្រួតពិនិត្យមានចំនួនតិចនិងមានសភាពចាស់ទ្រុឌទ្រោម។ សហគមន៍នេសាទ ក៏មានទូកល្បាតតូចៗដែលអាចប្រើសម្រាប់ឃាត់និងចាប់ជនល្មើសបាន ប៉ុន្តែត្រូវបញ្ជូនជនល្មើសទៅមន្ត្រីនគរបាលយុត្តិធម៌របស់រដ្ឋបាលជលផល ដើម្បីអនុវត្តតាមនីតិវិធី។ ចំពោះអង្គភាពពាក់ព័ន្ធរួមមាន នគរបាលព្រំដែនទឹកនិងកងទ័ពជើងទឹក ដែលធ្វើការងារភាគច្រើនទាក់ទងទៅនឹងការទប់ស្កាត់ការរត់ពន្ធ ការជួញដូរខុសច្បាប់ និងឧក្រិដ្ឋកម្មផ្សេងទៀតក្នុងនោះរួមទាំងបទល្មើសជលផលផងដែរ។ ដោយឡែក ចំពោះបទល្មើសជលផលត្រូវបញ្ជូនជនល្មើសនិងវត្ថុតាងមកមន្ត្រីជលផលមានសមត្ថកិច្ចដើម្បីអនុវត្តតាមនីតិវិធី។ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទអាចធ្វើអន្តរាគមន៍ទាំងលើគោកនិងដែនសមុទ្រ។

**ការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនៅក្នុងប្រទេស**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិករបស់គណៈរដ្ឋមន្ត្រី ដែលមាននាយករដ្ឋមន្ត្រីជាប្រមុខ។ ការសម្របសម្រួលនៅថ្នាក់ផ្សេងទៀតនៃជួររាជរដ្ឋាភិបាល ជាទូទៅមានទម្រង់ជាគណៈកម្មការចំពោះកិច្ចតាមរយៈក្រុមការងារថ្នាក់ជាតិដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលមានសមាសភាពមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានកសិកម្មនៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការនិងដឹកជញ្ជូននិងរដ្ឋបាលជលផល។ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ជលផលបានបង្កើតជាវេទិកាប្រជុំសម្រាប់សម្របសម្រួលការងារ រវាងស្ថាប័នរាជរដ្ឋាភិបាលនានា ជាមួយនឹងដៃគូអភិវឌ្ឍន៍និងក្រុមអង្គការមិនមែនរដ្ឋាភិបាល។ ប៉ុន្តែក្រុមការងារនេះ នឹងត្រូវធ្វើការកែសម្រួលដោយមូលហេតុមិនទាន់មានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធនៅឡើយ។

មកទល់នឹងពេលបច្ចុប្បន្ន កម្ពុជានៅមិនទាន់មានការរៀបចំជាផ្លូវការណាមួយក្នុងការសម្របសម្រួលចែករំលែកព័ត៌មានលើការចុះបញ្ជីនាវានេសាទដែលអនុវត្តដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងការចេញលិខិតអនុញ្ញាតឱ្យធ្វើនេសាទដែលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ការសម្របសម្រួលជាមួយស្ថាប័នអន្តរជាតិនិងអង្គការនានា**

ប្រទេសកម្ពុជាបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយស្ថាប័នថ្នាក់ពិភពលោកនិងអង្គការថ្នាក់តំបន់ជាច្រើនៈ

- កម្ពុជាគឺជាសមាជិករបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ាន។ល។
- កម្ពុជាមិនមែនជាសមាជិកនិងមិនមានកិច្ចសហការជាមួយនឹងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ណាមួយឡើយ។

រដ្ឋបាលជលផលដែលជាសេនាធិការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ជូនតំណាងឱ្យទៅចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំនៅអន្តរជាតិ ថ្នាក់តំបន់នានា រួមមានអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ាន ដើម្បីចូលរួមពិចារណាអំពីការគ្រប់គ្រងធនធានជលផលនិងកំណត់វិធានការដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

**១.៧- គ្របខ័ណ្ឌនិងវិសាលភាពនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទ ខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត**

ទម្រង់ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត របស់កម្ពុជា គឺផ្អែកទៅលើផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលផ្តល់នូវគោលការណ៍ណែនាំលើចំណុចសំខាន់ៗចំនួន៥រួមមានៈ (១)ការទទួលខុសត្រូវរបស់រដ្ឋទាំងអស់ (២)ការទទួលខុសត្រូវរបស់កម្ពុជាចំពោះឆ្នេរសមុទ្ររបស់ខ្លួន (៣) ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិ (៤) វិធានការណ៍របស់ប្រទេសកម្ពុជាក្នុងនាមជារដ្ឋម្ចាស់កំពង់ផែ និង (៥) វិធានការនានាពាក់ព័ន្ធនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ។ ទម្រង់នេះក៏បានបញ្ចូលផងដែរនូវចំណុចខ្លះៗរបស់ផែនការសកម្មភាពថ្នាក់តំបន់ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងគោលការណ៍ណែនាំរបស់សមាគមអាស៊ានស្តីពីការទប់ស្កាត់ការនាំចូលផល ផលិតផលជលផល ចេញពីសកម្មភាព នេសាទដែលបានមកពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ចូលទៅក្នុងខ្សែច្រវាក់នៃការផ្គត់ផ្គង់។ គោលការណ៍ណែនាំនៅក្នុងផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ត្រូវបានសង្ខេបដូចមាននៅក្នុងប្រអប់ខាងក្រោម។

ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត គ្របដណ្តប់នូវរាល់សកម្មភាពជលផលសមុទ្រនៅក្នុងដែនសមុទ្រកម្ពុជា ដែនសមុទ្ររដ្ឋដទៃ និងដែនសមុទ្រអន្តរជាតិ ដោយមានការគាំទ្រពីច្បាប់ជលផល គោលនយោបាយ បទប្បញ្ញត្តិ និងគ្របខ័ណ្ឌយុទ្ធសាស្ត្រនានាដូចដែលបានព្រមព្រៀងគ្នានៅក្នុងច្បាប់ជាតិនិងលិខិតុបករណ៍អន្តរជាតិឬក៏នៅក្នុងអនុសញ្ញាអន្តរជាតិនានា។

ប្រទេសកម្ពុជាបានរៀបចំចងក្រងផែនការសកម្មភាពសម្រាប់អនុវត្តផែនការសកម្មភាពជាតិស្តីពី ការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត យ៉ាងពិស្តារ ដែលបានបញ្ជាក់អំពីៈ (១) សូចនាករលទ្ធផលការងារសំខាន់ៗ (២) នីតិវិធីសម្រាប់ការអនុវត្ត (៣) ស្ថាប័នទទួលខុសត្រូវ និង (៤) ពេលវេលាកំណត់សម្រាប់សកម្មភាពនីមួយៗ។

## ២- គោលបំណងនិងយុទ្ធសាស្ត្រ

### ២.១- គោលបំណង

ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និង គ្មានការអនុញ្ញាតនេះ មានគោលបំណងរួមដូចខាងក្រោមៈ

១-ដើម្បីកំណត់សកម្មភាពសំខាន់ៗដែលកម្ពុជាត្រូវអនុវត្តក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

២-ដើម្បីភ្ជាប់សកម្មភាព និងវិធានការណ៍នានា ក្នុងការដោះស្រាយនូវរាល់បញ្ហាប្រឈមពាក់ព័ន្ធនឹងការបំផ្លិចបំផ្លាញធនធានជលផល ដែលបង្កឡើងដោយការនេសាទហួសសមត្ថភាពនិងហួសគម្រិត។

ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនេះ មានគោលដៅសំខាន់ៗ៣គឺ (១) គ្រប់គ្រងសមត្ថភាពនិងប្រសិទ្ធភាពនេសាទ រួមទាំងការត្រួតពិនិត្យលើការចេញលិខិតអនុញ្ញាតនិងការចុះបញ្ជីនាវានេសាទ (២) គាំទ្រការងារដោយអនុលោមទៅតាមច្បាប់ គោលនយោបាយ បទប្បញ្ញត្តិ ដែលបានព្រមព្រៀងគ្នាដូចមានចែងក្នុងច្បាប់ជាតិរបស់កម្ពុជា ច្បាប់អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិសំខាន់ៗ និងរួមទាំងអនុសញ្ញាអន្តរជាតិ តាមរយៈការពង្រឹងការតាមដានត្រួតពិនិត្យ និងអង្កេត និង (៣) ពង្រឹងកិច្ចសហការជាមួយប្រទេសជិតខាងក្នុងតំបន់អាស៊ាន។

## ២.២- យុទ្ធសាស្ត្រ

ដើម្បីសម្រេច គោលបំណងខាងលើ យុទ្ធសាស្ត្រសំខាន់ៗមានដូចខាងក្រោមៈ

### ២.២.១- លើកកម្ពស់ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋនៅលើសកលលោក

- រៀបចំអនុម័តលិខិតបទដ្ឋានគតិយុត្តអន្តរជាតិសំខាន់ៗនិងរៀបចំគោលនយោបាយជាតិដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្មភាពជាតិឱ្យមានប្រសិទ្ធភាព
- លើកកម្ពស់ការផ្សព្វផ្សាយនិងពន្លឿនការអនុវត្តផែនការសកម្មភាពជាតិអាទិភាព
- ធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល ដើម្បីជំរុញការអភិវឌ្ឍជលផលប្រកបដោយនិរន្តរភាព
- បង្កើតនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានា ពិសេសប្រទេសជិតខាង ក្នុងការចែករំលែកព័ត៌មាននិងការស៊ើបអង្កេត ដើម្បីទប់ស្កាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងតំបន់។

### ២.២.២- លើកកម្ពស់ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ឆ្នេរ

- ពង្រឹងការគ្រប់គ្រងធនធានជលផល តាមរយៈការកសាងផែនការគ្រប់គ្រងជលផលឱ្យបានទូលំទូលាយក្នុងការគាំទ្រការអនុវត្តច្បាប់ជលផលនិងក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់វិស័យជលផល និងកែលម្អប្រព័ន្ធប្រមូលទិន្នន័យនិងព័ត៌មានជលផល
- ពន្លឿនការចុះបញ្ជីនាវានេសាទនិងផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទខ្នាតមធ្យម និងខ្នាតធំ
- ពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលទៅលើការដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មទាំងក្នុងនិងក្រៅប្រទេស
- ពង្រឹងការតាមដាន ត្រួតពិនិត្យ និងអង្កេតឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពចំពោះការនេសាទចាប់ពីចំណុចចាប់ផ្តើមរហូតដល់គោលដៅចុងក្រោយ តាមរយៈការកសាងនិងអនុវត្តផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ រួមទាំងលើផ្ទៃសមុទ្រនិងនៅកន្លែងឡើងផលនេសាទ។

### ២.២.៣- លើកកម្ពស់ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិ

- ពិចារណានិងបង្កើតប្រព័ន្ធចុះបញ្ជីសាជាថ្មី សម្រាប់នាវានេសាទស្របច្បាប់ទៅធ្វើប្រតិបត្តិការនៅតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃនិងសមុទ្រអន្តរជាតិ
- ពង្រឹងការទទួលខុសត្រូវក្នុងការប្រើប្រាស់ទង់ជាតិកម្ពុជានៅលើនាវានេសាទដែលធ្វើប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃនិងសមុទ្រអន្តរជាតិ។

**២.២.៤- អនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ**

- អនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ ដោយកំណត់កំពង់ផែឬកន្លែងឡើងផលនេសាទសម្រាប់នាវានេសាទបរទេស បង្ហាញនិងផ្សព្វផ្សាយពីទីតាំងទាំងនោះដល់ស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ
- ពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ កិច្ចពិភាក្សាទ្វេភាគីឬពហុភាគី ដើម្បីពង្រឹងការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ។

**២.២.៥- អនុវត្តវិធានការពាក់ព័ន្ធនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ**

- អនុម័តនិងសាកល្បងប្រើប្រាស់ប្រព័ន្ធឯកសារគ្រប់គ្រងប្រព័ន្ធនាំចេញ-នាំចូល
- កសាងសមត្ថភាពមន្ត្រី ក្នុងការកត់ត្រាស្ថិតិផលនេសាទនិងផ្ទៀងផ្ទាត់លិខិតអនុញ្ញាត ជាមួយរដ្ឋដទៃ។

**២.២.៦- បង្កើននិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ**

- បន្តផ្តល់ព័ត៌មានដល់អង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ អំពីនាវាប្រើប្រាស់ទង់ជាតិកម្ពុជានៅសមុទ្រអន្តរជាតិនិងក្នុងតំបន់គ្រប់គ្រងដោយអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ ដើម្បីទប់ស្កាត់និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

## ៣- ផែនការសកម្មភាពនិងកាលវិភាគអនុវត្តសកម្មភាព ក្នុងវិស័យច្បាប់និងវិស័យពាក់ព័ន្ធ

### ៣.១- វិសាលភាព

វិសាលភាពនៃផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឆ្នាំ២០២០-២០២៤ ត្រូវបានគ្របដណ្តប់លើវិស័យជលផលសមុទ្រ ដោយបានណែនាំនូវវិធានការជាច្រើនដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទសមុទ្រខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ ផែនការសកម្មភាពនេះបានចាត់ថ្នាក់ដូចខាងក្រោមៈ

- ការទទួលខុសត្រូវរបស់រដ្ឋទាំងអស់
- ការទទួលខុសត្រូវរបស់រដ្ឋតំបន់ឆ្នេរសមុទ្រ
- ការទទួលខុសត្រូវរបស់រដ្ឋម្ចាស់ទង់ជាតិ
- វិធានការរដ្ឋម្ចាស់កំពង់ផែ
- វិធានការពាក់ព័ន្ធនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ
- កិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់និងប្រទេសដទៃទៀត ដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត
- លក្ខខណ្ឌតម្រូវពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ

- ការរាយការណ៍។

ចំពោះសកម្មភាពជាអាទិភាពនៃផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត រួមមាន (១) ការចុះហត្ថលេខាលើលិខិតុបករណ៍អន្តរជាតិ (២) ការពិនិត្យ និងកែសម្រួលច្បាប់ស្តីពីជលផល (៣) ការគ្រប់គ្រងសមត្ថភាពនេសាទតាមរយៈការចុះបញ្ជីនិងការផ្តល់លិខិតអនុញ្ញាតប្រកបដោយប្រសិទ្ធភាព (៤) ការពង្រឹងការតាមដាន ត្រួតពិនិត្យ និងអង្កេត ជាពិសេសការត្រួតពិនិត្យផែឡើងផលនេសាទ (៥) ការពង្រឹងការវាយតម្លៃសមត្ថភាពនេសាទនិងធនធានជលផលសម្រាប់តម្រូវការនៃការធ្វើរបាយការណ៍ និង (៦) ការហាមឃាត់នាវានេសាទបរទេស ដូចជានាវាប្រទេសជិតខាងនេសាទនៅក្នុងដែនសមុទ្រកម្ពុជាដែលមិនមានវិកទ។ ចំពោះការធ្វើនេសាទនៅក្នុងដែនសមុទ្ររដ្ឋជទៃនិងសមុទ្រអន្តរជាតិ សកម្មភាពចម្បងគឺត្រូវពង្រឹងប្រព័ន្ធចុះបញ្ជីនិងការចេញលិខិតអនុញ្ញាត សម្រាប់នាវាដែលប្រើទង់ជាតិកម្ពុជាដោយរួមបញ្ចូលទាំងវិធានការត្រួតពិនិត្យ និងអធិការកិច្ចប្រកបដោយប្រសិទ្ធភាព។

ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតតាក់តែងឡើងដោយមានឯកសារអមចំនួនពីរគឺ ទី១ សេចក្តីថ្លែងការណ៍គោលនយោបាយក្នុងការគ្រប់គ្រងការនេសាទសមុទ្រ និងទី២ ផែនការអនុវត្តរយៈពេលបីឆ្នាំ ដោយបានកំណត់ពេលវេលាសម្រាប់ការអនុវត្តសកម្មភាពអាទិភាព ចំណុចដៅ សូចនាករសំខាន់ៗ និងស្ថាប័នទទួលខុសត្រូវយ៉ាងច្បាស់លាស់។

## ៣.២- ផែនការសកម្មភាព

### ១- ការទទួលខុសត្រូវរបស់រដ្ឋ

### ១.១- លិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធសំខាន់ៗ

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋទាំងឡាយត្រូវផ្តល់នូវរាល់សុពលភាព និងកាតព្វកិច្ចនៃច្បាប់ និងវិធានអន្តរជាតិដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់រាល់សកម្មភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ រដ្ឋទាំងអស់ត្រូវបានលើកទឹកចិត្តក្នុងការលើកសំណើសុំធ្វើការកំណត់អាទិភាពនិងការផ្តល់សច្ចាប័ន ការទទួលយកឬក៏ចូលជាសមាជិកនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ឆ្នាំ១៩៨២ កិច្ចព្រមព្រៀងផលស្តុកត្រីឆ្នាំ១៩៩៥ កិច្ចព្រមព្រៀងអនុលោមតាមអង្គការស្បៀងនិងកសិកម្មនៃសហប្រជា-ជាតិឆ្នាំ១៩៩៣ និងអនុវត្តតាមក្រមប្រតិបត្តិរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ១៩៩៥ស្តីពីការនេសាទប្រកបដោយ ការទទួលខុសត្រូវ រួមបញ្ចូលទាំងផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ពាក់ព័ន្ធនានា និងយុទ្ធសាស្ត្រក្នុងការក្លាយខ្លួនជាសមាជិកឬការសហការក្នុងការបង្កើតអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ថ្មីដែលពាក់ព័ន្ធប្រសិនជាអាច។

កម្ពុជាបានផ្តល់សច្ចាប័នលើៈ ១. អនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៥៨ ស្តីពីដែនសមុទ្រអន្តរជាតិនិងចូលជាសមាជិកនៃអនុសញ្ញាសមុទ្រដែនដីនិងដែនសមុទ្រតំបន់តភ្ជាប់ឆ្នាំ១៩៦០ ២. អនុសញ្ញាស្តីពីជីវចម្រុះឆ្នាំ១៩៩៥និងចូលជាភាគីនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ឆ្នាំ១៩៩៧

៣. កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងចូលជាសមាជិកក្នុងឆ្នាំ២០១៩ និង៤.កិច្ចព្រមព្រៀងស្តីពីផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៃអង្គការសហប្រជាជាតិនិងចូលជាសមាជិកក្នុងឆ្នាំ២០២០។ ប៉ុន្តែកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអង្គការសហ-ប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២ ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប័នអនុសញ្ញាលើនោះនៅឡើយទេ។

ក្នុងនាមជាប្រទេសសមាជិកនៃអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ កម្ពុជាបានអនុម័តនូវក្រមប្រតិបត្តិប្រកបដោយការទទួលខុសត្រូវក្នុងវិស័យជលផលរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ព្រមទាំងបានរៀបចំសេចក្តីព្រាងក្រមប្រតិបត្តិប្រកបដោយការទទួលខុសត្រូវក្នុងវិស័យជលផលរបស់កម្ពុជាខ្លួនឯងផងដែរ។

កិច្ចសហប្រតិបត្តិការផ្សេងៗជាមួយអន្តរជាតិរួមមាន៖

- កម្ពុជាធ្វើសហប្រតិបត្តិការក្នុងនាមជាសមាជិកអាស៊ាននិងលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ ដើម្បីគាំទ្រនិងអនុវត្តសេចក្តីសម្រេចចិត្តនិងផែនការសកម្មភាពរបស់អាស៊ានលេខាធិការ-ដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ស្តីពីនិរន្តរភាពវិស័យជលផលសម្រាប់សន្តិសុខស្បៀងនៅតំបន់អាស៊ានឆ្ពោះទៅឆ្នាំ២០២០
- កម្ពុជាក្នុងនាមជាសមាជិករបស់លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ បានចូលរួមជាមួយការងារគ្រប់គ្រងថ្នាក់តំបន់ស្តីពីសមត្ថភាពនេសាទ ដែលប្រទេសនីមួយៗជាសមាជិកត្រូវអនុវត្តដើម្បីបង្កើត និងអនុវត្តផែនការសកម្មភាពជាតិស្តីពីការគ្រប់គ្រងសមត្ថភាពនេសាទ
- កម្ពុជាបាននិងកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នថ្នាក់តំបន់/អន្តរជាតិ ដូចជាគណៈកម្មការជលផលអាស៊ីប៉ាស៊ីហ្វិក និងបណ្តាញមជ្ឈមណ្ឌលវារីវប្បកម្មនៅអាស៊ីប៉ាស៊ីហ្វិក
- លើសពីនេះទៅទៀត ក្នុងនាមជាសមាជិកនៃក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការក្នុងកម្រិតអនុតំបន់ដូចជាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចូលរួមក្នុងសកម្មភាពនៅក្រោមក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការនេះ។

**សកម្មភាពនាពេលអនាគតរួមមាន៖**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | រៀបចំការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនិងអនុវត្តកិច្ចព្រមព្រៀង | | | | | |
| | ១.១- កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ | ✓ | ✓ | ✓ | ✓ | ✓ |
| | ១.២- កិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិស្តីពីផលស្តុកត្រី | ✓ | ✓ | ✓ | ✓ | ✓ |
| | ១.៣- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ | | | | | |

### ១.២- ក្របខ័ណ្ឌច្បាប់ជាតិ

១.២.១- បទប្បញ្ញត្តិ

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត បញ្ជាក់ថាបទប្បញ្ញត្តិជាតិគួរតែដោះស្រាយប្រកបដោយប្រសិទ្ធភាពនិងគ្រប់ទិដ្ឋភាពទាំងអស់នៃការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

ច្បាប់ស្តីពីជលផលឆ្នាំ២០០៦ ត្រូវបាននិងកំពុងកែសម្រួលនិងធ្វើវិសោធនកម្ម ដើម្បីជំរុញការអភិវឌ្ឍជលផលប្រកបដោយនិរន្តរភាព ស្របជាមួយនឹងគោលការណ៍ណែនាំនៅក្នុងបទដ្ឋានអន្តរជាតិព្រមទាំងក្របខ័ណ្ឌកិច្ចសហ-ប្រតិបត្តិការជាមួយបណ្តាប្រទេសផ្សេងៗទៀត ស្តីពីការគ្រប់គ្រងជលផលសមុទ្រ។

កម្ពុជានឹងបន្តកែសម្រួលបទប្បញ្ញត្តិជលផលផ្សេងៗទៀត យោងតាមច្បាប់ស្តីពីជលផលដែលត្រូវបានធ្វើវិសោធនកម្ម។ សកម្មភាពនាពេលអនាគតរួមមានៈ

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | ពិនិត្យកែសម្រួល សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីជលផល និងអនុក្រឹត្យស្តីពីជលផលសមុទ្រនិងការនេសាទនៅតំបន់សមុទ្រក្រៅ | ✓ | | | | |
| ២ | អនុម័តវិសោធនកម្មច្បាប់ស្តីពីជលផល និងអនុក្រឹត្យស្តីពីជលផលសមុទ្រនិងការនេសាទនៅតំបន់សមុទ្រក្រៅ | ✓ | ✓ | | | |

#### ១.២.២- ការត្រួតពិនិត្យរបស់រដ្ឋលើជាតិសាសន៍ (មនុស្សជាតិ) ផ្សេងៗ

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់ខ្ពស់បំផុតដើម្បីចាត់វិធានការឬធ្វើកិច្ចសហការដើម្បីធានាថាប្រជានេសាទរបស់ខ្លួនមិនគាំទ្រឬចូលរួមក្នុងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងដើម្បីធ្វើកិច្ចសហប្រតិបត្តិការក្នុងការកំណត់អត្តសញ្ញាណជនដែលជាអ្នកប្រព្រឹត្តឬម្ចាស់នាវានេសាទដែលធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

កម្ពុជាគាំទ្រការចាត់វិធានការប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតចំពោះប្រជានេសាទរបស់ខ្លួននៅក្រៅប្រទេស ប៉ុន្តែក៏នៅមានក្រុមអ្នកនេសាទកម្ពុជាដែលធ្វើការនៅលើនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ បញ្ហានេះត្រូវបាននិងកំពុងដោះស្រាយដោយការធ្វើកំណែទម្រង់ច្បាប់ផ្សេងៗ។ បច្ចុប្បន្នបញ្ហានេះគឺមិនមែនជាបញ្ហាចម្បងនៃការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនៅក្នុងកម្ពុជាឡើយ តែបញ្ហានេះនឹងត្រូវបានបញ្ជាក់នៅក្នុងច្បាប់ស្តីពីជលផលដែលត្រូវធ្វើវិសោធនកម្មនាពេលឆាប់ៗខាងមុខ។

#### ១.២.៣- ទោសប្បញ្ញត្តិនិងការដាក់ទណ្ឌកម្ម

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត បានដាក់ទណ្ឌកម្មដល់នាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងជាតិសាសន៍ទាំងឡាយដែលនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដោយតម្រូវឱ្យមានការប្តេជ្ញាចិត្តខ្ពស់ដើម្បីទប់ស្កាត់ឱ្យមានប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍និងគ្មានការអនុញ្ញាត ព្រមទាំងចាត់វិធានការតាមនីតិវិធីដល់ជនល្មើសដែលទទួលបានអត្ថប្រយោជន៍ពីការនេសាទខុសច្បាប់។

បច្ចុប្បន្ន កម្ពុជាកំពុងពិនិត្យច្បាប់ស្តីពីជលផលឡើងវិញ ព្រមទាំងដាក់បញ្ចូលទោសប្បញ្ញត្តិឬទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរថែមទៀតដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ។

សកម្មភាពនាពេលអនាគតរួមមានៈ

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | បន្តកែសម្រួលទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីជលផលឡើងវិញដោយដាក់ការផាកពិន័យឱ្យមានប្រសិទ្ធភាព | ✓ | ✓ | | | |

### ១.២.៤- ការលើកទឹកចិត្តជាលក្ខណៈសេដ្ឋកិច្ច

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត ចែងថារដ្ឋគួរតែជៀសវាងការគាំទ្រផ្នែកសេដ្ឋកិច្ច រួមទាំងជំនួយអនុគ្រោះទៅឱ្យក្រុមហ៊ុននាវាឬបុគ្គលដែលបានចូលរួមនៅក្នុងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

កម្ពុជាមិនបានផ្តល់ជំនួយអនុគ្រោះណាមួយ ដែលលើកទឹកចិត្តដល់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតឡើយ។ ប៉ុន្តែកម្ពុជាគាំទ្រដល់អ្នកនេសាទជាលក្ខណៈគ្រួសារ តាមរយៈសហគមន៍នេសាទ និងគាំទ្រដល់បណ្តាញអ្នកនេសាទស្ម័គ្រចិត្តសម្រាប់កម្មវិធីឃ្លាំមើលសកម្មភាពនេសាទនៅតាមតំបន់ឆ្នេរ។ កម្ពុជានឹងបន្តផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវលើការទទួលខុសត្រូវវិស័យជលផល និងការស្តារឡើងវិញនូវធនធានជលផលសមុទ្រ។

### ១.២.៥- កិច្ចសហប្រតិបត្តិការរវាងរដ្ឋនានា

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋនានាសម្របសម្រួលសកម្មភាពរបស់ខ្លួន និងធ្វើសហប្រតិបត្តិការដោយផ្ទាល់ឱ្យបានសមស្រប តាមរយៈអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់នានាដែលពាក់ព័ន្ធ ដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

កម្ពុជាកំពុងចាប់ផ្តើមដោះស្រាយបញ្ហានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតតាមរយៈកិច្ចព្រមព្រៀងទ្វេភាគីនិង/ឬពហុភាគី ដោយប្រើយន្តការដែលបានពិភាក្សាគ្នាក្នុងកិច្ចប្រជុំអនុតំបន់ឈូងសមុទ្រថៃ ដែលបានរៀបចំដោយ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងបានចូលរួមដោយកម្ពុជា

ម៉ាឡេស៊ី ថៃ និងវៀតណាម។ អនុស្សរណៈនៃកិច្ចព្រមព្រៀងរវាងរដ្ឋបាលជលផលនៃព្រះរាជាណាចក្រកម្ពុជានិងអគ្គនាយកដ្ឋានជលផលនៃប្រទេសវៀតណាមដែលបានព្រមព្រៀងនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤។ កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជានិងថៃ មានវឌ្ឍភាពមួយចំនួនដែលទាក់ទងនឹងការគ្រប់គ្រងផលស្តុកឆ្លងដែន ការបង្កើតយន្តការសម្រាប់ការគ្រប់គ្រងនាវានេសាទ រវាងខេត្តកោះកុងនៃព្រះរាជាណាចក្រកម្ពុជានិងខេត្តត្រាតនៃព្រះរាជាណាចក្រថៃ។កិច្ចពិភាក្សាទ្វេភាគីក៏ត្រូវបានរៀបចំឡើងរវាងស្ថាប័នអនុវត្តច្បាប់នៃប្រទេសជិតខាងផងដែរ។

កម្ពុជាទទួលស្គាល់លក្ខខណ្ឌតម្រូវរបស់ផែនការសកម្មភាពថ្នាក់តំបន់ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដើម្បីធ្វើកិច្ចសហប្រតិបត្តិការនិងចែករំលែកព័ត៌មានទាក់ទងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងការស៊ើបអង្កេតដើម្បីទប់ស្កាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត នៅក្នុងតំបន់។

**សកម្មភាពនាពេលអនាគតរួមមានៈ**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | បន្តរៀបចំនិងអនុវត្តកិច្ចព្រមព្រៀងជាមួយប្រទេសថៃនិងវៀតណាមដែលបានឯកភាពគ្នានៅក្នុងអនុស្សរណៈយោគយល់ | ✓ | ✓ | ✓ | ✓ | ✓ |

### ២- ការទទួលខុសត្រូវរបស់កម្ពុជា ក្នុងនាមជារដ្ឋម្ចាស់ឆ្នេរ

ក្នុងការអនុវត្តសិទ្ធិអធិបតេយ្យរបស់រដ្ឋនៅតំបន់ឆ្នេរសម្រាប់ការរុករកនិងធ្វើអាជីវកម្ម គ្រប់គ្រងនិងអភិរក្សធនធានសមុទ្រដែលមានជីវិតក្នុងដែនយុត្តាធិការរបស់ខ្លួន ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត បានអំពាវនាវឱ្យរដ្ឋនានានៅតាមតំបន់ឆ្នេរ អនុវត្តវិធានការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតក្នុងដែនទឹកស្ថិតក្រោមដែនយុត្តាធិការរបស់ខ្លួន។ វិធានការដែលរដ្ឋនៅតំបន់ឆ្នេរ គួរពិចារណាមានដូចជាការតាមដាន ត្រួតពិនិត្យ និងការអង្កេតឱ្យមានប្រសិទ្ធភាព កិច្ចសហប្រតិបត្តិការនិងការផ្លាស់ប្តូរព័ត៌មានជាមួយរដ្ឋនិងអង្គភាពគ្រប់គ្រងជលផលថ្នាក់តំបន់ដទៃទៀត ដើម្បីធានាថារាល់ការនេសាទទាំងអស់ត្រូវមានលិខិតអនុញ្ញាត មានការចុះបញ្ជីនាវាទាំងអស់ មានសៀវភៅកត់ត្រា ត្រួតពិនិត្យលើការផ្ទេរ ការកែច្នៃផលនេសាទ រៀបចំបទប្បញ្ញត្តិនៃការនេសាទ និងជៀសវាងការផ្តល់លិខិតអនុញ្ញាតដល់នាវាដែលធ្លាប់មានប្រវត្តិនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

### ២.១- ការគ្រប់គ្រងធនធានជលផល

កម្ពុជាទទួលស្គាល់ពីតម្រូវការក្នុងការពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យជលផលប្រកបដោយការយកចិត្តទុកដាក់។ដើម្បីសម្រេចកិច្ចការនេះ កម្ពុជាបាននិងកំពុងរៀបចំបង្កើតផែនការគ្រប់គ្រងជលផលឱ្យបានទូលំទូលាយសម្រាប់ធនធានជលផលសមុទ្រ ក្នុងការគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីជលផលដែលបានធ្វើវិសោធនកម្មនិងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១៥-២០២៤។ ផែនការគ្រប់គ្រងវិស័យជលផលត្រូវផ្តោតលើ

ប្រព័ន្ធអេកូឡូស៊ីដើម្បីគ្រប់គ្រងធនធានជលផល ដែលគិតទាំងប្រយោជន៍សេដ្ឋកិច្ចសង្គមនៃការនេសាទ និងតម្លៃចំណាយលើបរិស្ថានដែលអាចកើតមានឡើងតាមរយៈធនធានជលផលដែលបានខូចខាតទម្រង់ និងមុខងារប្រព័ន្ធអេកូឡូស៊ី។ ការគ្រប់គ្រងធនធានជលផលឱ្យមានភាពប្រសើរឡើង ត្រូវធ្វើឱ្យប្រសើរឡើងផងដែរនូវប្រព័ន្ធទិន្នន័យ និងព័ត៌មានជលផល រួមទាំងគោលនយោបាយនិងការធ្វើសេចក្ដីសម្រេចចិត្ត និងការវាយតម្លៃពីស្ថានភាពធនធានជលផលដែលផ្អែកលើការប្រែប្រួលផលនេសាទ និងចំនួនទូកនេសាទ។ ផ្នែកមួយនៃការកែលម្អនេះ គឺជាការចែករំលែកទិន្នន័យនិងព័ត៌មាន ជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការគ្រប់គ្រងប្រកបដោយនិរន្តរភាព | ✓ | ✓ | ✓ | ✓ | ✓ |
| ២ | រៀបចំនិងអនុម័តផែនការជាតិគ្រប់គ្រងផល-ផលសមុទ្រដែលមានលក្ខណៈទូលំទូលាយ | | ✓ | ✓ | | |
| ៣ | កែលម្អប្រព័ន្ធប្រមូលនិងវិភាគទិន្នន័យនៅតាមផែនេសាទ | ✓ | ✓ | | | |
| ៤ | កែលម្អប្រព័ន្ធព័ត៌មានជលផលសម្រាប់ការគ្រប់-គ្រងផលផលនិងអ្នកធ្វើគោលនយោបាយនិងចែករំលែកព័ត៌មានទាំងនោះជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិនិងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | ✓ | ✓ | | | |
| ៥ | ពង្រឹងប្រព័ន្ធប្រមូលទិន្នន័យនិងព័ត៌មានជលផលនិងចែករំលែកជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | | ✓ | ✓ | ✓ | ✓ |

### ២.២- ការផ្ដល់សិទ្ធិដល់នាវានេសាទកម្ពុជានេសាទនៅក្នុងដែនសមុទ្រកម្ពុជា

កម្ពុជាបានទទួលស្គាល់ថា មូលហេតុចម្បងនៃបញ្ហាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការ-អនុញ្ញាតនៅក្នុងដែនសមុទ្ររបស់ខ្លួន គឺការនេសាទហួសកម្រិតដែលបណ្ដាលមកពីការកើនឡើងនូវចំនួននាវានេសាទរបស់កម្ពុជា ព្រមទាំងការបន្តវត្តមាននៃនាវានេសាទបរទេសមកពីប្រទេសជិតខាង។ ដើម្បីសម្រេចបាននូវការគ្រប់គ្រងសមត្ថភាពនេសាទ កម្ពុជាកំពុងខិតខំបន្តការចុះបញ្ជីនិងផ្ដល់លិខិតអនុញ្ញាតសម្រាប់នាវានេសាទខ្នាតតូចនិងខ្នាតមធ្យម។

ក្រោមជំនួយឧបត្ថម្ភរបស់លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ កម្ពុជាកំពុងបង្កើតប្រព័ន្ធប្រមូលទិន្នន័យ ចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតបន្តដែលនឹងជួយដល់ដំណើរការការងារនោះ។ កម្ពុជាកំពុងសហការក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យនាវានេសាទថ្នាក់តំបន់សម្រាប់នាវាដែលមានប្រវែងលើសពី២៤ម៉ែត្រជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | បន្តប្រមូលទិន្នន័យនាវានេសាទសមុទ្រទាំងអស់ | ✓ | ✓ | | | |
| ២ | កសាងសមត្ថភាពក្នុងការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទសមុទ្រទាំងអស់ | | ✓ | | | |
| ៣ | ជំរុញការចុះបញ្ជីនាវានេសាទខ្នាតមធ្យមនិងខ្នាតធំទាំងអស់ | ✓ | ✓ | | | |
| ៤ | ចេញលិខិតអនុញ្ញាតឱ្យនាវានេសាទខ្នាតមធ្យម និងខ្នាតធំទាំងអស់ | ✓ | ✓ | | | |
| ៥ | ចុះកំណត់ត្រានិងចេញប័ណ្ណសម្គាល់ឱ្យនាវានេសាទខ្នាតតូចទាំងអស់ | ✓ | ✓ | | | |
| ៦ | កសាងសមត្ថភាពធនធានមនុស្សនិងស្ថាប័នសម្រាប់ការចុះបញ្ជី ចេញលិខិតអនុញ្ញាតឬប័ណ្ណសម្គាល់ដល់នាវានេសាទសមុទ្រ | ✓ | ✓ | ✓ | ✓ | ✓ |
| ៧ | ធ្វើទំនាក់ទំនងជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ចំពោះនាវានេសាទដែលមានប្រវែងលើសពី២៤ម៉ែត្រ | | ✓ | ✓ | ✓ | ✓ |

**២.៣- ការផ្តល់សិទ្ធិដល់នាវានេសាទបរទេសក្នុងដែននេសាទសមុទ្រកម្ពុជា**

ច្បាប់ស្តីពីជលផលឆ្នាំ២០០៦ បានកំណត់ថាការនេសាទរបស់ជនបរទេសត្រូវធ្វើឡើងដោយមានការព្រមព្រៀងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោយពីទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជារួច។

យោងតាមរបាយការណ៍បានឱ្យដឹងថា មាននាវានេសាទប្រទេសជិតខាងទាំងស្របច្បាប់និងមិនស្របច្បាប់នៅក្នុងដែននេសាទសមុទ្រកម្ពុជា។ ក្នុងនោះក៏មាននាវានេសាទចូលមកដោយគ្មានការអនុញ្ញាតពីរដ្ឋម្ចាស់ទង់ជាតិរបស់ខ្លួន។ នាវានេសាទបរទេសចូលមកនេសាទដោយប្រើឧបករណ៍នេសាទខុសច្បាប់កម្ពុជា ហើយបានធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ធនធានជលផល សេដ្ឋកិច្ចជាតិ និងចំណូលរបស់ប្រជានេសាទក្នុងស្រុក ប៉ុន្តែចំនួននៃផលប៉ះពាល់នេះមិនត្រូវបានដឹងឡើយ។

ប្រទេសជិតខាងកំពុងពង្រឹងការទទួលខុសត្រូវនូវការប្រើទង់ជាតិរបស់ខ្លួន ហើយនាពេលអនាគតនាវាទាំងអស់ដែលចូលមកនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខនៃប្រទេសមួយទៀតត្រូវតែមានការអនុញ្ញាត។

បញ្ហានៃការផ្ដល់សិទ្ធិមានភាពស្មុគស្មាញនៅក្នុងតំបន់ទឹកប្រវត្តិសាស្ត្រនិងតំបន់សមុទ្រទាមទារត្រួតគ្នាដែលរដ្ឋជិតខាងទាំងនោះអះអាងថាមានសិទ្ធិផងដែរ។ តំបន់ទាំងនេះត្រូវមានការរៀបចំនិងមានកិច្ចព្រមព្រៀងដោយឡែក។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | សហការជាមួយប្រទេសថៃនិងវៀតណាម និងមិនអនុញ្ញាតឱ្យនាវានេសាទថៃនិងវៀតណាមធ្វើនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ប្រទេសកម្ពុជា | ✓ | ✓ | | | |
| ២ | ពិភាក្សាស្ដីពីវិធានការគ្រប់គ្រងនិងការធ្វើនេសាទរួមគ្នានៅក្នុងតំបន់សមុទ្រទាមទារត្រួតគ្នាជាមួយថៃនិងតំបន់ទឹកប្រវត្តិសាស្ត្រជាមួយវៀតណាម | | ✓ | ✓ | ✓ | ✓ |

**២.៤- រៀបចំវិធានការត្រួតពិនិត្យនាវាដឹកជញ្ជូននិងនាវាផ្គត់ផ្គង់ផ្សេងៗទៀត**

> ផែនការសកម្មភាពអន្តរជាតិស្ដីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋនានាធានាថានាវាដឹកជញ្ជូននិងនាវាផ្គត់ផ្គង់ មិនត្រូវគាំទ្រឬពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ។

យោងតាមច្បាប់ស្ដីពីជលផលការដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាត្រូវមានលិខិតអនុញ្ញាត និងត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋបាលជលផល។ បរិមាណនៃការផ្ទេរផលនេសាទលើផ្ទៃសមុទ្រកម្ពុជាមានភាពមិនច្បាស់លាស់ ប៉ុន្តែផលនេសាទត្រូវបានដាក់ចុះនៅកន្លែងឡើងផលនេសាទកម្ពុជា ហើយត្រូវបានដឹកចេញដោយនាវាទៅប្រទេសជិតខាង ហើយផលនេសាទទាំងនោះក៏ត្រូវបានដឹកជញ្ជូនដោយរថយន្តទៅកាន់ទីផ្សារក្នុងប្រទេសកម្ពុជានិងនាំចេញទៅប្រទេសជិតខាងផងដែរ។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | ជំរុញការចុះបញ្ជីនាវានិងយានយន្តដែលពាក់ព័ន្ធនឹងការដឹកជញ្ជូននិងការនាំចេញផលផលិតផលជលផល | ✓ | ✓ | | | |
| ២ | បន្តផ្ដល់លិខិតអនុញ្ញាតឱ្យនាវានិងយានយន្តពាក់ព័ន្ធនឹងការដឹកជញ្ជូន និងការនាំចេញផល ផលិតផលជលផល | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នគយនិងរដ្ឋាករនិងអាជ្ញាធរពាក់ព័ន្ធដើម្បីពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យការដឹកជញ្ជូនផលនេសាទ | ✓ | ✓ | ✓ | ✓ | ✓ |

## ២.៥- ការតាមដាន ត្រួតពិនិត្យ និងការអង្កេត

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋទាំងអស់អនុវត្តការតាមដាន ត្រួតពិនិត្យ និងការអង្កេតឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពចំពោះការនេសាទ ចាប់ពីចំណុចចាប់ផ្តើមឆ្លងកាត់ ចំណុចចូលចត រហូតដល់គោលដៅចុងក្រោយ។

**ការតាមដានៈ** ផលចាប់ជលផលសមុទ្រសរុប ត្រូវធ្វើការតាមដានដោយរដ្ឋបាលជលផល។ រដ្ឋបាលជលផលនិងខណ្ឌរដ្ឋបាលជលផលត្រូវរក្សាទុកបញ្ជីនាវានេសាទ។ ការតាមដានចំនួននាវាដែលបានចុះបញ្ជី គឺជាការទទួលខុសត្រូវរបស់នាយកដ្ឋាននាវាជំនួញសមុទ្រ ហើយត្រូវចែករំលែកព័ត៌មានជាមួយរដ្ឋបាលជលផល។ ការតាមដានទិន្នន័យនៃប្រសិទ្ធភាពផលចាប់ក្នុងមួយឯកតា តម្រូវឱ្យធ្វើការវាយតម្លៃលើស្ថានភាពធនធាននិងសមត្ថភាពនេសាទដែលនឹងធ្វើឡើងដោយរដ្ឋបាលជលផលនៅកន្លែងឡើងផលនេសាទតាមតំបន់ឆ្នេរ។ ការងារនេះត្រូវប្រមូលព័ត៌មានពីនាវាមួយចំនួនជាគោលនិងពីអ្នកចែកចាយផលនេសាទក្នុងមូលដ្ឋាន។ កន្លងមក ទិន្នន័យប្រសិទ្ធភាពផលចាប់ក្នុងមួយឯកតាត្រូវបានប្រើជាធាតុចូលនៃស្ថិតិផលចាប់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិតែប៉ុណ្ណោះ។ មានករណីជាច្រើនពាក់ព័ន្ធទិន្នន័យប្រសិទ្ធភាពផលចាប់ក្នុងមួយឯកតាដែលមានប្រយោជន៍ត្រូវបានបាត់បង់ដោយសារសង្កាត់រដ្ឋបាលជលផលមិនមានកុំព្យូទ័រក្នុងការិយាល័យដើម្បីអនុវត្តការងារដ៏សំខាន់នេះទេ។

**ការត្រួតពិនិត្យៈ** ការត្រួតពិនិត្យលើការនេសាទសមុទ្រត្រូវបានបញ្ជាក់នៅក្នុងច្បាប់ស្តីពីជលផលឆ្នាំ២០០៦ និងបទប្បញ្ញត្តិ ហើយច្បាប់ទាំងនោះបង្ហាញពីសកម្មភាពស្របច្បាប់និងសកម្មភាពដែលខុសច្បាប់។ ការត្រួតពិនិត្យទាំងនេះ ត្រូវបានអនុវត្តតាមរយៈផែនការគ្រប់គ្រងវិស័យជលផលថ្មីដែលមានកំណត់គោលបំណងនិងបានដាក់ចេញនូវសកម្មភាពចាំបាច់ដែលត្រូវអនុវត្តមួយចំនួន ដើម្បីសម្រេចគោលបំណងទាំងនោះ។

**ការអង្កេតៈ** រដ្ឋបាលជលផលថ្នាក់ក្រោមជាតិ អនុវត្តជាចម្បងនូវការអង្កេតដោយប្រើនាវាល្បាត។ គ្មាននាវាណាមួយត្រូវបានបំពាក់ប្រព័ន្ធតាមដាននាវាទេ។ ម្យ៉ាងវិញទៀតប្រទេសថៃកំពុងដំឡើងប្រព័ន្ធតាមដាននាវាលើនាវាដែលមានទម្ងន់ផ្ទុកចាប់ពី៣៣ ទម្ងន់ផ្ទុក (≥ 33 GT) ទាំងអស់ ហើយប្រព័ន្ធនេះអាចតាមដាននាវារបស់ថៃនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃតំបន់ឆ្នេរនិងសមុទ្រអន្តរជាតិដទៃទៀត។ ការល្បាតដោយសហគមន៍មូលដ្ឋាននិងការគ្រប់គ្រងធនធានជលផលដោយផ្អែកលើសហគមន៍នេសាទ ជួយក្នុងការអង្កេតការនេសាទខ្នាតតូច និងឃ្លាំមើលការបំពានរបស់អ្នកនេសាទនៅក្នុងតំបន់ហាមឃាត់។

**ការអនុវត្តច្បាប់ៈ** ការស៊ើបអង្កេត ត្រួតពិនិត្យ បង្ការ និងការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទ គឺជាសមត្ថកិច្ចរបស់រដ្ឋបាលជលផល។ មន្ត្រីរដ្ឋបាលជលផលដែលទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិ

ក្នុងការស៊ើបអង្កេតបទល្មើសជលផលនិងកសាងសំណុំរឿងទៅតុលាការ។ អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ អង្គភាពគយនិងរដ្ឋាករ អង្គភាពអាកាសយានដ្ឋាន អាជ្ញាធរកំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀតត្រូវសហការស៊ើបអង្កេត បង្ការ និងបង្ក្រាបបទល្មើសជលផល។ ចំនួននៃការចាប់ខ្លួននិងការផ្តន្ទាទោសត្រូវបានកត់ត្រាទុកក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលជលផល។

សមត្ថភាពរបស់កម្ពុជាក្នុងការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានានៅមានកម្រិតនៅឡើយ។ ការធ្វើអធិការកិច្ចនៅលើផ្ទៃសមុទ្រក៏មានឧបសគ្គដោយខ្វះមធ្យោបាយ ឧបករណ៍សម្ភារ ប្រេងឥន្ធនៈ កម្លាំង និងសមត្ថភាពមន្ត្រីនៅមានកម្រិត។ ការធ្វើអធិការកិច្ចនៅកន្លែងឡើងផលនេសាទមិនទាន់បានអនុវត្តនៅឡើយ។ មិនត្រឹមតែខ្វះកម្លាំងនិងសមត្ថភាពមន្ត្រីនោះទេ ក៏នៅមានបញ្ហាប្រឈមជាច្រើនក្នុងការពង្រឹងការតាមដាន ត្រួតពិនិត្យ និងអង្កេត នៅតំបន់ឆ្នេរថែមទៀត។

កម្ពុជាកំពុងបង្កើតផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ ដែលបញ្ជាក់ពីអាទិភាពសម្រាប់ការតាមដាន ត្រួតពិនិត្យ និងអង្កេតដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត នៅតាមបណ្តាខេត្តតំបន់ឆ្នេរទាំង៤ ដោយផ្អែកលើការវាយតម្លៃហានិភ័យដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តផែនការនេះ។ អាទិភាពទាំងនេះ នឹងត្រូវបានបញ្ជាក់តាមរយៈសកម្មភាព រួមទាំងតម្រូវការក្នុងការត្រួតពិនិត្យនៅលើផ្ទៃសមុទ្រ ការត្រួតពិនិត្យនៅកន្លែងឡើងផលនេសាទ វិធានការរដ្ឋម្ចាស់កំពង់ផែ និងការធ្វើរបាយការណ៍។ ផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ ក៏ត្រូវការធនធានមនុស្ស ជាពិសេសអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រនិងខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរដើម្បីអនុវត្តបេសកកម្មរបស់ខ្លួន។

កម្ពុជាជារដ្ឋសមាជិកនៃផែនការសកម្មភាពថ្នាក់តំបន់ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលបានបង្កើតនីតិវិធីសម្រាប់កត់ត្រាក្នុងបញ្ជីនិងបញ្ជីខ្មៅនៃប្រទេសដែលបានជំរុញឱ្យមានការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | បន្តរៀបចំនិងអនុវត្តផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ | ✓ | ✓ | ✓ | ✓ | ✓ |
| ២ | បន្តបណ្តុះបណ្តាលការងារតាមដាន ត្រួតពិនិត្យ និងអង្កេតដែលមានចែងនៅក្នុងផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ | ✓ | ✓ | ✓ | ✓ | ✓ |
| ៣ | ទិញ ជួសជុល និងថែរក្សានាវាល្បាត | ✓ | ✓ | ✓ | ✓ | ✓ |
| ៤ | រៀបចំកម្មវិធីដើម្បីចាប់ផ្តើមការងារក្រុមអង្កេតការ | ✓ | | | | |
| ៥ | បណ្តុះបណ្តាលនិងផ្តល់ឱ្យប្រើប្រាស់នូវសៀវភៅកត់ត្រាស្ថិតិផលនេសាទសម្រាប់នាវានេសាទសមុទ្រខ្នាតធំ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦ | បណ្តុះបណ្តាលនិងផ្តល់ឱ្យប្រើប្រាស់នូវសៀវភៅកត់ត្រាស្ថិតិផលនេសាទសម្រាប់នាវានេសាទ | | ✓ | ✓ | ✓ | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| | សមុទ្រខ្នាតមធ្យម | | | | | |
| ៧ | សិក្សា ពិនិត្យ និងជ្រើសរើសឧបករណ៍តាមដានសមស្របដើម្បីដំឡើងប្រព័ន្ធតាមដានក្នុងនាវានេសាទខ្នាតមធ្យមនិងខ្នាតធំ | ✓ | | | | |
| ៨ | ដំឡើងប្រព័ន្ធតាមដានសម្រាប់នាវានេសាទខ្នាតមធ្យមនិងធំ | | ✓ | | | |

### ៣- ការទទួលខុសត្រូវរបស់កម្ពុជា ក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិ

### ៣.១- ការចុះបញ្ជី និងកត់ត្រានាវានេសាទ នៅក្នុងដែននេសាទសមុទ្ររបស់រដ្ឋដទៃឬនៅសមុទ្រអន្តរជាតិ

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋទាំងអស់ត្រូវធានាថានីតិវិធីចុះបញ្ជីនាវា និងការផ្តល់សិទ្ធិឱ្យធ្វើនេសាទរបស់នាវារដ្ឋម្ចាស់ទង់ជាតិនិងនាវាដែលបានផ្តល់សិទ្ធិ មិនត្រូវចូលរួមឬគាំទ្រចំពោះការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋម្ចាស់ទង់ជាតិនីមួយៗរក្សាកំណត់ត្រារបស់នាវានេសាទដែលមានសិទ្ធិបំពាក់ទង់ជាតិរបស់ខ្លួន។ រដ្ឋម្ចាស់ទង់ជាតិនីមួយៗត្រូវកត់ត្រាអំពីនាវានេសាទរបស់ខ្លួន រួមបញ្ចូលទាំងនាវាដែលបានអនុញ្ញាតនេសាទនៅសមុទ្រអន្តរជាតិ ត្រូវបញ្ចូលព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ ក្នុងប្រការ៤នៃកិច្ចព្រមព្រៀងរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ១៩៩៣ ព្រមទាំងព័ត៌មានបន្ថែមដែលបានចែងក្នុងកថាខណ្ឌ៤២នៃផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

**សម្គាល់:** ផ្នែកនៃផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនេះ សំដៅដល់នាវាដែលដាក់ទង់ជាតិកម្ពុជានៅសមុទ្រអន្តរជាតិនិងដែននេសាទសមុទ្ររបស់រដ្ឋដទៃទៀត។ ការចុះបញ្ជីនិងការអនុញ្ញាតឱ្យនាវាចូលក្នុងដែននេសាទសមុទ្ររបស់កម្ពុជា គឺបានបញ្ជាក់ក្នុងផ្នែកទី៤ រដ្ឋម្ចាស់ផែ្នរ។

ដោយសារការចុះបញ្ជីនាវាអន្តរជាតិ អនុវត្តដោយក្រុមហ៊ុន ចុះបញ្ជីនាវាអន្តរជាតិនៃកម្ពុជា ត្រូវបានផ្ទេរភារកិច្ចឱ្យក្រសួងសាធារណការនិងដឹកជញ្ជូនកម្ពុជា។ ក្រសួងសាធារណការនិងដឹកជញ្ជូនកម្ពុជាចាំបាច់ត្រូវរៀបចំប្រព័ន្ធចុះបញ្ជីសម្រាប់នាវាដែលមិនធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដើម្បីនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃនៅសមុទ្រអន្តរជាតិនិងតំបន់គ្រប់គ្រងដោយអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់នាពេលអនាគត។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | សហការវិភាគតម្លៃដាក់ទុននិងផលចំណេញសម្រាប់ការលើកឱ្យមានការចុះបញ្ជីនាវានេសាទបរទេសឡើងវិញ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | ✓ | ✓ | | | |
| ២ | រៀបចំប្រព័ន្ធចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទដែលបំពាក់ទង់ជាតិកម្ពុជា នេសាទក្នុងរដ្ឋដទៃ ឬនៅសមុទ្រអន្តរជាតិ | ✓ | ✓ | | | |

### ៣.២ ការផ្តល់សិទ្ធិឱ្យធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃនិងក្នុងសមុទ្រអន្តរជាតិ

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋទាំងអស់ធានាថាគ្មាននាវានេសាទណាដែលត្រូវបានអនុញ្ញាតឱ្យនេសាទដោយគ្មានការអនុញ្ញាតស្របតាមច្បាប់អន្តរជាតិនៅសមុទ្រអន្តរជាតិឡើយ។ រដ្ឋម្ចាស់ទង់ជាតិត្រូវធានាថានាវានីមួយៗ ដែលបានផ្តល់សិទ្ធិបំពាក់ទង់ជាតិនេសាទនៅក្នុងដែនទឹកខាងក្រៅអធិបតេយ្យភាពរបស់ខ្លួនឬដែនយុត្តាធិការរបស់ខ្លួន ត្រូវកាន់លិខិតអនុញ្ញាតនៅមានសុពលភាពនេសាទ ដែលចេញដោយរដ្ឋម្ចាស់ទង់ជាតិនោះ។ រដ្ឋម្ចាស់ឆ្នេរដែលអនុញ្ញាតឱ្យនាវានេសាទត្រូវធានាថា គ្មានការនេសាទកើតឡើងក្នុងដែនទឹករបស់ខ្លួនដោយគ្មានការផ្តល់សិទ្ធិឱ្យនេសាទដែលចេញដោយរដ្ឋម្ចាស់ទង់ជាតិឡើយ។

កន្លងមករដ្ឋបាលជលផលកម្ពុជា មិនបានអនុញ្ញាតឱ្យនាវានេសាទឬអនុញ្ញាតឱ្យនាវាដឹកជញ្ជូនដាក់ទង់ជាតិរបស់ខ្លួននេសាទឬដឹកជញ្ជូនផលនេសាទនៅក្នុងដែននេសាទសមុទ្ររបស់រដ្ឋដទៃឬនៅក្នុងសមុទ្រអន្តរជាតិ ទោះបីជាសកម្មភាពនេះបានកើតឡើងតាមរយៈ "ការផ្តល់ទង់ជាតិកម្ពុជាឱ្យទៅនាវាប្រទេសដទៃ" ក៏ដោយ។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | រៀបចំយន្តការនៃការផ្តល់សិទ្ធិឱ្យនាវាធ្វើនេសាទមិនមែនជាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលបំពាក់ទង់ជាតិកម្ពុជានៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃឬនៅក្នុងសមុទ្រអន្តរជាតិរួមទាំងវិធានការត្រួតពិនិត្យនិងអធិការកិច្ចដ៏មានប្រសិទ្ធភាព | ✓ | ✓ | ✓ | ✓ | ✓ |

### ៣.៣- វិធានការត្រួតពិនិត្យនាវាពាក់ព័ន្ធនឹងការនេសាទ

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋម្ចាស់ទង់ជាតិធានាថា នាវានេសាទ នាវាដឹកជញ្ជូន ឬនាវាផ្គត់ផ្គង់របស់ពួកគេ មិនគាំទ្រឬពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនោះទេ។

| ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ក៏អំពាវនាវផងដែរឱ្យរដ្ឋនានាខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីធានាថា នាវានេសាទ នាវាដឹកជញ្ជូន ឬនាវាផ្គត់ផ្គង់របស់ពួកគេ ដែលបានចូលរួមផ្ទេរផលនេសាទនៅសមុទ្រ ត្រូវធ្វើឡើងដោយមានលិខិតអនុញ្ញាតចេញដោយរដ្ឋម្ចាស់ទង់ជាតិជាមុននិងត្រូវរាយការណ៍អំពីព័ត៌មានជាក់លាក់ទៅឱ្យរដ្ឋបាលជលផលថ្នាក់ជាតិឬស្ថាប័នពាក់ព័ន្ធ។ |
|---|

នៅក្នុងខែឧសភា ឆ្នាំ២០១៧ គ្មាននាវានេសាទដែលបំពាក់ទង់ជាតិកម្ពុជានេសាទនៅក្នុងសមុទ្រអន្តរជាតិឡើយ។ កម្ពុជាបានផ្តល់ការយល់ព្រមទៅលើកិច្ចព្រមព្រៀងស្តីពីផលស្តុកត្រីរបស់អង្គការសហប្រជាជាតិ ដើម្បីធ្វើការសម្រេចចិត្តក្នុងការបើកឡើងវិញនូវការចុះបញ្ជីនាវានេសាទជាលក្ខណៈអន្តរជាតិ។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | បង្កើតប្រព័ន្ធចុះបញ្ជី ផ្តល់លិខិតអនុញ្ញាតនិងកត់ត្រានាវានេសាទ ដឹកជញ្ជូន និងនាវាផ្គត់ផ្គង់កម្ពុជានៅក្នុងដែននេសាទសមុទ្ររដ្ឋដទៃ និងសមុទ្រអន្តរជាតិ | | ✓ | ✓ | ✓ | |

## ៤- វិធានការរដ្ឋម្ចាស់កំពង់ផែ

### ៤.១- ការអនុវត្តវិធានការសកម្មភាពនាពេលអនាគតរួមមាន:រដ្ឋម្ចាស់កំពង់ផែ

| ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាតអំពាវនាវឱ្យរដ្ឋនានាអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែឱ្យស្របតាមច្បាប់អន្តរជាតិក្នុងការត្រួតពិនិត្យនាវានេសាទដែលចេញចូលកំពង់ផែដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ |
|---|

នាវានេសាទបរទេសមួយចំនួនបានប្រើកំពង់ផែឬកន្លែងឡើងផលនេសាទរបស់កម្ពុជា។ ប៉ុន្តែមានរបាយការណ៍កន្លងមកបញ្ជាក់ថាមានទូកនេសាទអួនអូសរបស់ប្រទេសជិតខាងបានចូលចតនិងឡើងផលនេសាទរបស់ខ្លួននៅខេត្តជាប់ព្រំដែនប្រទេសកម្ពុជា ដើម្បីគេចពីការបង្ក្រាបដ៏តឹងរ៉ឹងចំពោះសកម្មភាពនេសាទខុសច្បាប់ក្នុងប្រទេសទាំងនោះ។ នាវាផ្ទេរផលនេសាទក៏បានប្រើផែឬកន្លែងឡើងផលនេសាទកម្ពុជាដែរ។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើវិធានការរដ្ឋម្ចាស់កំពង់ផែនិងរៀបចំផែនការអនុវត្ត។

សកម្មភាពនាពេលអនាគតរួមមាន:

| ល.រ | **សកម្មភាព** | **២០២០** | **២០២១** | **២០២២** | **២០២៣** | **២០២៤** |
|---|---|---|---|---|---|---|
| ១ | កំណត់កំពង់ផែឬកន្លែងឡើងផលនេសាទផ្លូវការសម្រាប់នាវាបរទេស | ✓ | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | បង្ហាញឬផ្សព្វផ្សាយកន្លែងឡើងផលនេសាទឬកំពង់ផែនេសាទ សម្រាប់ធ្វើអធិការកិច្ច ចំពោះនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត របស់បរទេស | ✓ | ✓ | ✓ | ✓ | ✓ |

## ៤.២- នីតិវិធីចំពោះនាវាបរទេសដែលបានរកឃើញថាជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

| |
|---|
| នៅពេលធ្វើអធិការកិច្ច ប្រសិនបើរដ្ឋម្ចាស់កំពង់ផែរកឃើញមូលហេតុច្បាស់លាស់ដែលសង្ស័យថានាវាណាមួយពាក់ព័ន្ធឬគាំទ្រសកម្មភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋម្ចាស់កំពង់ផែរាយការណ៍ជាបន្ទាន់អំពីបញ្ហានេះទៅរដ្ឋម្ចាស់ទង់ជាតិរបស់នាវានោះនិងអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ណាមួយដែលពាក់ព័ន្ធប្រសិនបើអាចធ្វើបាន។ រដ្ឋម្ចាស់កំពង់ផែអាចចាត់វិធានការណ៍ផ្សេងទៀតដោយមានការឯកភាពឬព្រមព្រៀងទៅតាមសំណើរបស់រដ្ឋម្ចាស់ទង់ជាតិ។ |

កម្ពុជាកំពុងស្វែងរកមធ្យោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ទ្វេភាគីនិងពហុភាគីស្តីពីការអនុវត្ត "វិធានការរដ្ឋម្ចាស់កំពង់ផែ" នៅតាមផែឡើងផលនេសាទ ដោយនាវាបរទេស។ បញ្ហានេះរួមបញ្ចូលនីតិវិធីសម្រាប់នាវាបរទេសដែលបានរកឃើញថាជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | បង្កើត និងអនុវត្តនីតិវិធីចំពោះនាវាបរទេសដែលរកឃើញថាបាននេសាទ ខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត | ✓ | ✓ | | | |

## ៤.៣ កិច្ចសហប្រតិបត្តិការជាមួយរដ្ឋម្ចាស់កំពង់ផែ ឬអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ពាក់ព័ន្ធ

| |
|---|
| ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋនានាធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ពាក់ព័ន្ធឱ្យបានសមស្រប ដើម្បីបង្កើតវិធានការរួមដែលអាចអនុវត្តបានសម្រាប់រដ្ឋម្ចាស់កំពង់ផែក្នុងការត្រួតពិនិត្យនាវានេសាទទាំងនោះ។ ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ក៏ជំរុញឱ្យរដ្ឋនានាពិចារណាបង្កើតវិធានការរដ្ឋម្ចាស់កំពង់ផែសមស្របជាមួយអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ពាក់ព័ន្ធដើម្បីចាត់វិធានការចំពោះនាវានេសាទដែលមានសិទ្ធិប្រើទង់ជាតិនៃរដ្ឋនានា មិនមែនជាភាគីនិងមិនព្រមធ្វើសហការជាមួយអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ពាក់ព័ន្ធណាមួយ ដែលបញ្ជាក់ថាអាចចូលរួមក្នុងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត នៅក្នុងតំបន់របស់អង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ណាមួយ។ |

ប្រទេសកម្ពុជា កំពុងស្វែងរកមធ្យោបាយពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងកិច្ចពិភាក្សាទ្វេភាគីឬពហុភាគីដើម្បីពង្រឹងវិធានការរដ្ឋម្ចាស់កំពង់ផែ។ កម្ពុជាក៏បានចូលរួមជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ ដើម្បីបង្កើតជាបណ្តាញតាមដាន ត្រួតពិនិត្យ និងអង្កេតនៅក្នុងឈូងសមុទ្រថៃនៅពាក់កណ្តាលឆ្នាំ ២០១៩។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | សហការជាមួយរដ្ឋតំបន់ឆ្នេរ រដ្ឋម្ចាស់កំពង់ផែ និងរដ្ឋពាក់ព័ន្ធនានាព្រមទាំងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ស្តីពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | ✓ | ✓ | ✓ | ✓ | ✓ |
| ២ | ចែករំលែកព័ត៌មានស្តីពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងការតាមដាន ត្រួតពិនិត្យ និងអង្កេត | ✓ | ✓ | ✓ | ✓ | ✓ |

## ៥- វិធានការទាក់ទងនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ

> ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋនានាចូលរួមសហការ តាមរយៈអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងថ្នាក់ពិភពលោកដើម្បីអនុម័តវិធានការសមស្របទាក់ទងនឹងពាណិជ្ជកម្មដែលបានព្រមព្រៀងជាពហុភាគីស្របតាមអង្គការពាណិជ្ជកម្មពិភពលោកដែលចាំបាច់ក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

ច្បាប់ស្តីពីជលផលចែងថាការនាំចេញ និងការនាំចូលជាលក្ខណៈពាណិជ្ជកម្មនូវផល ផលិតផលជលផល អាចអនុវត្តទៅបានលុះត្រាតែ:

- មានលិខិតអនុញ្ញាតដែលចេញដោយប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល
- មានលិខិតអនុញ្ញាតដែលចេញដោយអាជ្ញាធរគ្រប់គ្រងអនុសញ្ញាអន្តរជាតិស្តីពីការធ្វើពាណិជ្ជកម្មលើប្រភេទសត្វនិងរុក្ខជាតិដែលជិតផុតពូជរបស់កម្ពុជា ចំពោះប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ ទោះបីជាមិនធ្វើពាណិជ្ជកម្មក៏ដោយ។

ការទិញ ការលក់ ការកែច្នៃ ការធ្វើសន្និធិ និងការដឹកជញ្ជូនផល ផលិតផលជលផលបានពីការនេសាទខុសច្បាប់ត្រូវបានហាមឃាត់។ ទោះជាយ៉ាងនេះក្តី ការត្រួតពិនិត្យការនាំចេញនិងនាំចូលតាមផ្លូវគោក និងសមុទ្រមានការលំបាក ហើយជាទូទៅនៅមានសកម្មភាពខុសច្បាប់ជាច្រើន។

**ប្រព័ន្ធឯកសារគ្រប់គ្រងផលនេសាទ**

> ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ស្នើថាលិខិតបញ្ជាក់និងឯកសារចាំបាច់នានាត្រូវមានស្តង់ដារនិងត្រឹមត្រូវទៅតាម

| |
|---|
| បទដ្ឋាននានា និងប្រើប្រព័ន្ធអេឡិចត្រូនិក ប្រសិនបើអាចបង្កើតបាន ដើម្បីធានាប្រសិទ្ធភាព កាត់បន្ថយឱកាសការលួចបន្លំ និងការគេចវេះពីការបង់ពន្ធ។ |

កម្ពុជាកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ផលផលនៃតំបន់អាស៊ីអាគ្នេយ៍ ដើម្បីបង្កើតប្រព័ន្ធឯកសារគ្រប់គ្រងផលនេសាទរបស់អាស៊ាន។

**គោលបំណងនៃការបង្កើតប្រព័ន្ធនេះគឺ:**

(១) ផ្តល់ក្របខ័ណ្ឌរួមដែលនឹងពង្រឹងការតាមដានផល ផលិតផលជលផលសម្រាប់ការគ្រប់គ្រងធនធានជលផលសមុទ្រនៅក្នុងប្រទេសសមាជិកអាស៊ានប្រកបដោយប្រសិទ្ធភាព។

(២) បង្កើនភាពជឿជាក់លើផល ផលិតផលជលផលសម្រាប់ពាណិជ្ជកម្មថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

(៣) បង្ការ និងទប់ស្កាត់ការនាំចូលផល ផលិតផលជលផលពីសកម្មភាពនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត ចូលក្នុងខ្សែច្រវាក់ផលិតកម្មរបស់ប្រទេសសមាជិកអាស៊ាន។

**ប្រព័ន្ធឯកសារគ្រប់គ្រងផលនេសាទរួមមាន:**

- របាយការណ៍ផលនេសាទ/សៀវភៅកត់ត្រាស្ថិតិផលនេសាទឬតារាងកត់ត្រា
- ការបញ្ជូនឯកសារចាប់ពីផែឡើងផលនេសាទដល់គោលដៅ
- វិញ្ញាបនបត្របញ្ជាក់ផលនេសាទរបស់អាស៊ាន សម្រាប់ការនាំចេញ
- វិញ្ញាបនបត្របញ្ជាក់អំពីការកែច្នៃផលនេសាទសម្រាប់នាំចេញបន្ត
- វិញ្ញាបនបត្របញ្ជាក់ការនាំចេញបន្តរបស់អាស៊ានសម្រាប់នាំចូលផល ផលិតផលជលផលពីប្រទេសដែលមិនមែនជាសមាជិកអាស៊ាន។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | អនុម័តនិងសាកល្បងប្រើប្រព័ន្ធឯកសារផលនេសាទអាស៊ាននិងលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ | | ✓ | ✓ | ✓ | ✓ |
| ២ | កសាងសមត្ថភាពក្នុងការកត់ត្រាស្ថិតិផលនេសាទនិងផ្ទៀងផ្ទាត់លិខិតអនុញ្ញាតជាមួយប្រទេសនានា | | | ✓ | ✓ | ✓ |

**៦- កិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងប្រទេសផ្សេងទៀត ដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត**

***ការប្រតិបត្តិចំពោះប្រទេសដែលមិនមែនជាសមាជិក***

| |
|---|
| ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋនានាប្រើកាតព្វកិច្ចរបស់ខ្លួនដើម្បីធ្វើសហការ ដោយយល់ព្រម អនុវត្តន៍វិធានការគ្រប់គ្រង និងអភិរក្សជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ចំពោះរដ្ឋមិនមែនជាសមាជិកឬអនុម័តលើវិធានការដោយស្របតាមវិធានការគ្រប់គ្រងនិងអភិរក្សរបស់អង្គការគ្រប់គ្រងជលផល |

ថ្នាក់តំបន់និងត្រូវធានាថានាវាដែលមានសិទ្ធិប្រើទង់ជាតិរបស់ខ្លួនមិនធ្វើឱ្យប៉ះពាល់ដល់វិធានការណ៍ទាំងនោះ។

ទោះបីកម្ពុជាមិនមែនជាសមាជិករបស់អង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ ប៉ុន្តែកម្ពុជាមានបំណងសហការតាមការស្នើសុំព័ត៌មានដែលអាចធ្វើទៅបាន ជាពិសេសបញ្ហានៃការប្រើទង់ជាតិ។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | បន្តផ្តល់ព័ត៌មានដល់អង្គការគ្រប់គ្រងផលផលថ្នាក់តំបន់អំពីនាវានេសាទដោតទង់ជាតិកម្ពុជានៅក្នុងសមុទ្រអន្តរជាតិនិងក្នុងតំបន់របស់អង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ | | ✓ | ✓ | ✓ | ✓ |

**៧- លក្ខខណ្ឌតម្រូវពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ**

ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ទទួលស្គាល់នូវតម្រូវការពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍ។ ហេតុនេះផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត អំពាវនាវឱ្យរដ្ឋនានាធ្វើការគាំទ្រដល់ការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងពិចារណាផ្តល់ជំនួយហិរញ្ញវត្ថុ បច្ចេកទេស និងជំនួយផ្សេងៗដល់ប្រទេសកំពុងអភិវឌ្ឍ ជាពិសេសការជួយដល់ប្រទេសដែលមានការអភិវឌ្ឍតិចតួច និងប្រទេសជាកោះតូចៗកំពុងអភិវឌ្ឍ ដែលនាំឱ្យប្រទេសទាំងនោះមានការប្តេជ្ញាចិត្តខ្ពស់ ដោយអនុលោមតាមផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងកាតព្វកិច្ចស្ថិតក្រោមច្បាប់អន្តរជាតិ រួមទាំងកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិនិងរដ្ឋម្ចាស់កំពង់ផែ។

**ការកសាងសមត្ថភាពនៅក្នុងបណ្តាប្រទេសអាស៊ាន**

កម្ពុជាស្វាគមន៍ការកសាងសមត្ថភាពទាក់ទងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ជាពិសេសផ្តោតលើការគ្រប់គ្រងសមត្ថភាពនេសាទ ការចុះបញ្ជី ការផ្តល់លិខិតអនុញ្ញាត ការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងអង្កេត និងច្បាប់អន្តរជាតិ ព្រមទាំងកាតព្វកិច្ចនានា។ កម្ពុជាមានបំណងចូលរួមក្នុងប្រតិបត្តិការល្បាតរួមស្របតាមស្តង់ដារអន្តរជាតិ និងការគ្រប់គ្រងធនធានជលផលដោយប្រើវិធានការ តាមដានត្រួតពិនិត្យ និងអង្កេត។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | បន្តកិច្ចសហការជាមួយអាស៊ានលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ | ✓ | ✓ | ✓ | ✓ | ✓ |

## ៨- ការរាយការណ៍

| |
|---|
| ផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយ-ការណ៍ និងគ្មានការអនុញ្ញាត តម្រូវឱ្យរដ្ឋនានាត្រូវរាយការណ៍ទៅកាន់អង្គការស្បៀងនិងកសិកម្មនៃសហប្រជា-ជាតិជារៀងរាល់ពីរ(២)ឆ្នាំម្តង អំពីវឌ្ឍនភាពនៃការអនុវត្តផែនការរបស់ខ្លួនដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់សកម្ម ភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដោយមានការពន្យល់ច្បាស់លាស់ស្តីពីក្រមប្រតិបត្តិក្នុងវិស័យជលផល។ របាយការណ៍ទាំងនេះត្រូវចេញផ្សាយដោយអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឱ្យទាន់ពេលវេលា។ |

**លក្ខខណ្ឌក្នុងការរាយការណ៍**

កម្ពុជាត្រូវរាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត របស់ខ្លួនតាមរយៈរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលជលផល។ កម្ពុជាត្រូវរាយការណ៍ទៅអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិរៀងរាល់ពីរ(២)ឆ្នាំម្តង ពីវឌ្ឍនភាពដោយមានការពន្យល់និងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

**សកម្មភាពនាពេលអនាគតរួមមាន:**

| ល.រ | សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | រៀបចំផែនការនិងអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងថវិកាសម្រាប់អនុវត្តប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ |
| ២ | រាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | ✓ | ✓ | ✓ | ✓ | ✓ |
| ៣ | រាយការណ៍ទៅកាន់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិរៀងរាល់ពីរឆ្នាំម្តង | | ✓ | | ✓ | |

## ៤- គម្រោងចំណាយ

ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត កំណត់សកម្មភាពនានាឱ្យបានទូលំទូលាយ និងច្បាស់លាស់ជារៀងរាល់ឆ្នាំ។ សកម្មភាពដែលកំពុងបន្តអនុវត្តត្រូវការថវិកាជានិរន្តរ៍។ ការរៀបចំផែនការសម្រាប់អនុវត្តសកម្មភាព ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត កម្ពុជាបានរៀបចំផែនការលម្អិតបីឆ្នាំរំកិល ផ្អែកលើសកម្មភាពនានាដែលមាននៅក្នុងផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដោយចាប់ផ្តើមអនុវត្តនៅឆ្នាំ២០២០ និងបានបញ្ជាក់អំពី: (១) ស្ថាប័នអនុវត្ត (២)វិធីសាស្រ្តនៃការអនុវត្ត (៣) ពេលវេលា និងការចំណាយ។ សកម្មភាពទាំងនេះ ត្រូវបានសង្ខេបក្នុងតារាងម៉ាទ្រិករួមមាន: (១) ស្ថាប័នទទួលខុសត្រូវ (២) សូចនាករគន្លឹះសម្រាប់វាស់វែងការអនុវត្ត និង(៣) ប្រភពថវិកាសម្រាប់ឆ្នាំនីមួយៗ។

**គម្រោងថវិកាចំណាយ ចំណុចដៅ និងស្ថាប័នទទួលខុសត្រូវសម្រាប់អនុវត្តសកម្មភាពនីមួយៗរបស់ផែនការសកម្មភាពជាតិ**

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| **១-ការទទួលខុសត្រូវរបស់រដ្ឋ** | | | | | | | | |
| **១.១- លិខិតុបករណ៍អន្តរជាតិសំខាន់ៗ** | | | | | | | | |
| ១.១.១- កិច្ចព្រមព្រៀងរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ | ៦០ ០០០ | | | | | ៦០ ០០០ | ឯកសារវិធានការរដ្ឋម្ចាស់កំពង់ផែ ត្រូវបានអនុម័ត បោះពុម្ព និងផ្សព្វផ្សាយ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១.១.២- កិច្ចព្រមព្រៀងអង្គការសហប្រជាជាតិស្តីពីផលស្តុកត្រី | ១០ ០០០ | | | | | ១០ ០០០ | កិច្ចព្រមព្រៀងអង្គការសហប្រជាជាតិស្តីពីផលស្តុកត្រី ត្រូវបានអនុម័ត បោះពុម្ព និងផ្សព្វផ្សាយ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| ១.១.៣- ច្បាប់អង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ | | | | | | | ជូនដំណឹងដល់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងការផ្តល់សច្ចាប័ន | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **១.២- ក្របខ័ណ្ឌច្បាប់ជាតិ** | | | | | | | | |
| **១.២.១- បទប្បញ្ញត្តិ** | | | | | | | | |
| ១.២.១.១- បន្តពិនិត្យកែសម្រួលសេចក្តីព្រាងនិងអនុម័តវិសោធនកម្មច្បាប់ស្តីពីជលផលនិងអនុក្រឹត្យស្តីពីជលផលសមុទ្រនិងការនេសាទនៅតំបន់សមុទ្រក្រៅ | ២០០ ០០០ | | | | | ២០០ ០០០ | វិសោធនកម្មច្បាប់ស្តីពីជលផលត្រូវបានអនុម័តនិងផ្សព្វផ្សាយ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១.២.១.២- អនុម័តវិសោធនកម្មច្បាប់ស្តីពីជលផលនិងអនុក្រឹត្យស្តីពីជលផលសមុទ្រនិងការនេសាទនៅតំបន់សមុទ្រក្រៅ | ១០ ០០០ | | | | | ១០ ០០០ | អនុក្រឹត្យស្តីពីជលផលសមុទ្រនិងការនេសាទនៅតំបន់សមុទ្រក្រៅត្រូវបានអនុម័តនិងផ្សព្វផ្សាយ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **១.២.៣- ទោសប្បញ្ញត្តិ និងការដាក់ទណ្ឌកម្ម** | | | | | | | | |
| ១.២.៣.១- បន្តកែសម្រួលទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីជលផលឡើងវិញដោយដាក់ការផាកពិន័យឱ្យមានប្រសិទ្ធភាព | ១០ ០០០ | ១០ ០០០ | | | | ២០ ០០០ | | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| **១.២.៥- សហប្រតិបត្តិការវាងរដ្ឋនានា** | | | | | | | | |
| ១.២.៥.១- បន្តរៀបចំនិងអនុវត្តកិច្ចព្រមព្រៀងជាមួយប្រទេសថៃនិងវៀតណាមដែលបានឯកភាពគ្នានៅក្នុងអនុស្សរណៈយោគយល់ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ១០០ ០០០ | អនុស្សរណៈយោគយល់សម្រាប់អនុវត្តសកម្មភាពនានាត្រូវបានរៀបចំនិងឯកភាព | រដ្ឋបាលជលផលនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **២- ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ទង់** | | | | | | | | |
| **២.១- ការគ្រប់គ្រងធនធានជលផលនៅកម្ពុជា** | | | | | | | | |
| ២.១.១- លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការគ្រប់គ្រងប្រកបដោយនិរន្តរភាព | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ១០០ ០០០ | ការយល់ដឹងរបស់អ្នកពាក់ព័ន្ធស្តីពីសារៈសំខាន់នៃការគ្រប់គ្រងប្រកបដោយនិរន្តរភាពត្រូវបានលើកកម្ពស់ | រដ្ឋបាលជលផលនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.១.២- រៀបចំនិងអនុម័តផែនការជាតិគ្រប់គ្រងជលផលសមុទ្រដែលមានលក្ខណៈទូលំទូលាយ | | ៥០ ០០០ | ៥០ ០០០ | | | ១០០ ០០០ | ផែនការគ្រប់គ្រងជលផលត្រូវបានបញ្ចប់និងអនុម័ត | រដ្ឋបាលជលផលនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.១.៣- កែលម្អប្រព័ន្ធប្រមូលនិងវិភាគទិន្នន័យនៅតាមផែនេសាទ | ៥០ ០០០ | ៥០ ០០០ | | | | ១០០ ០០០ | របាយការណ៍ប្រព័ន្ធទិន្នន័យនិងព័ត៌មានជលផលត្រូវបានធ្វើការកែសម្រួលនិងផ្តល់អនុសាសន៍ | រដ្ឋបាលជលផល |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| ២.១.៤- កែលម្អប្រព័ន្ធព័ត៌មានជលផលសម្រាប់ការគ្រប់គ្រងជលផល និងអ្នកធ្វើគោលនយោបាយនិងចែករំលែកព័ត៌មានទាំងនោះជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | ១០០ ០០០ | ១០០ ០០០ | | | | ២០០ ០០០ | ការប្រមូលទិន្នន័យនិងប្រព័ន្ធព័ត៌មានជលផលត្រូវបានកែលម្អដោយធ្វើការប្រៀបធៀបទៅនឹងទិន្នន័យឆ្នាំគោល ២០១៨។ ព័ត៌មានត្រូវបានចែករំលែកជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀង និងកសិកម្មនៃសហប្រជា-ជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ជារៀងរាល់ឆ្នាំ | រដ្ឋបាលជលផល |
| ២.១.៥- ពង្រឹងប្រព័ន្ធប្រមូលនិងវិភាគទិន្នន័យព័ត៌មានជលផលនិងចែករំលែកជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ២០០ ០០០ | ការប្រមូលទិន្នន័យនិងប្រព័ន្ធព័ត៌មានជលផលត្រូវបានធ្វើការប្រៀប-ធៀបទៅនឹងទិន្នន័យឆ្នាំគោល២០១៩។ ព័ត៌មានត្រូវបានចែករំលែកជាមួយលេខាធិ- | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍នានា |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| | | | | | | | ការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិជារៀងរាល់ឆ្នាំ | |
| **២.២- ការផ្តល់សិទ្ធិដល់នាវានេសាទកម្ពុជាធ្វើនេសាទនៅក្នុងដែនសមុទ្រកម្ពុជា** | | | | | | | | |
| ២.២.១- បន្តប្រមូលទិន្នន័យនាវានេសាទសមុទ្រទាំងអស់ | ១២៥ ០០០ | ១២៥ ០០០ | | | | ២៥០ ០០០ | ទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រទាំងអស់ត្រូវបានបូកសរុបវិភាគនិងផ្សព្វផ្សាយ។ ទិន្នន័យត្រឹះថ្នាក់ជាតិត្រូវបានបង្កើតនិងគ្រប់គ្រង | រដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសមុទ្រទាំង៤ |
| ២.២.២- កសាងសមត្ថភាពក្នុងការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទទាំងអស់ | | ៥០ ០០០ | | | | ៥០ ០០០ | កម្មវិធីបណ្តុះបណ្តាលសមស្របត្រូវបានឯកភាពនិងគាំទ្រដល់ក្រសួងសាធារណការនិងដឹកជញ្ជូន និង រដ្ឋបាលជលផលដើម្បីចុះបញ្ជី និងផ្តល់សិទ្ធិដល់នាវានេសាទ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសាធារណការ និងដឹកជញ្ជូន |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| ២.២.៣- ជំរុញការចុះបញ្ជីនាវានេសាទខ្នាតមធ្យមនិងខ្នាតធំទាំងអស់ | ១៥០ ០០០ | ១៥០ ០០០ | | | | ៣០០ ០០០ | នាវានេសាទខ្នាតមធ្យមនិងធំត្រូវបានចុះបញ្ជីទាំងអស់ | រដ្ឋបាលជលផល និងក្រសួងសាធារណការ និងដឹកជញ្ជូន |
| ២.២.៤- ចេញលិខិតអនុញ្ញាតឱ្យនាវានេសាទខ្នាតមធ្យមនិងខ្នាតធំទាំងអស់ | ១៥០ ០០០ | ១៥០ ០០០ | | | | ៣០០ ០០០ | នាវានេសាទខ្នាតមធ្យមនិងធំត្រូវបានផ្តល់លិខិតអនុញ្ញាត | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.២.៥- ចុះកំណត់ត្រានិងចេញប័ណ្ណសម្គាល់ឱ្យនាវានេសាទខ្នាតតូចទាំងអស់ | ១០០ ០០០ | ១០០ ០០០ | | | | ២០០ ០០០ | នាវានេសាទខ្នាតតូចត្រូវបានកត់ត្រាក្នុងបញ្ជី | រដ្ឋបាលជលផល |
| ២.២.៦- កសាងសមត្ថភាពធនធានមនុស្ស និងស្ថាប័នសម្រាប់ការចុះបញ្ជីចេញលិខិតអនុញ្ញាតឬប័ណ្ណសម្គាល់ដល់នាវានេសាទតំបន់ឆ្នេរ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ២៥០ ០០០ | មន្ត្រីជលផលខេត្តត្រូវបានបណ្តុះបណ្តាលក្នុងការចុះបញ្ជីនិងចេញលិខិតអនុញ្ញាតនាវានេសាទ | រដ្ឋបាលជលផល និងក្រសួងសាធារណការ និងដឹកជញ្ជូន |
| ២.២.៧- ទំនាក់ទំនងជាមួយ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ ចំពោះនាវានេសាទដែលមានប្រវែងលើសពី២៤ម៉ែត្រ | | ៥០០០ | ៥០០០ | ៥០០០ | ៥០០០ | ២០ ០០០ | ទិន្នន័យនិងព័តមាននាវានេសាទដែលមានប្រវែងលើសពី២៤ម៉ែត្រត្រូវបានចែករំលែក | រដ្ឋបាលជលផល |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| | | | | | | | ជាមួយ បណ្ដាប្រទេសអាស៊ាន | |
| **២.៣- ការផ្ដល់សិទ្ធិដល់នាវាបរទេសក្នុងដែននេសាទសមុទ្រកម្ពុជា** | | | | | | | | |
| ២.៣.១- សហការជាមួយប្រទេសថៃ និងវៀតណាម និងមិនអនុញ្ញាតឱ្យនាវានេសាទថៃ និងវៀតណាមនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ប្រទេសកម្ពុជា | ២៥ ០០០ | ២៥ ០០០ | | | | ៥០ ០០០ | -កិច្ចសហការជាមួយប្រទេសថៃនិងវៀតណាមត្រូវបានពង្រឹង<br>-គ្មាននាវានេសាទថៃនិងវៀតណាមនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ប្រទេសកម្ពុជា | រដ្ឋបាលជលផល |
| ២.៣.២- ពិភាក្សាស្ដីពីវិធានការគ្រប់គ្រងនិងការនេសាទរួមគ្នានៅក្នុងតំបន់ទាមទារត្រួតគ្នាជាមួយថៃនិងវៀតណាម | | ២៥ ០០០ | ២៥ ០០០ | ២៥ ០០០ | ២៥ ០០០ | ១០០ ០០០ | កិច្ចព្រមព្រៀងស្ដីពីវិធានគ្រប់គ្រង និងអភិរក្សជលផលរួមគ្នាក្នុងតំបន់ទាមទារត្រួត-គ្នាដែលមានវិវាទត្រូវបានចុះហត្ថលេខា | រដ្ឋបាលជលផល និងក្រសួងសាធារណការ និងដឹកជញ្ជូន |
| **២.៤- រៀបចំវិធានការត្រួតពិនិត្យនាវាដឹកជញ្ជូននិងនាវាផ្គត់ផ្គង់ផ្សេងៗទៀត** | | | | | | | | |
| ២.៤.១- ជំរុញការចុះបញ្ជីនាវានិងយានយន្តដែលពាក់ព័ន្ធនឹងការដឹកជញ្ជូន និងការនាំចេញផល ផលិតផលជលផល | ៥០ ០០០ | ៥០ ០០០ | | | | ១០០ ០០០ | រាល់នាវានិងយានយន្តដែលមានការពាក់ព័ន្ធនឹងការដឹកជញ្ជូននិងនាំចេញផល ផលិតផលជលផលត្រូវបានចុះបញ្ជី | រដ្ឋបាលជលផល និងក្រសួងសាធារណការ និងដឹកជញ្ជូន |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| ២.៤.២- បន្តផ្តល់លិខិតអនុញ្ញាតឱ្យនាវា និងរថយន្តពាក់ព័ន្ធនឹងការដឹកជញ្ជូន និងការនាំចេញផល ផលិតផលជលផល | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ | ៥០០ ០០០ | រាល់នាវានិងយានយន្តដែលមានការពាក់ព័ន្ធនឹងការដឹកជញ្ជូននិងនាំចេញផល ផលិតផលជលផលត្រូវបានផ្តល់សិទ្ធិ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.៤.៣- សហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអាជ្ញាធរពាក់ព័ន្ធដើម្បីពង្រឹងប្រព័ន្ធត្រួត-ពិនិត្យនៃការដឹកជញ្ជូនផលនេសាទ | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ | ៥០០ ០០០ | ប្រព័ន្ធតាមដានត្រូវបានឯកភាពឱ្យប្រើប្រាស់ដើម្បីតាមដានការដឹកជញ្ជូនផលនេសាទ | រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងស្ថាប័នពាក់ព័ន្ធ |
| **២.៥- ការតាមដាន ត្រួតពិនិត្យ និងការអង្កេត** | | | | | | | | |
| ២.៥.១- បន្តរៀបចំនិងអនុវត្តផែនការជាតិក្នុងការត្រួតពិនិត្យនិងអធិការកិច្ច | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ២៥០ ០០០ | របាយការណ៍វាយតម្លៃលើតួនាទីនិងភារកិច្ចក្នុងការអនុវត្តផែនការជាតិក្នុងការត្រួតពិនិត្យនិងអធិការកិច្ច | រដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធ |
| ២.៥.២- បន្តបណ្តុះបណ្តាលការងារការតាមដានត្រួតពិនិត្យនិងអង្កេតដែលមានចែងនៅក្នុងផែនការជាតិត្រួតពិនិត្យនិងអធិការកិច្ច | ៣០ ០០០ | ៣០ ០០០ | ៣០ ០០០ | ៣០ ០០០ | ៣០ ០០០ | ១៥០ ០០០ | មន្ត្រីដែលបានបណ្តុះបណ្តាលបានអនុវត្តការតាមដានត្រួតពិនិត្យនិងអង្កេតជាក់ស្តែង | រដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធ |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| ២.៥.៣- ទិញ ជួសជុល និងថែរក្សានាវាល្បាត | ១ ៥០០ ០០០ | ១២៥ ០០០ | ១២៥ ០០០ | ១២៥ ០០០ | ១២៥ ០០០ | ២ ០០០ ០០០ | នាវាត្រួតពិនិត្យត្រូវបានកែលម្អនិងចុះប្រតិបត្តិការយ៉ាងពេញលេញ | រដ្ឋបាលជលផល |
| ២.៥.៤- រៀបចំកម្មវិធីដើម្បីចាប់ផ្តើមការងារក្រុមអង្កេតការ | ១០ ០០០ | | | | | ១០ ០០០ | ក្រុមអង្កេតការត្រូវបានបណ្តុះបណ្តាល | រដ្ឋបាលជលផល |
| ២.៥.៥- បណ្តុះបណ្តាលនិងផ្តល់សៀវភៅកត់ត្រាស្ថិតិផលនេសាទសម្រាប់នាវានេសាទខ្នាតធំនិងខ្នាតមធ្យម | ១០ ០០០ | ៣៥ ០០០ | ៣៥ ០០០ | ៣៥ ០០០ | ៣៥ ០០០ | ១៥០ ០០០ | សៀវភៅកត់ត្រាស្ថិតិផលនេសាទត្រូវបានដាក់ឱ្យប្រើប្រាស់ហើយរបៀបប្រើប្រាស់ត្រូវបានបណ្តុះបណ្តាលដល់អ្នក | រដ្ឋបាលជលផលនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.៥.៦- សិក្សា ពិនិត្យ និងជ្រើសរើសឧបករណ៍តាមដានសបស្រួបដើម្បីដំឡើងប្រព័ន្ធតាមដានក្នុងនាវានេសាទខ្នាតមធ្យមនិងខ្នាតធំ | ៥០ ០០០ | | | | | ៥០ ០០០ | ប្រព័ន្ធនិងឧបករណ៍តាមដានសមស្របត្រូវបានជ្រើសរើសសម្រាប់ប្រើក្នុងនាវានេសាទខ្នាតមធ្យម និងខ្នាតធំ | រដ្ឋបាលជលផល |
| ២.៥.៧- ដំឡើងប្រព័ន្ធតាមដានសម្រាប់នាវានេសាទខ្នាតមធ្យមនិងធំ | | ៥០ ០០០ | | | | ៥០ ០០០ | ការិយាល័យតាមដាននាវានេសាទខ្នាតមធ្យមនិងធំត្រូវបានបង្កើតឡើងនិងដំណើរការការងារនៅក្នុងរដ្ឋបាលជលផល | រដ្ឋបាលជលផល |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| **៣- ការទទួលខុសត្រូវរបស់កម្ពុជា ក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិ** | | | | | | | | |
| ៣.១- ការចុះបញ្ជីនិងកត់ត្រានាវានេសាទ នៅក្នុងដែននេសាទសមុទ្ររបស់រដ្ឋដទៃឬនៅសមុទ្រអន្តរជាតិ | | | | | | | | |
| ៣.១.១- សហការវិភាគតម្លៃដាក់ទុននិងផលចំណេញ(ប្រសិទ្ធភាពសេដ្ឋកិច្ច) សម្រាប់ការបើកឱ្យមានការចុះបញ្ជីនាវានេសាទបរទេសឡើងវិញដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | ៥០ ០០០ | ៥០ ០០០ | | | | ១០០ ០០០ | របាយការណ៍លទ្ធផលការវិភាគនិងវាយតម្លៃការដាក់ទុននិងផលចំណេញត្រូវបានរៀបចំនិងចែកចាយ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣.១.២- រៀបចំប្រព័ន្ធចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទដែលបំពាក់ទង់ជាតិកម្ពុជានេសាទក្នុងរដ្ឋដទៃ ឬនៅសមុទ្រអន្តរជាតិ | ២៥ ០០០ | ២៥ ០០០ | | | | ៥០ ០០០ | ការចុះបញ្ជីជាសាធារណៈដល់នាវានេសាទដោតទង់ជាតិកម្ពុជា | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣.២- ការផ្តល់សិទ្ធិឱ្យនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃនិងក្នុងសមុទ្រអន្តរជាតិ | | | | | | | | |
| ៣.២.១- រៀបចំយន្តការនៃការផ្តល់សិទ្ធិឱ្យនាវានេសាទមិនមែនជាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលបំពាក់ទង់ជាតិកម្ពុជា នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃ ឬនៅក្នុងសមុទ្រ អន្តរជាតិ រួមទាំងវិធានការណ៍ត្រួតពិនិត្យ និងអធិការកិច្ចដ៏មានប្រសិទ្ធភាព | ១៥ ០០០ | ១៥ ០០០ | ១៥ ០០០ | ១៥ ០០០ | ១៥ ០០០ | ៧៥ ០០០ | នីតិវិធីប្រកបដោយតម្លាភាពត្រូវបានឯកភាពសម្រាប់ផ្តល់សិទ្ធិដល់នាវានេសាទស្របច្បាប់ដែលដោតទង់ជាតិកម្ពុជានេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃឬក្នុងសមុទ្រអន្តរជាតិ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| **៣.៣- វិធានការត្រួតពិនិត្យនាវាពាក់ព័ន្ធនឹងការនេសាទ** | | | | | | | | |
| ៣.៣.១- បង្កើតប្រព័ន្ធចុះបញ្ជីផ្តល់លិខិតអនុញ្ញាតនិងកត់ត្រានាវានេសាទ ដឹកជញ្ជូននិងនាវាផ្គត់ផ្គង់កម្ពុជានៅក្នុងដែននេសាទ សមុទ្ររដ្ឋដទៃ និងសមុទ្រអន្តរជាតិ | | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | | ១៥០ ០០០ | ប្រព័ន្ធចុះបញ្ជីជាសាធារណៈរបស់នាវានេសាទដោតទង់ជាតិកម្ពុជាត្រូវបានបង្កើត | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| **៤- វិធានការរដ្ឋម្ចាស់កំពង់ផែកម្ពុជា** | | | | | | | | |
| **៤.១ ការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ** | | | | | | | | |
| ៤.១.១- កំណត់កំពង់ផែឬកន្លែងឡើងផលនេសាទផ្លូវការសម្រាប់នាវាបរទេស | ៣០ ០០០ | | | | | ៣០ ០០០ | ផ្សព្វផ្សាយជាសាធារណៈនូវទីតាំងកន្លែងឡើងផលនេសាទឬកំពង់ផែសម្រាប់នាវានេសាទបរទេស | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤.១.២- បង្ហាញឬផ្សព្វផ្សាយកន្លែងឡើងផលនេសាទឬកំពង់ផែនេសាទ សម្រាប់ធ្វើអធិការកិច្ច ចំពោះនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតរបស់បរទេស | ២៥ ០០០ | ២៥ ០០០ | | | | ៥០ ០០០ | សៀវភៅស្តីពីនីតិវិធីណែនាំកន្លែងឡើងផលនេសាទឬកំពង់ផែនេសាទសម្រាប់ធ្វើអធិការកិច្ច ចំពោះនាវានេសាទខុសច្បាប់របស់បរទេស ត្រូវបានរៀបចំ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| **៤.២- នីតិវិធីចំពោះនាវាបរទេសដែលបានរកឃើញថា ជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត** | | | | | | | | |
| ៤.២.១- បង្កើតនិងអនុវត្តនីតិវិធីចំពោះនាវាបរទេសដែលរកឃើញថាបាននេសាទខុសច្បាប់ គ្មានរបាយការណ៍និងគ្មានការអនុញ្ញាត | ២៥ ០០០ | ២៥ ០០០ | | | | ៥០ ០០០ | សៀវភៅស្តីពីនីតិវិធីណែនាំសម្រាប់នាវាបរទេសដែលត្រូវបានរកឃើញថាជានាវានេសាទខុសច្បាប់ ត្រូវបានបង្កើត និងអនុវត្ត | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **៤.៣- កិច្ចសហប្រតិបត្តិការជាមួយរដ្ឋម្ចាស់កំពង់ផែឬអង្គការគ្រប់គ្រងជលផលសមុទ្រពាក់ព័ន្ធ** | | | | | | | | |
| ៤.៣.១- សហការជាមួយរដ្ឋម្ចាស់ឆ្នេរ រដ្ឋម្ចាស់កំពង់ផែនិងរដ្ឋពាក់ព័ន្ធនានា ព្រមទាំងអង្គការគ្រប់គ្រងជលផលសមុទ្រពាក់ព័ន្ធនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ១០០ ០០០ | បណ្តាញព័ត៌មានស្តីពីនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតត្រូវបានបង្កើតឡើងនិងព័ត៌មានត្រូវបានចែករំលែក | រដ្ឋបាលជលផល និងរដ្ឋពាក់ព័ន្ធនានា |
| ៤.៣.២- ចែករំលែកព័ត៌មានស្តីពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងការតាមដានត្រួតពិនិត្យ និងអង្កេត | ១៥ ០០០ | ១៥ ០០០ | ១៥ ០០០ | ១៥ ០០០ | ១៥ ០០០ | ៧៥ ០០០ | បណ្តាញព័ត៌មានស្តីពីនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍និងគ្មានការអនុញ្ញាតត្រូវបានបង្កើតឡើងនិងព័ត៌មានត្រូវបានចែករំលែកនៅក្នុងឈូងសមុទ្រថៃ | រដ្ឋបាលជលផល និងលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| **៥- វិធានការទាក់ទងនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ** | | | | | | | | |
| ៥.១- ប្រព័ន្ធឯកសារគ្រប់គ្រងផលនេសាទ | | | | | | | | |
| ៥.១.១- អនុម័តនិងសាកល្បងប្រើប្រព័ន្ធឯកសារផលនេសាទអាស៊ាន និងលេខាធិការដ្ឋានអភិវឌ្ឍន៍ផលផលតំបន់អាស៊ីអាគ្នេយ៍ | | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ២០០ ០០០ | ប្រព័ន្ធឯកសារផលចាប់របស់អាស៊ានលេខាលេធិការដ្ឋានអភិវឌ្ឍន៍ផលផលនៃតំបន់អាស៊ីអាគ្នេយ៍ត្រូវបានកែសម្រួលសម្រាប់ប្រើក្នុងបរិបទកម្ពុជា | រដ្ឋបាលជលផល |
| ៥.២.១- កសាងសមត្ថភាពក្នុងការកត់ត្រាស្ថិតិផលនេសាទនិងផ្ទៀងផ្ទាត់លិខិតអនុញ្ញាតជាមួយប្រទេសនានា | | | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ | ក្រុមការងារត្រូវបានបណ្តុះបណ្តាលនិងអនុវត្តការងារប្រកបដោយវិជ្ជាជីវៈនិងមានប្រសិទ្ធភាពខ្ពស់ | រដ្ឋបាលជលផល |
| **៦- កិច្ចសហប្រតិបត្តិការជាមួយ អង្គការគ្រប់គ្រងជលផលសមុទ្រ និងប្រទេសផ្សេងទៀត ដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត** | | | | | | | | |
| ៦.១- ការប្រតិបត្តិចំពោះប្រទេសដែលមិនមែនជាសមាជិក | | | | | | | | |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| ៦.១.១- បន្តផ្តល់ព័ត៌មានដល់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់អំពីនាវានេសាទដោតទង់ជាតិកម្ពុជានៅក្នុងសមុទ្រអន្តរជាតិនិងក្នុងតំបន់របស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | | ១០ ០០០ | ១០ ០០០ | ១០ ០០០ | ១០ ០០០ | ៤០ ០០០ | បណ្តាញព័ត៌មានស្តីពីនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍និងគ្មានការអនុញ្ញាតត្រូវបានបង្កើតឡើងនិងព័ត៌-មានត្រូវបានចែករំលែក | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **៧- លក្ខខណ្ឌតម្រូវពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ** | | | | | | | | |
| **៧.១- ការកសាងសមត្ថភាពនៅក្នុងបណ្តាប្រទេសអាស៊ាន** | | | | | | | | |
| ៧.១.១- បន្តកិច្ចសហការជាមួយអាស៊ានលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ១០០ ០០០ | មន្ត្រីដែលបានបណ្តុះបណ្តាលបានអនុវត្តការតាមដានត្រួតពិនិត្យនិងអង្កេតប្រកបដោយវិជ្ជាជីវៈនិងមានប្រសិទ្ធភាពខ្ពស់ | រដ្ឋបាលជលផល លេខាធិការដ្ឋានអាស៊ានលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍និងអង្គការស្បៀង និងកសិកម្មនៃសហ-ប្រជាជាតិ |
| **៨- ការរាយការណ៍** | | | | | | | | |
| ៨.១- លក្ខខណ្ឌក្នុងការរាយការណ៍ | | | | | | | | |

| សកម្មភាព | ថវិកាគ្រោងតាមឆ្នាំ (ដុល្លារសហរដ្ឋអាមេរិក) | | | | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| ៨.១.១- រៀបចំផែនការនិងអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងថវិកាសម្រាប់អនុវត្តប្រចាំឆ្នាំ | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ៥ ០០០ | **២៥ ០០០** | ផែនការនិងថវិកាអនុវត្តប្រចាំឆ្នាំត្រូវបានរៀបចំ និងអនុម័ត | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៨.១.២- រាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្ត ផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ៥ ០០០ | **២៥ ០០០** | របាយការណ៍អនុវត្តប្រចាំឆ្នាំត្រូវបានរៀបចំ និងអនុម័ត | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៨.១.៣- រាយការណ៍ទៅកាន់ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ រៀងរាល់ពីរឆ្នាំម្តង | | ១០ ០០០ | | ១០ ០០០ | | **២០ ០០០** | របាយការណ៍អនុវត្តប្រចាំឆ្នាំត្រូវបានរៀបចំ និងអនុម័ត និងរាយការណ៍ទៅកាន់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិរៀងរាល់ពីរឆ្នាំម្តង | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

## ៥- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីអនុវត្តផែនការសកម្មភាពជាតិស្ដីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការពិនិត្យឡើងវិញ និងសំណើកែលម្អការអនុវត្តដោយផ្ដោតលើៈ

- ពេលវេលានៃការអនុវត្ត
- សូចនាករនៃផែនការសកម្មភាពជាតិ
- ការចូលរួមអនុវត្តផែនការសកម្មភាពរបស់អ្នកពាក់ព័ន្ធ
- លទ្ធផលទទួលបានធៀបនឹងចំណុចដៅ
- ផលប្រយោជន៍ដែលទទួលបានពីការអនុវត្តផែនការសកម្មភាពជាតិ។

## ៦- សេចក្ដីសន្និដ្ឋាន

ការអនុវត្តបានជោគជ័យនូវផែនការសកម្មភាពជាតិស្ដីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត នឹងធ្វើឱ្យកម្ពុជាទទួលបាននូវការធ្វើនេសាទប្រកបដោយការទទួលខុសត្រូវនិងមាននិរន្តរភាពក្នុងដែនសមុទ្រកម្ពុជា ព្រមទាំងបានធ្វើសមាហរណកម្មជាមួយការគ្រប់គ្រងសមុទ្រអន្តរជាតិដែលធ្វើឱ្យកម្ពុជាមានទំនុកចិត្តនិងភាពជឿជាក់ឡើងវិញលើឆាកអន្តរជាតិ។ លទ្ធផលនៃការអនុវត្តផែនការសកម្មភាពជាតិខាងលើ បានធ្វើឱ្យប្រសើរឡើងនូវជីវភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងបង្កើនសន្តិសុខស្បៀង។ ម្យ៉ាងវិញទៀត ការអនុវត្តសកម្មភាពទាំងនេះ សបញ្ជាក់ពីការចូលរួមចំណែករបស់កម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងនិងអភិរក្សធនធានជលផល ទាំងថ្នាក់ជាតិនិងអន្តរជាតិ ព្រមទាំងចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់ដល់និរន្តរភាពយូរអង្វែងនៃធនធានជលផលពិភពលោក។ បន្ថែមពីលើនេះទៀត បានជួយបង្កើនឱកាសសង្គមនិងសេដ្ឋកិច្ចក្នុងរយៈពេលខ្លីនិងវែង តាមរយៈការបង្កើនប្រាក់ចំណូលពីការនេសាទស្របច្បាប់សម្រាប់សហគមន៍តំបន់ឆ្នេរ សេដ្ឋកិច្ចរដ្ឋតំបន់ឆ្នេរ សេដ្ឋកិច្ចពិភពលោក និងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថានសមុទ្រកម្ពុជានិងសមុទ្រអន្តរជាតិ។ តាមរយៈការអនុវត្តផែនការសកម្មភាពជាតិ កម្ពុជានឹងទទួលបានកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញពីបណ្ដាប្រទេសនានាក្នុងតំបន់និងលើសកលលោកក្នុងការគាំទ្រផ្នែកបច្ចេកទេសនិងថវិកា ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

**ឧបសម្ព័ន្ធ១: ការចុះបញ្ជីនាវា និងការផ្តល់លិខិតអនុញ្ញាតនាពេលបច្ចុប្បន្ន**

**ក- ការចុះបញ្ជីនាវា**

ការចុះបញ្ជីនាវានេសាទ ផ្តល់ដោយមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី/ខេត្តឬនាយកដ្ឋាននាវាជំនួញសមុទ្រ។

ដំណើរការនៃការចុះបញ្ជីនាវានេសាទរួមមានៈ

១- ដាក់ពាក្យស្នើសុំចុះបញ្ជីនាវាដោយមានឯកសារពាក់ព័ន្ធភ្ជាប់ជាមួយ។

២- ការពិនិត្យនិងផ្ទៀងផ្ទាត់ឯកសារ។

៣- ការពិនិត្យលក្ខណៈបច្ចេកទេសនាវា មានដូចជា ទម្ងន់ផ្ទុក ម៉ាស៊ីន ទំហំនាវា។ល។

៤- ការផ្តល់ប័ណ្ណសម្គាល់នាវានិងស្លាកលេខ។

**ខ- ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ**

ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទនិងប្រើនាវានេសាទផ្តល់ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី/ខេត្តឬរដ្ឋបាលជលផល។

ដំណើរការនៃការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ និងប្រើនាវានេសាទ រួមមានៈ

១- ពាក្យស្នើសុំធ្វើអាជីវកម្មនេសាទនិងប្រើនាវានេសាទ ដោយមានឯកសារពាក់ព័ន្ធភ្ជាប់ជាមួយ។

២- បំពេញលក្ខខណ្ឌបច្ចេកទេសនាវានេសាទនិងលក្ខខណ្ឌនៃការធ្វើនេសាទ។

៣- ការពិនិត្យនិងផ្ទៀងផ្ទាត់ឯកសារ។

៤- ការពិនិត្យលក្ខណៈបច្ចេកទេសនាវានិងឧបករណ៍នេសាទ។

៥- ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទនិងប្រើនាវានេសាទ។

ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទនិងប្រើនាវានេសាទ ចែកចេញជាពីរៈ

- នាវានេសាទដែលមានកម្លាំងចាប់ពី៥០សេះឡើង ផ្តល់ដោយរដ្ឋបាលជលផល
- នាវានេសាទដែលមានកម្លាំងក្រោម៥០សេះផ្តល់ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសាមី។

គំរូពាក្យស្នើសុំរួមមានៈ

- ឈ្មោះ ភេទ អាយុ សញ្ជាតិ អាសយដ្ឋាន មុខរបររបស់ម្ចាស់នាវា
- ប្រភេទនាវា លេខចុះបញ្ជី/ស្លាកលេខ
- ព័ត៌មានអំពីនាវា(ទម្ងន់ផ្ទុកសរុប ម៉ាស៊ីន កម្លាំងសេះ ប្លង់ បណ្តោយ ទទឹង ជម្រៅ)
- ប្រភេទឧបករណ៍នេសាទ
- តំបន់នេសាទ
- សុពលភាពលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ។

ក្រោយពីបានពិនិត្យលើពាក្យស្នើសុំរបស់ម្ចាស់នាវានេសាទ ក្រុមការងារបច្ចេកទេសរដ្ឋបាលជលផលចុះពិនិត្យនាវានេសាទនិងឧបករណ៍នេសាទ មុននឹងផ្តល់លិខិតអនុញ្ញាត។

* លក្ខខណ្ឌបច្ចេកទេសនាវានេសាទ:

- ដោតទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ស្លាកលេខសម្គាល់នាវា ភ្លើងសញ្ញា សញ្ញាសម្គាល់
- វិទ្យុទាក់ទង ឧបករណ៍ពន្លត់អគ្គីភ័យ ពោងសង្គ្រោះ អាវពោង កៃវយឹត ត្រីវិស័យឬGPS ថ្នាំពេទ្យសម្រាប់សង្គ្រោះបឋម ភ្លើងម្រាប់មើលផ្លូវ ភ្លើងសញ្ញាប្រកាសអាសន្ន ស៊ីផ្លេឬជួងឬកណ្តឹង
- សំបកនិងម៉ាស៊ីននាវានេសាទដែលមានគុណភាព និងសុវត្ថិភាពក្នុងការធ្វើអាជីវកម្មនេសាទ
- ធុងសម្រាប់ផ្ទុករាល់កាកសំណល់នៅលើនាវានេសាទនិងប្រេងដែលបានប្តូរចេញពីម៉ាស៊ីនឱ្យបានត្រឹមត្រូវយកទៅចោលនៅទីកន្លែងដែលបានកំណត់
- លាបពណ៌សម្គាល់នៅលើគែមនាវានេសាទតាមរាជធានី ខេត្ត។ ឧទាហរណ៍ ខេត្តកំពតត្រូវលាបពណ៌ក្រហម រីឯខេត្តព្រះសីហនុលាបពណ៌លឿង។ល។

## ឧបសម្ព័ន្ធ២

## សកម្មភាពជាក់លាក់សម្រាប់អនុវត្តរយៈពេល៣ឆ្នាំ នៃផែនការសកម្មភាពស្ដីពីការបង្ការ ទប់ស្កាត់ និងការលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និង គ្មានការអនុញ្ញាត ក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ២០២០-២០២២

### ១- សេចក្ដីផ្ដើម

វិស័យជលផល ដើរតួនាទីយ៉ាងសំខាន់ចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាតាំងពីយូរលង់ ហើយបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសផ្ដល់នូវសន្តិសុខស្បៀង អាហារូបត្ថម្ភ កាត់បន្ថយភាពក្រីក្រ បង្កើតការងារ ធ្វើឱ្យមានសមភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ច តុល្យភាពរូបិយបណ្ណបរទេស និងការការពារបេតិកភណ្ឌធម្មជាតិទៀតផងដែរ។ ត្រីផ្ដល់នូវសារជាតិប្រូតេអ៊ីនប្រមាណជាង៨០ភាគរយ ដែលបានមកពីសាច់សត្វក្នុងរបបអាហារប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា។ បច្ចុប្បន្នផលិតផលជលផលសរុបទូទាំងប្រទេសទាំងទឹកសាបនិងទឹកប្រៃ មានតម្លៃប្រមាណពី២០០-៣០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ(តម្លៃគិតនៅកន្លែងឡើងផលនេសាទ)ដែលបានរួមចំណែកប្រមាណ៦-៨ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ដោយឡែកនៅឆ្នាំ២០១៧ ផលនេសាទសមុទ្រទទួលបានប្រមាណជាង១២០ ០០០តោនក្នុងមួយឆ្នាំស្មើនឹង២០ភាគរយនៃផលនេសាទសរុបទូទាំងប្រទេស ដែលទិន្នផលនេះមានការកើនឡើងជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០០៨មក។

ទោះបីជាវិស័យជលផលមានសារៈសំខាន់យ៉ាងនេះក៏ដោយ ក៏ការគ្រប់គ្រងនិងអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃជលផលសមុទ្រត្រូវបានគំរាមកំហែងដោយបញ្ហាមួយចំនួនរួមមាន ការនេសាទហួសកម្រិត ចំនួនទូកនេសាទលើសសមត្ថភាពធៀបនឹងផលចាប់ ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ការអភិវឌ្ឍតាមតំបន់ឆ្នេរ ការបាត់បង់ទីជម្រក ការខ្វះធនធាននិងមធ្យោបាយក្នុងការអនុវត្តសកម្មភាពសម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព។ កត្តាទាំងនេះបណ្ដាលឱ្យអ្នកនេសាទគ្រួសារនិងខ្នាតតូចងាយរងគ្រោះដោយផលប៉ះពាល់អវិជ្ជមានពីបញ្ហាទាំងនេះ។ ដើម្បីផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋ មានការងារជាច្រើនត្រូវដោះស្រាយជាបន្ទាន់ក្នុងវិស័យជលផលសមុទ្រនៃប្រទេសកម្ពុជា ក្នុងគោលដៅបង្កើនសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដំណោះស្រាយជាចម្បងរួមមានការកែលម្អ និងបំពេញបន្ថែមលិខិតុបករណ៍ពាក់ព័ន្ធនឹងវិស័យជលផល ពង្រឹងអភិបាលកិច្ចជលផល ពង្រឹងការទទួលខុសត្រូវរបស់រដ្ឋម្ចាស់ឆ្នេរ រដ្ឋម្ចាស់ទង់ជាតិនិងរដ្ឋម្ចាស់កំពង់ផែ វិធានការទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ សហគមន៍អន្តរជាតិ និងប្រទេសដទៃទៀតក្នុងការលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ ផែនការសកម្មភាពលម្អិតដែលទាក់ទងនឹងដំណោះស្រាយដូចបានរៀបរាប់ខាងលើមានដូចក្នុងចំណុច២ខាងក្រោម។

### ២- ផែនការសកម្មភាព

### ក- សកម្មភាពអាទិភាព សូចនាករសំខាន់ៗ និងស្ថាប័នអនុវត្ត

ផែនការសកម្មភាពជាតិស្ដីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទសមុទ្រខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត កម្ពុជាបានដាក់ចេញនូវសកម្មភាពជាច្រើនដែលត្រូវអនុវត្តក្នុងរយៈពេល៣ឆ្នាំ(២០២០-

២០២៤) ដើម្បីទប់ស្កាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ ក្នុងនោះ ផែនការរំកិល៣ឆ្នាំ (២០២០-២០២២) ត្រូវបានដកស្រង់ចេញនូវសកម្មភាពអាទិភាពបំផុតពីផែនការសកម្មភាពជាតិ៥ឆ្នាំខាងលើ ដែលចាប់ផ្តើមពីឆ្នាំ២០២០ ដោយបានបញ្ជាក់លម្អិតអំពីសកម្មភាព សូចនាករ ពេលវេលា ស្ថាប័ន អនុវត្តវិធីសាស្ត្រក្នុងការអនុវត្តសកម្មភាពនិងថវិកា។

សកម្មភាពអាទិភាពលម្អិត សូចនាករសំខាន់ៗ ពេលវេលា ថវិកា និងស្ថាប័នអនុវត្តនៃផែនការ៣ឆ្នាំរំកិលស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត(២០២០-២០២២) មានជូនភ្ជាប់ក្នុងតារាងទី១ និងតារាងទី២។

ការអនុវត្តផែនការនិងការសម្រេចបាននូវសូចនាករសំខាន់ៗនៃផែនការសកម្មភាពជាតិស្តីពី ការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត គឺផ្អែកលើការផ្តល់ថវិកាដែលអាចនឹងទទួលបានតាមរយៈកម្មវិធីកម្ពុជាសម្រាប់អភិវឌ្ឍន៍វិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ន្នសមាសភាគការនេសាទពីមូលនិធិសហភាពអឺរ៉ុប។ ប្រសិនបើមូលនិធិនេះមិនមានទេ សកម្មភាពមួយចំនួននឹងត្រូវលើកយកទៅអនុវត្តនៅឆ្នាំបន្តបន្ទាប់។

## ខ- ផែនការសកម្មភាពអាទិភាពលម្អិត៣ឆ្នាំរំកិល

កំណត់សម្គាល់ ផែនការសកម្មភាព៣ឆ្នាំរំកិលខាងក្រោមនេះ បានដាក់លេខរៀងសកម្មភាពតាមលំដាប់អាទិភាពនៃផែនការសកម្មភាពជាតិ៥ឆ្នាំ ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដោយចាប់ផ្តើមពីចំណុចទី៣ ដូចខាងក្រោមៈ

### ១- ការទទួលខុសត្រូវរបស់រដ្ឋ

### ១.១- ការផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិសំខាន់ៗ

១.១.១- សកម្មភាព : បន្តរៀបចំបែបបទលិខិតរដ្ឋបាលក្នុងការស្នើសុំចូលជារដ្ឋសមាជិកនៃវិធានការរដ្ឋម្ចាស់កំពង់ផែនៃកិច្ចព្រមព្រៀងរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : រៀបចំលិខិតស្នាមពាក់ព័ន្ធនៃវិធានការរដ្ឋម្ចាស់កំពង់ផែដើម្បីគាំទ្រដល់ការចូលជាសមាជិក

ពេលវេលា : ឆ្នាំ ២០២០

ថវិកា : ៦០ ០០០ដុល្លារ (ថវិកាជាតិ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍នានា)

១.១.២- សកម្មភាព : បន្តរៀបចំស្នើសុំការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអង្គការសហប្រជាជាតិស្តីពីផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា ស្ថាប័ននីតិប្បញ្ញត្តិ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : ព្រះរាជាណាចក្រកម្ពុជានឹងអនុម័តនិងផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងអង្គការសហប្រជាជាតិស្តីពីផលស្តុកត្រី និងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីគាំទ្រដល់ការចូលជាសមាជិក

ពេលវេលា : ឆ្នាំ២០២០

ថវិកា : ១០ ០០០ដុល្លារ (ថវិកាជាតិ)។

**១.២- ការពង្រឹងក្របខ័ណ្ឌច្បាប់ជាតិ**

១.២.១- លិខិតុបករណ៍ផ្សេងៗ

១.២.១.១- សកម្មភាព : បន្តពិនិត្យកែសម្រួលសេចក្តីព្រាង និងអនុម័តវិសោធនកម្មច្បាប់ស្តីពីជលផល និងអនុក្រឹត្យស្តីពីជលផលសមុទ្រ និងការនេសាទនៅសមុទ្រក្រៅ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : ការងារស្ថិតក្រោមជំនួយបច្ចេកទេសរបស់ជំនាញការបរទេស

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ២០០ ០០០ដុល្លារ (ថវិកាជាតិ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍នានា)។

១.២.១.២- សកម្មភាព : អនុម័តវិសោធនកម្មច្បាប់ស្តីពីជលផល និងអនុក្រឹត្យស្តីពីជលផលសមុទ្រ និងការនេសាទនៅសមុទ្រក្រៅ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : -តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ទីស្តីការគណៈរដ្ឋមន្ត្រី បញ្ជូនទៅរដ្ឋសភា ព្រឹទ្ធសភា ដើម្បីអនុម័តក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល
-តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីសម្រេចអនុក្រឹត្យស្តីពីជលផលសមុទ្រនិងការធ្វើនេសាទនៅសមុទ្រក្រៅក្នុងការសម្រេចអនុក្រឹត្យពាក់ព័ន្ធ

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ១០ ០០០ដុល្លារ (ថវិកាជាតិ)។

១.២.៣- ទោសប្បញ្ញត្តិ

១.២.៣.១- សកម្មភាព : បន្តកែសម្រួលទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីជលផលឡើងវិញ ដោយជាក់ការដោះពិន័យឱ្យមានប្រសិទ្ធភាព

ស្ថាប័នអនុវត្ត : អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា

នីតិវិធី : ពិនិត្យលើជំពូកទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីជលផល ដើម្បីឱ្យសមស្របជាមួយទោសប្បញ្ញត្តិនៃប្រទេសក្នុងតំបន់អាស៊ាន

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ២០ ០០០ដុល្លារ (ថវិកាជាតិ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

១.២.៥- សហប្រតិបត្តិការរវាងរដ្ឋនានា

១.២.៥.១- សកម្មភាព : បន្តរៀបចំនិងអនុវត្តកិច្ចព្រមព្រៀងជាមួយប្រទេសថៃ និងវៀតណាមដែលបានឯកភាពគ្នានៅក្នុងអនុស្សរណៈយោគយល់

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ ទីស្តីការគណៈរដ្ឋមន្ត្រី

នីតិវិធី : តាមរយៈយន្តការដែលមានស្រាប់ដែលបានរៀបចំឡើងដោយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងតាមរយៈកិច្ចសហប្រតិបត្តិការដោយផ្ទាល់របស់មន្ត្រីជាន់ខ្ពស់ ត្រូវសហការជាមួយប្រទេសជិតខាងដើម្បីឆ្លើយតបទៅនឹងបញ្ហារួមគ្នា

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ២០ ០០០ដុល្លារ/ឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

## ២- ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ផ្ទែរ

## ២.១- ការលើកកម្ពស់ការគ្រប់គ្រងធនធានជលផលសមុទ្រ

២.១.២- សកម្មភាព : រៀបចំនិងអនុម័តផែនការជាតិគ្រប់គ្រងជលផលសមុទ្រដែលមានលក្ខណៈទូលំទូលាយ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល សហគមន៍នេសាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ អង្គការសង្គមស៊ីវិល កម្មវិធីសហភាពអឺរ៉ុប ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា

នីតិវិធី : អ្នកជំនាញការជាន់ខ្ពស់សម្របសម្រួលដំណើរការរៀបចំផែនការដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ១០០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

២.១.៣- សកម្មភាព : កែលម្អប្រព័ន្ធប្រមូលទិន្នន័យនិងព័ត៌មាននៅតាមផែនេសាទ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : ពិនិត្យឡើងវិញ កំណត់ភាពខ្វះខាត និងផ្ដល់អនុសាសន៍ក្នុងការធ្វើឱ្យប្រសើរឡើង នូវប្រព័ន្ធប្រមូលទិន្នន័យ

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ១០០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

២.១.៤- សកម្មភាព : កែលម្អប្រព័ន្ធព័ត៌មានជលផល សម្រាប់ការគ្រប់គ្រងជលផល និងអ្នកធ្វើគោល-នយោបាយ និងចែករំលែកព័ត៌មានទាំងនោះ ជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : លើកកម្ពស់បច្ចេកវិទ្យានិងកសាងធនធានមនុស្ស ពង្រឹងការប្រមូលទិន្នន័យតាមផែនេសាទ រៀបចំប្រព័ន្ធព័ត៌មាន ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញសម្រាប់ឆ្នាំ២០១៩។ រៀបចំប្រព័ន្ធព័ត៌មានសម្រាប់ចែករំលែកជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ២០០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

២.១.៥- សកម្មភាព : ពង្រឹងប្រព័ន្ធប្រមូលនិងវិភាគទិន្នន័យព័ត៌មានជលផលនិងចែករំលែកជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : បន្តការលើកកម្ពស់បច្ចេកវិទ្យានិងការកសាងធនធានមនុស្សគឺ ត្រូវពង្រឹងការប្រមូលទិន្នន័យតាមផែនេសាទ រៀបចំប្រព័ន្ធព័ត៌មានដោយផ្អែកលើការត្រួតពិនិត្យឡើងវិញសម្រាប់ឆ្នាំ២០១៩ និងបន្តចាប់ពីឆ្នាំ២០២០ទៅ

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ៥០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

**២.២- ការផ្ដល់សិទ្ធិដល់នាវានេសាទកម្ពុជាធ្វើនេសាទនៅក្នុងដែនសមុទ្ររបស់កម្ពុជា**

២.២.១- សកម្មភាព : បន្តប្រមូលទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រទាំងអស់

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ និង អាជ្ញាធរមូលដ្ឋាន

នីតិវិធី : ធ្វើជំរឿននាវានេសាទសមុទ្រផ្អែកតាមបញ្ជីសំណួរនិងធ្វើការវិភាគលទ្ធផលព្រមទាំងផ្តួចផ្តើមដំណើរការចុះបញ្ជីនិងលិខិតអនុញ្ញាតនាវានេសាទខ្នាតមធ្យមនិងខ្នាតធំ

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ២៥០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)

២.២.២- សកម្មភាព : កសាងសមត្ថភាពក្នុងការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទសមុទ្រទាំងអស់

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តតំបន់ឆ្នេរ និងដៃគូអភិវឌ្ឍន៍នានា

នីតិវិធី : ស្រាវជ្រាវវិធីសាស្ត្រសំខាន់ៗ ក្នុងដំណើរការសិក្សាអំពីនាវានេសាទដើម្បីពង្រឹងសមត្ថភាពមន្ត្រីជលផលក្នុងការចុះបញ្ជីនិងចេញលិខិតអនុញ្ញាតនាវានេសាទ

ពេលវេលា : ឆ្នាំ២០២០

ថវិកា : ៥០ ០០០ដុល្លារ (ថវិកាជាតិ)។

២.២.៣- សកម្មភាព : ជំរុញការចុះបញ្ជីនាវានេសាទខ្នាតមធ្យមនិងខ្នាតធំទាំងអស់

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តតំបន់ឆ្នេរ និងដៃគូអភិវឌ្ឍន៍នានា

នីតិវិធី : ដោយមានកិច្ចសហការពីរដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីនិងផ្តល់ស្លាកលេខនាវានេសាទខ្នាតមធ្យមនិងខ្នាតធំ។ ព័ត៌មានការចុះបញ្ជីនេះត្រូវរក្សាទុកក្នុងមូលដ្ឋានទិន្នន័យនាវានេសាទ

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ៣០០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

២.២.៤- សកម្មភាព : ចេញលិខិតអនុញ្ញាតដល់នាវានេសាទខ្នាតមធ្យមនិងធំទាំងអស់

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រនិងកំពង់ផែ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តតំបន់ឆ្នេរ និងដៃគូអភិវឌ្ឍនានា

នីតិវិធី : រដ្ឋបាលជលផលផ្តល់លិខិតអនុញ្ញាតធ្វើនេសាទដល់នាវានេសាទខ្នាតមធ្យមនិងខ្នាតធំ។ ការផ្តល់លិខិតអនុញ្ញាតធ្វើនេសាទនេះត្រូវរក្សាទុកក្នុងមូលដ្ឋានទិន្នន័យនាវានេសាទ

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ៣០០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

២.២.៥- សកម្មភាព : ចុះកំណត់ត្រា និងចេញប័ណ្ណសម្គាល់ឱ្យនាវានេសាទសមុទ្រខ្នាតតូចទាំងអស់

| | | |
|---|---|---|
| ស្ថាប័នអនុវត្ត | : | រដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តតំបន់ឆ្នេរ និងដៃគូអភិវឌ្ឍន៍នានា |
| នីតិវិធី | : | រដ្ឋបាលជលផលរៀបចំចុះកំណត់ត្រា និងចេញប័ណ្ណសម្គាល់ឱ្យនាវានេសាទសមុទ្រខ្នាតតូចទាំងអស់ |
| ពេលវេលា | : | ឆ្នាំ២០២០-២០២១ |
| ថវិកា | : | ២០០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។ |

| | | |
|---|---|---|
| ២.២.៦- សកម្មភាព | : | កសាងសមត្ថភាពធនធានមនុស្សនិងស្ថាប័នសម្រាប់ការចុះបញ្ជីចេញលិខិតអនុញ្ញាត ឬបណ្ណសម្គាល់ដល់នាវានេសាទសមុទ្រ |
| ស្ថាប័នអនុវត្ត | : | រដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តតំបន់ឆ្នេរ និងដៃគូអភិវឌ្ឍន៍នានា |
| នីតិវិធី | : | រៀបចំនិងប្រើមូលដ្ឋានទិន្នន័យថ្មីស្តីពីការចុះបញ្ជីនាវានេសាទនិងបណ្តុះបណ្តាលមន្ត្រីជលផលក្នុងការប្រើមូលដ្ឋានទិន្នន័យ ដោយផ្អែកទៅនឹងសេចក្តីថ្លែងការណ៍គោលនយោបាយជាតិស្តីពីជលផលសមុទ្រ សម្រាប់ការចុះបញ្ជីនាវានេសាទនិងការផ្តល់លិខិតអនុញ្ញាត។ សកម្មភាពនេះត្រូវចាប់ផ្តើមពីមន្ត្រីជលផលថ្នាក់កណ្តាលនិងមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូនដែលទទួលបន្ទុកការចុះបញ្ជីនាវានេសាទខ្នាតមធ្យមនិងខ្នាតធំ |
| ពេលវេលា | : | ឆ្នាំ២០២០-២០២២ |
| ថវិកា | : | ១៥០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។ |

**២.៣- ការផ្តល់សិទ្ធិដល់នាវាបរទេសក្នុងដែននេសាទសមុទ្រកម្ពុជា**

| | | |
|---|---|---|
| ២.៣.១- សកម្មភាព | : | ធ្វើកិច្ចសហការជាមួយប្រទេសថៃនិងវៀតណាមតាមនីតិវិធីក្នុងការមិនអនុញ្ញាតឱ្យនាវានេសាទថៃនិងវៀតណាមចូលធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ប្រទេសកម្ពុជា |
| ស្ថាប័នអនុវត្ត | : | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានជលផលនៃប្រទេសថៃ និងអគ្គនាយកដ្ឋានជលផលនៃប្រទេសវៀតណាម |
| នីតិវិធី | : | ពង្រឹងកិច្ចសហការជាមួយថៃនិងវៀតណាម និងបង្កើតយន្តការសហការ ដើម្បីធានាថាគ្មាននាវានេសាទថៃនិងវៀតណាមធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ប្រទេសកម្ពុជា |
| ពេលវេលា | : | ឆ្នាំ២០២០-២០២១ |
| ថវិកា | : | ៥០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។ |
| ២.៣.២- សកម្មភាព | : | ពិភាក្សាស្តីពីវិធានការគ្រប់គ្រងនិងការនេសាទរួមគ្នានៅក្នុងតំបន់ទាមទារត្រួតគ្នាជាមួយថៃនិងដែនទឹកប្រវត្តិសាស្ត្រជាមួយវៀតណាម |

| | | |
|---|---|---|
| ស្ថាប័នអនុវត្ត | : | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប |
| នីតិវិធី | : | តាមរយៈយន្តការដែលមានស្រាប់ដែលបានរៀបចំឡើងដោយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងតាមរយៈកិច្ចសហប្រតិបត្តិការដោយផ្ទាល់របស់មន្ត្រីជាន់ខ្ពស់ត្រូវសម្រេចឱ្យបាននូវកិច្ចព្រមព្រៀងថ្នាក់ជាតិដើម្បីគ្រប់គ្រងតំបន់ដែនទឹកប្រវត្តិសាស្ត្រជាមួយវៀតណាមនិងតំបន់ទាមទារត្រួតគ្នាជាមួយថៃ |
| ពេលវេលា | : | ឆ្នាំ២០២០-២០២១ |
| ថវិកា | : | ៥០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។ |

**២.៤- រៀបចំវិធានការត្រួតពិនិត្យនាវាដឹកជញ្ជូន និងនាវាផ្គត់ផ្គង់ផ្សេងៗទៀត**

| | | |
|---|---|---|
| ២.៤.១- សកម្មភាព | : | ជំរុញការចុះបញ្ជីនាវានិងយានយន្តដែលពាក់ព័ន្ធនឹងការដឹកជញ្ជូននិងការនាំចេញផល ផលិតផលជលផល |
| ស្ថាប័នអនុវត្ត | : | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងដៃគូអភិវឌ្ឍន៍នានា |
| នីតិវិធី | : | ផ្នែកមួយនៃការយកចិត្តទុកដាក់លើការចុះបញ្ជីនិងការចេញលិខិតអនុញ្ញាតនេសាទដល់នាវានេសាទ ត្រូវពង្រឹងលើការចេញលិខិតអនុញ្ញាតដល់នាវាដឹកជញ្ជូនក្នុងខេត្តសាកល្បង (កោះកុង) បន្ទាប់មកត្រូវពង្រីកទៅខេត្តដទៃទៀត។ |
| ពេលវេលា | : | ២០២០ - ២០២១ |
| ថវិកា | : | ១០០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។ |
| ២.៤.២ សកម្មភាព | : | បន្តផ្តល់លិខិតអនុញ្ញាតឱ្យនាវានេសាទនិងរថយន្តពាក់ព័ន្ធនឹងការដឹកជញ្ជូននិងការនាំចេញផល ផលិតផលជលផល |
| ស្ថាប័នអនុវត្ត | : | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍នានា |
| នីតិវិធី | : | ផ្នែកមួយនៃការយកចិត្តទុកដាក់លើការចេញលិខិតអនុញ្ញាតនាវានេសាទ ត្រូវពង្រឹងការចេញលិខិតអនុញ្ញាតដល់នាវាដឹកជញ្ជូន និងយានយន្តដទៃទៀតក្នុងខេត្តសាកល្បង (កោះកុង) បន្ទាប់មកត្រូវពង្រីកទៅខេត្តដទៃទៀត |
| ពេលវេលា | : | ២០២០ - ២០២២ |
| ថវិកា | : | ១០០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។ |
| ២.៤.៣ សកម្មភាព | : | សហប្រតិបត្តិការជាមួយសមត្ថកិច្ចគយនិងរដ្ឋាករ និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យនៃការដឹកជញ្ជូនផលនេសាទ |
| ស្ថាប័នអនុវត្ត | : | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា |

នីតិវិធី : ពង្រឹងប្រព័ន្ធចាំបាច់មួយចំនួនដើម្បីតាមដានការដឹកជញ្ជូនត្រីតាមផ្លូវសមុទ្រ អាកាស និងផ្លូវគោក ដែលចាប់ផ្ដើមក្នុងខេត្តសាកល្បង (កោះកុង) បន្ទាប់មកត្រូវពង្រីកទៅខេត្តដទៃទៀត

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ១០០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)

**២.៥- ពង្រឹងការតាមដាន ត្រួតពិនិត្យ និងការអង្កេត**

២.៥.១- សកម្មភាព : បន្តរៀបចំ និងអនុវត្តផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចផលផលសមុទ្រ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍នានា

នីតិវិធី : ជំហានដំបូងត្រូវពង្រឹងការតាមដាន ត្រួតពិនិត្យ និងការអង្កេតតាមតំបន់ឆ្នេរសមុទ្រកម្ពុជា បន្ទាប់មកពិនិត្យឡើងវិញនូវតួនាទីនិងភារកិច្ចរបស់ស្ថាប័នទទួលបន្ទុកការតាមដានត្រួតពិនិត្យនិងការអង្កេត និងផ្ដល់អនុសាសន៍សម្រាប់ធ្វើការកែលម្អ។ ជំហានបន្ទាប់ត្រូវរៀបចំ និងអនុម័តផែនការត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ ដោយផ្អែកលើការវាយតម្លៃហានិភ័យពីសកម្មភាពនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ ជាពិសេសការពង្រឹងសមត្ថភាពមន្ត្រីនិង ស្ថាប័នពាក់ព័ន្ធ

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ៥០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

២.៥.២- សកម្មភាព : បន្តបណ្ដុះបណ្ដាលការងារតាមដាន ត្រួតពិនិត្យ និងអង្កេត ដែលមានចែងនៅក្នុងផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍នានា

នីតិវិធី : ផ្ដល់វគ្គបណ្ដុះបណ្ដាលសម្រាប់ការតាមដានត្រួតពិនិត្យ និងអង្កេតនិងពង្រីកការបណ្ដុះបណ្ដាលទៅតាមខេត្តតំបន់ឆ្នេរដទៃទៀត គ្រូបង្គោលអាចមកពីមន្ត្រីអធិការកិច្ចនៃប្រទេសតំបន់អាស៊ាន

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ៣០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

២.៥.៣- សកម្មភាព : ទិញ ជួសជុល និងថែរក្សានាវាល្បាត

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍នានា

នីតិវិធី : មុននឹងទិញ ជួសជុលកែលម្អ និងថែរក្សា ត្រូវមានឯកសារសម្រង់តម្លៃ

ចំណាំ : ត្រូវមានថវិកាសម្រាប់ជួសជុលជាប្រចាំ

ពេលវេលា : ២០២០-២០២២

ថវិកា : ២ ០០០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

២.៥.៥- សកម្មភាព : បណ្តុះបណ្តាលនិងផ្តល់សៀវភៅកត់ត្រាស្ថិតិផលនេសាទសម្រាប់នាវានេសាទសមុទ្រខ្នាតធំនិងខ្នាតមធ្យម

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នីតិវិធី : រៀបចំអនុវត្តសាកល្បងនិងដាក់ឱ្យប្រើសៀវភៅកត់ត្រាស្ថិតិផលនេសាទក្នុងខេត្តសាកល្បង និងពង្រីកទៅខេត្តដទៃទៀត

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ៥៥ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)

២.៥.៦- សកម្មភាព : សិក្សា ពិនិត្យ និងជ្រើសរើសឧបករណ៍តាមដានសមស្រប ដើម្បីដំឡើងប្រព័ន្ធតាមដានក្នុងនាវានេសាទខ្នាតមធ្យមនិងខ្នាតធំ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងរដ្ឋបាលជាតិមហាសមុទ្រ និងបរិយាកាសនៃសហរដ្ឋអាមេរិក

នីតិវិធី : តាមរយៈសិក្ខាសាលាថ្នាក់តំបន់ (តាមរយៈការផ្លាស់ប្តូរកិច្ចពិភាក្សាទ្វេភាគី) និងប្រជុំពិភាក្សាថ្នាក់ជាតិ ស្តីពីប្រព័ន្ធគ្រប់គ្រងរូបភាពតាមផ្កាយរណបនិងប្រព័ន្ធតាមដាននាវានេសាទ និងតាមរយៈបទពិសោធន៍ពីបណ្តាប្រទេសអាស៊ាន និងទីប្រឹក្សាផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រឆ្នាំ២០២០-២០២៤ ត្រូវពិនិត្យជម្រើសដើម្បីដំឡើងប្រព័ន្ធគ្រប់គ្រងរូបភាពតាម ផ្កាយរណបនិងប្រព័ន្ធតាមដាននាវានេសាទក្នុងនាវានេសាទខ្នាតមធ្យមនិងខ្នាតធំ

ពេលវេលា : ឆ្នាំ២០២០

ថវិកា : ៥០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

២.៥.៧- សកម្មភាព : ដំឡើងប្រព័ន្ធតាមដាន សម្រាប់នាវានេសាទខ្នាតមធ្យមនិងខ្នាតធំ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នីតិវិធី : មុនធ្វើការដំឡើងប្រព័ន្ធតាមដានត្រូវមានឯកសារសម្រង់តម្លៃ

ពេលវេលា : ឆ្នាំ២០២១

ថវិកា : ៥០០ ០០០ដុល្លារ(ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

**៣- ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិ**

**៣.១- ការចុះបញ្ជី និងកត់ត្រានាវានេសាទ នៅក្នុងដែននេសាទសមុទ្ររបស់រដ្ឋដទៃឬនៅសមុទ្រអន្តរជាតិ**

៣.១.១- សកម្មភាព : សហការវិភាគតម្លៃជាក់ទុននិងផលចំណេញ សម្រាប់ការបើកឱ្យមានការចុះបញ្ជីនាវានេសាទបរទេសឡើងវិញ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : ដោយមានកិច្ចសហការពីរដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ត្រូវការជំនួយទីប្រឹក្សាអន្តរជាតិ ដើម្បីសិក្សាវាយតម្លៃការដាក់ទុន និងផលចំណេញ សម្រាប់ការបើកឱ្យមានការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតនាវានេសាទបរទេសឡើងវិញ ដើម្បីតាមដាន ត្រួតពិនិត្យ និងអង្កេតចំពោះនាវានេសាទឬផ្ទេរផលនេសាទឬផ្គត់ផ្គង់នាវានេសាទ

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ១០០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

៣.១.២. សកម្មភាព : រៀបចំប្រព័ន្ធចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតនាវានេសាទសមុទ្រ បំពាក់ទង់ជាតិកម្ពុជាដែលធ្វើនេសាទក្នុងរដ្ឋដទៃឬនៅសមុទ្រអន្តរជាតិ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : អនុវត្តវិធានការត្រួតពិនិត្យ និងអធិការកិច្ចឱ្យមានប្រសិទ្ធភាពដោយមានកិច្ចសហការពីរដ្ឋបាលជលផល អគ្គនាយដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ រៀបចំប្រព័ន្ធចុះបញ្ជីនាវានេសាទមិនមែននេសាទខុសច្បាប់ គ្មានរបាយកាណ៍ និងគ្មានការអនុញ្ញាត ដើម្បីធ្វើនេសាទឬផ្ទេរផលនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃ (ដែលបានអនុញ្ញាត) និងនៅសមុទ្រអន្តរជាតិឬតំបន់របស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ៥០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

**៣.២- ការផ្តល់សិទ្ធិឱ្យធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃនិងក្នុងសមុទ្រអន្តរជាតិ**

៣.២.១- សកម្មភាព : រៀបចំយន្តការនៃការផ្តល់សិទ្ធិឱ្យនាវាធ្វើនេសាទមិនមែនជាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលបំពាក់ទង់ជាតិកម្ពុជានៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃឬនៅក្នុងសមុទ្រអន្តរជាតិ រួមទាំងវិធានការត្រួតពិនិត្យ និងអធិការកិច្ចដ៏មានប្រសិទ្ធភាព

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល និងក្រសួងសាធារណការនិងដឹកជញ្ជូន

នីតិវិធី : ដោយមានកិច្ចសហការពីរដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រនិងកំពង់ផែនិងដៃគូអភិវឌ្ឍន៍ ត្រូវការជំនួយទីប្រឹក្សាអន្តរជាតិ ក្នុងការរៀបចំប្រព័ន្ធផ្តល់សិទ្ធិសម្រាប់នាវានេសាទ មិនមែននេសាទខុសច្បាប់ គ្មានរបាយកាណ៍ និងគ្មានការអនុញ្ញាត ដើម្បីធ្វើនេសាទឬផ្ទេរផលនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃ(ដែលបានអនុញ្ញាត) និងនៅសមុទ្រអន្តរជាតិឬតំបន់របស់ អង្គការ

គ្រប់គ្រងផលផលថ្នាក់តំបន់ ដោយរួមបញ្ចូលវិធានការត្រួតពិនិត្យនិងអធិការកិច្ច ដូចជាកម្មវិធីអង្កេតប្រព័ន្ធតាមដាននាវានេសាទ។ល។

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ៤៥ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

## ៣.៣- វិធានការត្រួតពិនិត្យនាវាពាក់ព័ន្ធនឹងការនេសាទ

៣.៣.១- សកម្មភាព : បង្កើតប្រព័ន្ធចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាត និងកត់ត្រានាវានេសាទដឹកជញ្ជូននិងនាវាផ្គត់ផ្គង់កម្ពុជានៅក្នុងដែននេសាទសមុទ្ររដ្ឋដទៃនិងសមុទ្រអន្តរជាតិ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ

នីតិវិធី : បញ្ជូនឯកសារសុំធ្វើនេសាទឱ្យរដ្ឋបាលជលផលពិនិត្យផ្ទៀងផ្ទាត់ជាមុនបង្កើតប្រព័ន្ធចុះបញ្ជីផ្តល់លិខិតអនុញ្ញាតកត់ត្រានាវានេសាទដឹកជញ្ជូននិងផ្គត់ផ្គង់របស់កម្ពុជានៅក្នុងដែននេសាទសមុទ្ររដ្ឋដទៃនិងសមុទ្រអន្តរជាតិ ត្រូវផ្តល់ឯកសារសុំធ្វើនេសាទឱ្យរដ្ឋបាលជលផល ពិនិត្យផ្ទៀងផ្ទាត់ជាមុន ដើម្បីអនុវត្តវិធានការត្រួតពិនិត្យនិងអធិការកិច្ចដ៏មានប្រសិទ្ធភាព ដោយមានកិច្ចសហការពីរដ្ឋបាលជលផល ក្រសួងសាធារណការនិងដឹកជញ្ជូនរៀបចំវិធានការត្រួតពិនិត្យនាវានេសាទ និងនាវាផ្គត់ផ្គត់ដទៃទៀត

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ៥០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

# ៤- វិធានការរបស់រដ្ឋម្ចាស់កំពង់ផែ

## ៤.១- ការប្រើវិធានការរដ្ឋម្ចាស់កំពង់ផែ

៤.១.១- សកម្មភាព : កំណត់កំពង់ផែឬកន្លែងឡើងផលនេសាទផ្លូវការសម្រាប់នាវាបរទេស

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផលនិងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : ក្រោមជំនួយរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ត្រូវកំណត់និងជ្រើសយកកំពង់ផែឬផែនេសាទជាផ្លូវការសម្រាប់នាវានេសាទបរទេស

ពេលវេលា : ឆ្នាំ២០២០

ថវិកា : ៣០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

៤.១.២- សកម្មភាព : បង្ហាញឬផ្សព្វផ្សាយកន្លែងឡើងផលនេសាទឬកំពង់ផែនេសាទសម្រាប់ធ្វើអធិការកិច្ចចំពោះនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតរបស់បរទេស

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផលនិងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រនិងកំពង់ផែ

នីតិវិធី : ក្រោមជំនួយរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងតាមរយៈកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលជលផលនិងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ

និងកំពង់ផែត្រូវរៀបចំនីតិវិធីត្រួតពិនិត្យនាវានេសាទបរទេសដែលមាននៅក្នុងកំពង់ផែ ឬផែនេសាទរបស់កម្ពុជា

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ៥០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

**៤.២- នីតិវិធីចំពោះនាវាបរទេសដែលបានរកឃើញថា ជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត**

៤.២.១- សកម្មភាព : បង្កើតនិងអនុវត្តនីតិវិធីចំពោះនាវាបរទេសដែលរកឃើញថាបាននេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ

នីតិវិធី : រដ្ឋបាលជលផលសហការជាមួយ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ដើម្បីបង្កើតនិងអនុវត្តនីតិវិធីចំពោះនាវានេសាទបរទេស ដែលជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងបណ្តុះបណ្តាលដល់មន្ត្រីអធិការកិច្ចសម្រាប់ចុះត្រួតពិនិត្យនិងបន្តចុះធ្វើអធិការកិច្ច

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ២៥ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

**៤.៣- កិច្ចសហប្រតិបត្តិការជាមួយរដ្ឋម្ចាស់កំពង់ផែ ឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ**

៤.៣.១- សកម្មភាព : សហការជាមួយរដ្ឋម្ចាស់ឆ្នេរ រដ្ឋម្ចាស់កំពង់ផែនិងរដ្ឋពាក់ព័ន្ធនានា ព្រមទាំងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ស្តីពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ អាស៊ាន និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់

នីតិវិធី : តាមរយៈយន្តការដែលមានស្រាប់របស់អាស៊ាន លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ត្រូវធ្វើការសហការនិងផ្តល់ព័ត៌មានអំពីនាវាបរទេសដែលជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតដែលមាននៅកំពង់ផែនេសាទ

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ២០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

៤.៣.២- សកម្មភាព : ចែករំលែកព័ត៌មានស្តីពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងការតាមដានត្រួតពិនិត្យ និងការអង្កេត

ស្ថាប័នអនុវត្ត : អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រនៃរដ្ឋបាលជលផល កងទ័ពជើងទឹក និងទីបញ្ជាការជួរមុខ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

នីតិវិធី : តាមរយៈបណ្តាញការតាមដាន ត្រួតពិនិត្យ និងអង្កេតថ្នាក់អនុតំបន់របស់លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ ត្រូវចែករំលែកព័ត៌មាន និងបទពិសោធន៍ស្តីពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងការតាមដាន ត្រួតពិនិត្យ និងអង្កេតនៅក្នុងឈូងសមុទ្រថៃ

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ១៥ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។

## ៥- វិធានការទាត់ទងនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ

៥.១- សកម្មភាព : អនុម័តនិងសាកល្បងប្រើប្រព័ន្ធឯកសារគ្រប់គ្រងផលនេសាទអាស៊ាន និងលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងកិច្ចសហប្រតិបត្តិការមហាសមុទ្រ

នីតិវិធី : រៀបចំនិងធ្វើការសាកល្បងនូវប្រព័ន្ធឯកសារផលនេសាទ ដោយមានកិច្ចសហការពីលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងកិច្ចសហប្រតិបត្តិការមហាសមុទ្រ

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ៥០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងដៃគូអភិវឌ្ឍន៍នានា)។

## ៦- កិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់និងប្រទេសផ្សេងទៀត ដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

៦.១- សកម្មភាព : បន្តផ្តល់ព័ត៌មានដល់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់អំពីនាវានេសាទដោតទង់ជាតិកម្ពុជានៅក្នុងសមុទ្រអន្តរជាតិនិងក្នុងតំបន់របស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នីតិវិធី : សហការជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់តាមការចាំបាច់

ពេលវេលា : ឆ្នាំ២០២០-២០២១

ថវិកា : ១០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិ)។

## ៧- លក្ខខណ្ឌតម្រូវពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ

៧.១- សកម្មភាព : បន្តកិច្ចការជាមួយអាស៊ាន លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល កងទ័ពជើងទឹក នគរបាលព្រំដែនទឹក គណៈកម្មការជាតិសន្តិសុខលម្ហសមុទ្រ លេខាធិការដ្ឋានអាស៊ាន លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

នីតិវិធី : ចូលរួមជាមួយប្រទេសជាសមាជិកអាស៊ានក្នុងសកម្មភាពពង្រឹងសមត្ថភាពជាមួយប្រទេសសមាជិកអាស៊ាន រួមទាំងការងារល្បាតរួមគ្នាជាមួយប្រទេសជិតខាង ដើម្បីពង្រឹងសមត្ថភាពមន្រ្តីជលផលនិងដៃគូ

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ២០ ០០០ដុល្លារក្នុងមួយឆ្នាំ (ថវិកាជាតិ )។

## ៨-ការរាយការណ៍

៨.១- សកម្មភាព : រៀបចំផែនការអនុវត្តនិងអនុវត្តផែនការសកម្មភាពជាតិស្តីពី ការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងថវិកាសម្រាប់អនុវត្តន៍ប្រចាំឆ្នាំ

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នីតិវិធី : រៀបចំផែនការសកម្មភាពប្រចាំឆ្នាំនីមួយៗដោយផ្អែកទៅនឹងផែនការអនុវត្តរយៈពេល៣ឆ្នាំ

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ១៥ ០០០ដុល្លារ (ថវិកាជាតិ)។

៨.២- សកម្មភាព : រាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នីតិវិធី : រៀបចំរបាយការណ៍វឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំតាមរយៈរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលជលផល

ពេលវេលា : ឆ្នាំ២០២០-២០២២

ថវិកា : ១៥ ០០០ដុល្លារ (ថវិកាជាតិ)។

៨.៣- សកម្មភាព : រាយការណ៍ទៅកាន់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិរៀងរាល់ពីរឆ្នាំម្តង

ស្ថាប័នអនុវត្ត : រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | | |
|---|---|---|
| នីតិវិធី | : | ប្រមូលទិន្នន័យព័ត៌មានដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាពក្នុងការអនុវត្តក្រមប្រតិបត្តិដោយមានការទទួលខុសត្រូវក្នុងវិស័យជលផល រយៈពេលពីរឆ្នាំជូនអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ |
| ពេលវេលា | : | ឆ្នាំ២០២០ |
| ថវិកា | : | ១០ ០០០ដុល្លារ (ថវិកាជាតិនិងដៃគូអភិវឌ្ឍន៍នានា)។ |

## គ. តារាងសកម្មភាពអាទិភាព សូចនាករ និងស្ថាប័នទទួលខុសត្រូវ

| លេខរៀងសកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ១ | **ការទទួលខុសត្រូវរបស់រដ្ឋ** | | | | | |
| ១.១ | **ផ្តល់សច្ចាប័នដល់លិខិតុបករណ៍អន្តរជាតិសំខាន់ៗ** | | | | | |
| ១.១.១ | រៀបចំបែបបទលិខិតរដ្ឋបាលក្នុងការស្នើសុំចូលជារដ្ឋសមាជិកនៃវិធានការរដ្ឋម្ចាស់កំពង់ផែនៃកិច្ចព្រមព្រៀងរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ | √ | | | ព្រះរាជាណាចក្រកម្ពុជានឹងក្លាយជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែនៃអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ១.១.២ | រៀបចំស្នើសុំការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអង្គការសហប្រជាជាតិស្តីពីផលស្តុកត្រី | √ | | | កិច្ចព្រមព្រៀងអង្គការសហប្រជាជាតិស្តីពីផលស្តុកត្រីនឹងត្រូវបានអនុម័តនឹងផ្តល់សច្ចាប័ន ព្រះរាជាណាចក្រកម្ពុជានឹងក្លាយជាសមាជិកនៃកិច្ចព្រមព្រៀងអង្គការសហប្រជាជាតិស្តីពីផលស្តុកត្រី | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋសភាជាតិ ព្រឹទ្ធសភាជាតិ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ១.២ | **គ្របខ័ណ្ឌច្បាប់ជាតិ** | | | | | |
| ១.២.១ | **បទប្បញ្ញត្តិ** | | | | | |
| ១.២.១.១ | បន្តពិនិត្យកែសម្រួលសេចក្តីព្រាងនិងអនុម័តវិសោធនកម្មច្បាប់ស្តីពីជលផលនិងអនុក្រឹត្យស្តីពីជលផលសមុទ្រ និងការនេសាទនៅតំបន់សមុទ្រក្រៅ | √ | | | សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីជលផល និងអនុក្រឹត្យស្តីពីជលផលសមុទ្រត្រូវបានពិនិត្យ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| លេខរៀង សកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ១.២.១.២ | អនុម័តវិសោធនកម្មច្បាប់ស្តីពីជលផល និង អនុក្រឹត្យស្តីពីជលផលសមុទ្រនិងការនេសាទនៅតំបន់សមុទ្រក្រៅ | √ | √ | | វិសោធនកម្មច្បាប់ស្តីពីជលផលនិងអនុក្រឹត្យស្តីពីជលផលសមុទ្រត្រូវបានអនុម័ត និង ផ្សព្វផ្សាយជាផ្លូវការ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ១.២.៣ | **ទោសប្បញ្ញត្តិនិងការដាក់ទណ្ឌកម្ម** | | | | | |
| ១.២.៣.១ | បន្តកែសម្រួលទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីជលផលឡើងវិញដោយដាក់ការផាកពិន័យឱ្យមានប្រសិទ្ធភាព | √ | √ | | ជំពូកទោសប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីជលផលត្រូវបានកែសម្រួល និងអនុម័ត | រដ្ឋបាលជលផល |
| ១.២.៥ | **កិច្ចសហប្រតិបត្តិការរវាងរដ្ឋនានា** | | | | | |
| ១.២.៥.១ | បន្តរៀបចំនិងអនុវត្តកិច្ចព្រមព្រៀងជាមួយប្រទេសថៃ និងវៀតណាមដែលបានឯកភាពគ្នានៅក្នុងអនុស្សរណៈយោគយល់ | √ | √ | √ | អនុស្សរណៈយោគយល់ជាមួយប្រទេសថៃ និងវៀតណាម សម្រាប់អនុវត្តសកម្មភាពនានាត្រូវបានរៀបចំ ឯកភាពនិងអនុវត្ត | រដ្ឋបាលជលផល ជលផលវៀតណាមនិងជលផលថៃ |
| ២ | **ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ឆ្នេរ** | | | | | |
| ២.១ | **ការគ្រប់គ្រងធនធានជលផលនៅកម្ពុជា** | | | | | |
| ២.១.២ | រៀបចំនិងអនុម័តផែនការជាតិគ្រប់គ្រងជលផលសមុទ្រដែលមានលក្ខណៈទូលំទូលាយ | | √ | √ | ផែនការជាតិគ្រប់គ្រងវិស័យជលផលសមុទ្រត្រូវបានរៀបចំនិងអនុម័ត | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ២.១.៣ | កែលម្អប្រព័ន្ធប្រមូលទិន្នន័យនិងព័ត៌មាននៅតាមផែនេសាទ | √ | √ | | ប្រព័ន្ធប្រមូលទិន្នន័យនិងព័ត៌មានតាមកំពង់ផែត្រូវបានធ្វើការកែសម្រួល | រដ្ឋបាលជលផល |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ២.១.៤ | កែលម្អប្រព័ន្ធព័ត៌មានជលផលសម្រាប់ការគ្រប់គ្រងជលផលនិងអ្នកធ្វើគោលនយោបាយ និងចែករំលែកព័ត៌មានទាំងនោះជាមួយលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិនិងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | √ | √ | | ប្រព័ន្ធព័ត៌មានជលផលត្រូវបានកែលម្អដោយធ្វើការប្រៀបធៀបទៅនឹងទិន្នន័យឆ្នាំគោល ២០១៨ និងព័ត៌មានទាំងនោះត្រូវបានចែករំលែកជាមួយ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ជារៀងរាល់ឆ្នាំ | រដ្ឋបាលជលផល |
| ២.១.៥ | ពង្រឹងប្រព័ន្ធប្រមូលនិងវិភាគទិន្នន័យព័ត៌មានជលផល និងចែករំលែកជាមួយ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់ អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | √ | √ | | ការប្រមូលទិន្នន័យនិងប្រព័ន្ធព័ត៌មានជលផលត្រូវបានធ្វើការប្រៀបធៀបទៅនឹងទិន្នន័យឆ្នាំគោល២០១៩។ ព័ត៌មានត្រូវបានចែករំលែកជាមួយ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិជារៀងរាល់ឆ្នាំ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍នានា |
| **២.២** | **ការផ្តល់សិទ្ធិដល់នាវានេសាទកម្ពុជាធ្វើនេសាទនៅក្នុងដែនសមុទ្រកម្ពុជា** | | | | | |
| ២.២.១ | បន្តប្រមូលទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រទាំងអស់ | √ | √ | | របាយការណ៍ស្តីពីទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រត្រូវបានចងក្រង | រដ្ឋបាលជលផល |
| ២.២.២ | កសាងសមត្ថភាពក្នុងការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតដល់នាវានេសាទសមុទ្រទាំងអស់ | | √ | | កម្មវិធីបណ្តុះបណ្តាលសមស្របត្រូវបាន | រដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| | | | | | ឯកភាពនិងគាំទ្រដល់ក្រសួងសាធារណការនិងដឹកជញ្ជូននិងរដ្ឋបាលជលផលដើម្បីចុះបញ្ជីនិងផ្តល់សិទ្ធិដល់នាវានេសាទ | |
| ២.២.៣ | ជំរុញការចុះបញ្ជីនាវានេសាទខ្នាតមធ្យមនិងខ្នាតធំទាំងអស់ | √ | √ | | នាវានេសាទខ្នាតមធ្យមនិងខ្នាតធំត្រូវបានចុះបញ្ជីទាំងអស់ | អគ្គនាយកដ្ឋានដឹកជញ្ជូន ផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ និងរដ្ឋបាលជលផល |
| ២.២.៤ | ចេញលិខិតអនុញ្ញាតដល់នាវានេសាទសមុទ្រខ្នាតមធ្យមនិងធំទាំងអស់ | √ | √ | | នាវានេសាទខ្នាតមធ្យមនិងធំត្រូវបានទទួលលិខិតអនុញ្ញាត | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.២.៥ | ចុះកំណត់ត្រាបញ្ជីនិងចេញប័ណ្ណសម្គាល់ឱ្យនាវានេសាទសមុទ្រខ្នាតតូចទាំងអស់ | √ | √ | | នាវានេសាទខ្នាតតូចត្រូវបានកត់ត្រាក្នុងបញ្ជី | រដ្ឋបាលជលផល |
| ២.២.៦ | កសាងសមត្ថភាពធនធានមនុស្សនិងស្ថាប័នសម្រាប់ការចុះបញ្ជី ចេញលិខិតអនុញ្ញាតឬប័ណ្ណសម្គាល់ដល់នាវានេសាទសមុទ្រ | √ | √ | √ | ចំនួនមន្ត្រី៥នាក់/ខេត្ត ត្រូវបានបណ្តុះបណ្តាលក្នុងការចុះបញ្ជីនិងចេញលិខិតអនុញ្ញាតនាវានេសាទ | រដ្ឋបាលជលផលនិងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ |
| ២.៣ | **ការផ្តល់សិទ្ធិដល់នាវាបរទេសក្នុងដែននេសាទសមុទ្រកម្ពុជា** | | | | | |
| ២.៣.១ | សហការជាមួយប្រទេសថៃនិងវៀតណាម មិនអនុញ្ញាតឱ្យនាវានេសាទថៃនិងវៀតណាម ធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ប្រទេសកម្ពុជា | √ | √ | | ព័ត៌មានបញ្ជាក់ថាគ្មាននាវានេសាទបរទេសធ្វើនេសាទក្នុងដែនសមុទ្រកម្ពុជា ដែលមិនមានវិវាទត្រូវបានចងក្រង | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| លេខរៀង សកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ២.៣.២ | ពិភាក្សាស្តីពីវិធានការគ្រប់គ្រងនិងការធ្វើនេសាទរួមគ្នានៅក្នុងតំបន់ទាមទារត្រួតគ្នាជាមួយថៃនិងវៀតណាម | | √ | √ | កិច្ចព្រមព្រៀងស្តីពីវិធានគ្រប់គ្រងនិងអភិរក្សផលផលរួមគ្នាក្នុងតំបន់ទាមទារត្រួតគ្នាដែលមានវិវាទត្រូវបានចុះហត្ថលេខា | រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ |
| **២.៤** | **វិធានការត្រួតពិនិត្យទាក់ទងនឹងការនេសាទ** | | | | | |
| ២.៤.១ | ជំរុញការចុះបញ្ជីនាវានិងយានយន្តដែលពាក់ព័ន្ធនឹងការដឹកជញ្ជូននិងការនាំចេញផល ផលិតផលជលផល | √ | √ | | នាវានិងយានយន្តដែលមានការពាក់ព័ន្ធនឹងការដឹកជញ្ជូន និងការនាំចេញផល ផលិតផលជលផលត្រូវបានចុះបញ្ជី | រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានដឹកជញ្ជូន ផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ |
| ២.៤.២ | បន្តចេញលិខិតអនុញ្ញាតដល់នាវានិងយានយន្តដែលពាក់ព័ន្ធនឹងការដឹកជញ្ជូននិងនាំចេញផល ផលិតផលជលផល | √ | √ | √ | នាវានិងយានយន្តដែលមានការពាក់ព័ន្ធនឹងការដឹកជញ្ជូននិងនាំចេញផល ផលិតផលជលផលត្រូវបានផ្តល់លិខិតអនុញ្ញាត | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.៤.៣ | សហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យការដឹកជញ្ជូនផលនេសាទ | √ | √ | √ | ប្រព័ន្ធតាមដានត្រួតពិនិត្យត្រូវបានឯកភាព ឱ្យប្រើប្រាស់ដើម្បីតាមដានការដឹកជញ្ជូនត្រី | រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ |
| **២.៥** | **ការតាមដាន ត្រួតពិនិត្យ និងអង្កេត** | | | | | |
| ២.៥.១ | រៀបចំនិងអនុវត្តផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ | √ | √ | √ | ផែនការសកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ ត្រូវបានអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.៥.២ | បន្តបណ្តុះបណ្តាលការងារតាមដានត្រួតពិនិត្យនិងអង្កេត ដែលមានចែងនៅក្នុងផែនការ | √ | √ | √ | មន្ត្រីចំនួន៥០នាក់ក្នុងមួយឆ្នាំ ត្រូវបានបណ្តុះបណ្តាលលើការងារតាមដាន ត្រួតពិនិត្យនិងអង្កេត | រដ្ឋបាលជលផល |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| | សកម្មភាពត្រួតពិនិត្យនិងអធិការកិច្ចជលផលសមុទ្រ | | | | | |
| ២.៥.៣ | ទិញ ជួសជុលនិងថែរក្សានាវាល្បាត | √ | √ | √ | នាវាល្បាតត្រូវបានទិញបន្ថែម ជួសជុលកែលម្អ | រដ្ឋបាលជលផល |
| ២.៥.៥ | បណ្តុះបណ្តាលនិងផ្តល់សៀវភៅកត់ត្រាស្ថិតិផលនេសាទសម្រាប់នាវានេសាទសមុទ្រខ្នាតធំនិងខ្នាតមធ្យម | √ | √ | √ | សៀវភៅកត់ត្រាស្ថិតិត្រូវបានដាក់ឱ្យប្រើប្រាស់ ហើយអ្នកនេសាទត្រូវបានបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.៥.៦ | សិក្សា ពិនិត្យ និងជ្រើសរើសឧបករណ៍តាមដានសមស្រប ដើម្បីដំឡើងប្រព័ន្ធតាមដានក្នុងនាវានេសាទសមុទ្រខ្នាតមធ្យម និងខ្នាតធំ | √ | | | ប្រព័ន្ធនិងឧបករណ៍តាមដានសមស្របត្រូវបានជ្រើសរើសសម្រាប់ប្រើក្នុងនាវានេសាទខ្នាតមធ្យម និងខ្នាតធំ | រដ្ឋបាលជលផល |
| ២.៥.៧ | ដំឡើងប្រព័ន្ធតាមដាន សម្រាប់នាវានេសាទសមុទ្រខ្នាតមធ្យមនិងខ្នាតធំ | | √ | | ការិយាល័យអង្កេតតាមដាន ត្រូវបានបង្កើត និងប្រព័ន្ធតាមដាន ត្រូវបានបំពាក់នៅលើនាវានេសាទសមុទ្រខ្នាតមធ្យមនិងធំ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៣ | **ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិ** | | | | | |
| ៣.១ | **ការចុះបញ្ជី និងកត់ត្រានាវានេសាទ នៅក្នុងដែននេសាទសមុទ្ររបស់រដ្ឋដទៃឬនៅសមុទ្រអន្តរជាតិ** | | | | | |
| ៣.១.១ | សហការវិភាគតម្លៃដាក់ទុននិងផលចំណេញសម្រាប់ការបើកឱ្យមានការចុះបញ្ជីនាវានេសាទបរទេសឡើងវិញ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | √ | √ | | របាយការណ៍លទ្ធផលការវិភាគនិងវាយតម្លៃការដាក់ទុន និងផលចំណេញត្រូវបានរៀបចំ និងចែកចាយ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |

| លេខរៀង សកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ៣.១.២ | រៀបចំប្រព័ន្ធចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតនាវានេសាទសមុទ្របំពាក់ទង់ជាតិកម្ពុជាដែលធ្វើនេសាទក្នុងរដ្ឋដទៃឬនៅសមុទ្រអន្តរជាតិ | √ | √ | | ការចុះបញ្ជីជាសាធារណៈដល់នាវានេសាទសមុទ្រដោតទង់ជាតិកម្ពុជា ត្រូវបានផ្សព្វផ្សាយជាសាធារណៈ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣.២ | **ការផ្តល់សិទ្ធិឱ្យធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃនិងក្នុងសមុទ្រអន្តរជាតិ** | | | | | |
| ៣.២.១ | រៀបចំយន្តការនៃការផ្តល់សិទ្ធិឱ្យនាវាធ្វើនេសាទមិនមែនជាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតដែលបំពាក់ទង់ជាតិកម្ពុជា នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដទៃឬនៅក្នុងសមុទ្រអន្តរជាតិ រួមទាំងវិធានការត្រួតពិនិត្យនិងអធិការកិច្ចដ៏មានប្រសិទ្ធភាព | √ | √ | √ | នីតិវិធីប្រកបដោយតម្លាភាពត្រូវបានឯកភាពសម្រាប់ផ្តល់សិទ្ធិដល់នាវានេសាទដែលមិនមែនជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដោតទង់ជាតិកម្ពុជា នេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ របស់រដ្ឋដទៃ ឬក្នុងសមុទ្រអន្តរជាតិ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣.៣ | **វិធានការត្រួតពិនិត្យនាវាពាក់ព័ន្ធនឹងការនេសាទ** | | | | | |
| ៣.៣.១ | បង្កើតប្រព័ន្ធចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតនិងកត់ត្រានាវានេសាទដឹកជញ្ជូន និងនាវា ផ្គត់ផ្គង់កម្ពុជានៅក្នុងដែននេសាទសមុទ្រ រដ្ឋដទៃនិងសមុទ្រអន្តរជាតិ | | √ | √ | ប្រព័ន្ធចុះបញ្ជី ផ្តល់លិខិតអនុញ្ញាត និងកត់ត្រានាវានេសាទដឹកជញ្ជូនរបស់នាវានេសាទ ដោតទង់ជាតិកម្ពុជាត្រូវបានបង្កើត | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤ | **វិធានការរដ្ឋម្ចាស់កំពង់ផែ** | | | | | |
| ៤.១ | **ការប្រើវិធានការរដ្ឋម្ចាស់កំពង់ផែ** | | | | | |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ៤.១.១ | កំណត់កំពង់ផែឬកន្លែងឡើងផលនេសាទ ផ្លូវការសម្រាប់នាវាបរទេស | √ | | | ផ្សព្វផ្សាយជាសាធារណៈនូវទីតាំងកន្លែងឡើងផលនេសាទឬកំពង់ផែសម្រាប់នាវានេសាទបរទេស | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤.១.២ | បង្ហាញឬផ្សព្វផ្សាយកន្លែងឡើងផលនេសាទឬកំពង់ផែនេសាទ សម្រាប់ធ្វើអធិការកិច្ច ចំពោះនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតរបស់បរទេស | √ | √ | | សៀវភៅស្តីពីនីតិវិធីណែនាំកន្លែងឡើងផលនេសាទឬកំពង់ផែនេសាទ សម្រាប់ធ្វើអធិការកិច្ចចំពោះនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតរបស់បរទេសត្រូវបានរៀបចំ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| **៤.២** | **នីតិវិធីចំពោះនាវាបរទេសដែលបានរកឃើញថា ជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត** | | | | | |
| ៤.២.១ | បង្កើតនិងអនុវត្តនីតិវិធីចំពោះនាវាបរទេសដែលរកឃើញថាជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | √ | √ | | សៀវភៅស្តីពី នីតិវិធីណែនាំសម្រាប់នាវាបរទេសដែលត្រូវបានរកឃើញថាជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតត្រូវបានបង្កើតនិងអនុវត្ត | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **៤.៣** | **សហប្រតិបត្តិការជាមួយរដ្ឋម្ចាស់កំពង់ផែឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ដែលពាក់ព័ន្ធ** | | | | | |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
| --- | --- | --- | --- | --- | --- | --- |
| | | ២០២០ | ២០២១ | ២០២២ | | |
| ៤.៣.១ | សហការជាមួយរដ្ឋម្ចាស់ផ្ទែរ រដ្ឋម្ចាស់កំពង់ផែ និងរដ្ឋពាក់ព័ន្ធនានា ព្រមទាំងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ស្តីពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | √ | √ | √ | មន្ត្រីបង្គោលសម្រាប់សហការជាមួយបណ្តារដ្ឋ និងអង្គការអន្តរជាតិនានាស្តីពីការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយ-ការណ៍ត្រូវបានជ្រើសរើស | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់ អាស៊ីអាគ្នេយ៍ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ |
| ៤.៣.២ | ចែករំលែកព័ត៌មានស្តីពីការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ និង ការតាមដាន ត្រួតពិនិត្យ និងការអង្កេត | √ | √ | √ | ព័ត៌មានស្តីពីការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ និងការតាមដានត្រួតពិនិត្យ និងការអង្កេតត្រូវបានចែករំលែក | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ និងដៃគូអភិវឌ្ឍន៍នានា |
| ៥ | **វិធានការទាក់ទងនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ** | | | | | |
| ៥.១ | អនុម័តនិងសាកល្បងប្រើប្រព័ន្ធឯកសារផលនេសាទអាស៊ាន និងលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ | | √ | √ | ប្រព័ន្ធឯកសារផលចាប់របស់អាស៊ាននិងលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ ត្រូវបានកែសម្រួលសម្រាប់ប្រើក្នុងបរិបទកម្ពុជា | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៦ | **កិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងប្រទេសផ្សេងទៀតដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត** | | | | | |
| ៦.១ | បន្តផ្តល់ព័ត៌មានដល់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់អំពីនាវានេសាទដោតទង់ជាតិកម្ពុជា នៅក្នុងសមុទ្រអន្តរជាតិ និងក្នុងតំបន់របស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | | √ | √ | ព័ត៌មានស្តីពីនាវានេសាទដោតទង់ជាតិកម្ពុជានៅក្នុងសមុទ្រអន្តរជាតិ និងក្នុងតំបន់របស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ត្រូវបានបន្តចែករំលែក | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណុចដៅ | | | សូចនាករតាមដាន | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ៧ | **លក្ខខណ្ឌតម្រូវពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍** | | | | | |
| ៧.១ | បន្តកិច្ចសហការជាមួយអាស៊ានលេខាធិការ-ដ្ឋានអភិវឌ្ឍន៍ផលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជា-ជាតិ | √ | √ | √ | ប្រព័ន្ធទំនាក់ទំនងជាមួយលេខាធិការដ្ឋានអាស៊ាន លេខាធិការដ្ឋានអភិវឌ្ឍន៍ផលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ត្រូវបានបន្តកិច្ចសហការ | រដ្ឋបាលជលផល កងទ័ពជើងទឹក ប៉ូលីសលម្ហសមុទ្រ លេខាធិការដ្ឋានអាស៊ាន លេខាធិការដ្ឋានអភិវឌ្ឍន៍ផលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ |
| ៨ | **ការរាយការណ៍** | | | | | |
| ៨.១ | រៀបចំផែនការអនុវត្តនិងអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតនិងថវិកាសម្រាប់អនុវត្តប្រចាំឆ្នាំ | √ | √ | √ | ផែនការប្រចាំឆ្នាំនិងថវិកាត្រូវបានរៀបចំនិងអនុវត្ត | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៨.២ | រាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | √ | √ | √ | របាយការណ៍ស្តីពីវឌ្ឍនភាពការអនុវត្តផែនការប្រចាំឆ្នាំត្រូវបានចងក្រង | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៨.៣ | រាយការណ៍ទៅកាន់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិរៀងរាល់ពីរឆ្នាំម្តង | | √ | | របាយការណ៍វឌ្ឍនភាពត្រូវបានរាយការណ៍នៅក្នុងកិច្ចប្រជុំគណៈកម្មការជលផលនៃអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

## ឃ.តារាងសកម្មភាព និងថវិកា

| លេខរៀងសកម្មភាព | សកម្មភាព | ចំណាយគ្រោងតាមឆ្នាំ (ដុល្លារអាមេរិក) | | | ចំណាយសរុប | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ១ | **ការទទួលខុសត្រូវរបស់រដ្ឋ** | | | | | |
| ១.១ | **ផ្ដល់សច្ចាប័នដល់លិខិតុបករណ៍អន្តរជាតិសំខាន់ៗ** | | | | | |
| ១.១.១ | បន្តរៀបចំបែបបទលិខិតរដ្ឋបាលក្នុងការស្នើសុំចូលជារដ្ឋសមាជិកនៃវិធានការរដ្ឋម្ចាស់កំពង់ផែនៃកិច្ចព្រមព្រៀងរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ | ៦០ ០០០ | | | ៦០ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងទីស្ដីការគណៈរដ្ឋមន្ត្រី |
| ១.១.២ | បន្តរៀបចំស្នើសុំការផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងអង្គការសហប្រជាជាតិស្ដីពីផលស្តុកត្រី | ១០ ០០០ | | | ១០ ០០០ | |
| ១.២ | **ក្របខ័ណ្ឌច្បាប់ជាតិ** | | | | | |
| ១.២.១ | **បទប្បញ្ញត្តិ** | | | | | |
| ១.២.១.១ | បន្តពិនិត្យកែសម្រួលសេចក្ដីព្រាងនិងអនុម័តវិសោធនកម្មច្បាប់ស្ដីពីជលផល និងអនុក្រឹត្យស្ដីពីជលផលសមុទ្រ និងការនេសាទនៅតំបន់សមុទ្រក្រៅ | ២០០ ០០០ | | | ២០០ ០០០ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១.២.១.២ | អនុម័តវិសោធនកម្មច្បាប់ស្ដីពីជលផល និងអនុក្រឹត្យស្ដីពីជលផលសមុទ្រនិងការនេសាទ នៅតំបន់សមុទ្រក្រៅ | ៥ ០០០ | ៥ ០០០ | | ១០ ០០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទីស្ដីការគណៈរដ្ឋមន្ត្រី |
| ១.២.៣ | **ទោសប្បញ្ញត្តិនិងការដាក់ទណ្ឌកម្ម** | | | | | |
| ១.២.៣.១ | បន្តកែសម្រួលទោសប្បញ្ញត្តិក្នុងច្បាប់ស្ដីពីជលផលឡើងវិញដោយដាក់ការផាកពិន័យឱ្យមានប្រសិទ្ធភាព | ១០ ០០០ | ១០ ០០០ | | ២០ ០០០ | រដ្ឋបាលជលផល |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណាយគ្រោងតាមឆ្នាំ (ដុល្លារអាមេរិក) | | | ចំណាយសរុប | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ១.២.៥ | **កិច្ចសហប្រតិបត្តិការរវាងវេទិកាផ្សេងៗ** | | | | | |
| ១.២.៥.១ | បន្តរៀបចំនិងអនុវត្តកិច្ចព្រមព្រៀងជាមួយប្រទេសថៃ និងវៀតណាមដែលបានឯកភាពគ្នានៅក្នុងអនុស្សរណៈយោគយល់ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ | រដ្ឋបាលជលផល អគ្គនាយកដ្ឋានជលផលវៀតណាម និងនាយកដ្ឋានជលផលថៃ |
| ២ | **ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ផែ** | | | | | |
| ២.១ | **ការគ្រប់គ្រងធនធានជលផលនៅកម្ពុជា** | | | | | |
| ២.១.២ | រៀបចំនិងអនុម័តផែនការជាតិគ្រប់គ្រងជលផលសមុទ្រដែលមានលក្ខណៈទូលំទូលាយ | | ៥០ ០០០ | ៥០ ០០០ | ១០០ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ២.១.៣ | កែលម្អប្រព័ន្ធប្រមូលទិន្នន័យនិងព័ត៌មាននៅតាមផែនេសាទ | ៥០ ០០០ | ៥០ ០០០ | | ១០០ ០០០ | រដ្ឋបាលជលផល |
| ២.១.៤ | កែលម្អប្រព័ន្ធព័ត៌មានជលផលសម្រាប់ការគ្រប់គ្រងជលផលនិងអ្នកធ្វើគោលនយោបាយ និងចែករំលែកព័ត៌មានទាំងនោះជាមួយ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | ១០០ ០០០ | ១០០ ០០០ | | ២០០ ០០០ | រដ្ឋបាលជលផល |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណាយគ្រោងតាមឆ្នាំ (ដុល្លារអាមេរិក) | | | ចំណាយសរុប | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ២.១.៥ | ពង្រឹងប្រព័ន្ធប្រមូលនិងវិភាគទិន្នន័យព័ត៌មានជលផលនិងចែករំលែកជាមួយ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | | ៥០ ០០០ | ៥០ ០០០ | ១០០ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍នានា |
| **២.២** | **ការផ្ដល់សិទ្ធិដល់នាវានេសាទកម្ពុជាធ្វើនេសាទនៅក្នុងដែនសមុទ្រកម្ពុជា** | | | | | |
| ២.២.១ | បន្តប្រមូលទិន្នន័យនិងព័ត៌មាននាវានេសាទសមុទ្រទាំងអស់ | ១២៥ ០០០ | ១២៥ ០០០ | | ២៥០ ០០០ | រដ្ឋបាលជលផល |
| ២.២.២ | កសាងសមត្ថភាពក្នុងការចុះបញ្ជីនិងផ្ដល់លិខិតអនុញ្ញាតដល់នាវានេសាទសមុទ្រទាំងអស់ | | ៥០ ០០០ | | ៥០ ០០០ | រដ្ឋបាលជលផល អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ |
| ២.២.៣ | ជំរុញការចុះបញ្ជីនាវានេសាទខ្នាតមធ្យមនិងខ្នាតធំទាំងអស់ | ១៥០ ០០០ | ១៥០ ០០០ | | ៣០០ ០០០ | រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ |
| ២.២.៤ | ចេញលិខិតអនុញ្ញាតដល់នាវានេសាទសមុទ្រខ្នាតមធ្យមនិងធំទាំងអស់ | ១៥០ ០០០ | ១៥០ ០០០ | | ៣០០ ០០០ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.២.៥ | ចុះកំណត់ត្រាបញ្ជីនិងចេញប័ណ្ណសម្គាល់ឱ្យនាវានេសាទសមុទ្រខ្នាតតូចទាំងអស់ | ១០០ ០០០ | ១០០ ០០០ | | ២០០ ០០០ | រដ្ឋបាលជលផល |
| ២.២.៦ | កសាងសមត្ថភាពធនធានមនុស្សនិងស្ថាប័នសម្រាប់ការចុះបញ្ជី ចេញលិខិតអនុញ្ញាតប័ណ្ណសម្គាល់ដល់នាវានេសាទសមុទ្រ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ១៥០ ០០០ | រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណាយគ្រោងតាមឆ្នាំ (ដុល្លារអាមេរិក) | | | ចំណាយសរុប | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| **២.៣** | **ការផ្តល់សិទ្ធិដល់នាវាបរទេសក្នុងដែននេសាទសមុទ្រកម្ពុជា** | | | | | |
| ២.៣.១ | សហការជាមួយប្រទេសថៃនិងវៀតណាមមិនអនុញ្ញាតឱ្យនាវានេសាទថៃនិងវៀតណាម នេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ប្រទេសកម្ពុជា | ២៥ ០០០ | ២៥ ០០០ | | **៥០ ០០០** | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ |
| ២.៣.២ | ពិភាក្សាស្តីពីវិធានការគ្រប់គ្រងនិងការធ្វើនេសាទរួមគ្នានៅក្នុងតំបន់ទាមទារត្រួតគ្នាជាមួយថៃនិងដែនទឹកប្រវត្តិសាស្ត្រជាមួយវៀតណាម | | ២៥ ០០០ | ២៥ ០០០ | **៥០ ០០០** | រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានដឹកជញ្ជូន ផ្លូវទឹកផ្លូវសមុទ្រ និងកំពង់ផែ |
| **២.៤** | **វិធានការត្រួតពិនិត្យទាក់ទងនឹងការនេសាទ** | | | | | |
| ២.៤.១ | ជំរុញការចុះបញ្ជីនាវានិងយានយន្តដែលពាក់ព័ន្ធនឹងការដឹកជញ្ជូននិងការនាំចេញផល ផលិតផលជលផល | ១០០ ០០០ | ១០០ ០០០ | | **២០០ ០០០** | រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានដឹកជញ្ជូន ផ្លូវទឹកផ្លូវសមុទ្រ និងកំពង់ផែ |
| ២.៤.២ | បន្តចេញលិខិតអនុញ្ញាតដល់នាវានិងយានយន្តដែលពាក់ព័ន្ធនឹងការដឹកជញ្ជូននិងនាំចេញផល ផលិតផលជលផល | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ | **៣០០ ០០០** | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ |
| ២.៤.៣ | សហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យការដឹកជញ្ជូនផលនេសាទ | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ | **៣០០ ០០០** | រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ |
| **២.៥** | **ការតាមដាន ត្រួតពិនិត្យ និងអង្កេត** | | | | | |
| ២.៥.១ | រៀបចំនិងអនុវត្តផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | **១៥០ ០០០** | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណាយគ្រោងតាមឆ្នាំ (ដុល្លារអាមេរិក) | | | ចំណាយសរុប | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ២.៥.២ | បន្តបណ្តុះបណ្តាលការងារតាមដាន ត្រួតពិនិត្យ និងអង្កេត ដែលមានចែងនៅក្នុងផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ | ៣០ ០០០ | ៣០ ០០០ | ៣០ ០០០ | ៩០ ០០០ | រដ្ឋបាលជលផល |
| ២.៥.៣ | ទិញជូសជុលនិងថែរក្សានាវាល្បាត | ១ ៥០០ ០០០ | ១២៥ ០០០ | ១២៥ ០០០ | ១ ៧៥០ ០០០ | រដ្ឋបាលជលផល |
| ២.៥.៥ | បណ្តុះបណ្តាលនិងផ្តល់សៀវភៅកត់ត្រាស្ថិតិផលនេសាទសម្រាប់នាវានេសាទសមុទ្រខ្នាតធំនិងខ្នាតមធ្យម | ១០ ០០០ | ៣៥ ០០០ | ៣៥ ០០០ | ៨០ ០០០ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២.៥.៦ | សិក្សា ពិនិត្យ និងជ្រើសរើសឧបករណ៍តាមដានសមស្រប ដើម្បីដំឡើងប្រព័ន្ធតាមដានក្នុងនាវានេសាទសមុទ្រខ្នាតមធ្យមនិងខ្នាតធំ | ៥០ ០០០ | | | ៥០ ០០០ | រដ្ឋបាលជលផល |
| ២.៥.៧ | ដំឡើងប្រព័ន្ធតាមដាន សម្រាប់នាវានេសាទសមុទ្រខ្នាតមធ្យមនិងធំ | | ៥០ ០០០ | | ៥០ ០០០ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៣ | **ការទទួលខុសត្រូវរបស់កម្ពុជាក្នុងនាមជារដ្ឋម្ចាស់ទង់ជាតិ** | | | | | |
| ៣.១ | **ការចុះបញ្ជី និងកត់ត្រានាវានេសាទ នៅក្នុងដែននេសាទសមុទ្ររបស់រដ្ឋដទៃឬនៅសមុទ្រអន្តរជាតិ** | | | | | |
| ៣.១.១ | សហការវិភាគតម្លៃដាក់ទុននិងផលចំណេញសម្រាប់ការបើកឱ្យមានការចុះបញ្ជីនាវានេសាទបរទេសឡើងវិញដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | ៥០ ០០០ | ៥០ ០០០ | | ១០០ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងទីស្ដីការគណៈរដ្ឋមន្ត្រី |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណាយគ្រោងតាមឆ្នាំ (ដុល្លារអាមេរិក) | | | ចំណាយសរុប | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ៣.១.២ | រៀបចំប្រព័ន្ធចុះបញ្ជីនិងផ្ដល់លិខិតអនុញ្ញាតនាវានេសាទសមុទ្របំពាក់ទង់ជាតិកម្ពុជាដែលធ្វើនេសាទក្នុងរដ្ឋដទៃ ឬនៅសមុទ្រអន្តរជាតិ | ២៥ ០០០ | ២៥ ០០០ | | ៥០ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងទីស្ដីការគណៈរដ្ឋមន្ត្រី |
| ៣.២ | **ការផ្ដល់សិទ្ធិឱ្យធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋដទៃ និងក្នុងសមុទ្រអន្តរជាតិ** | | | | | |
| ៣.២.១ | រៀបចំយន្តការនៃការផ្ដល់សិទ្ធិឱ្យនាវាធ្វើនេសាទមិនមែនជាការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតដែលបំពាក់ទង់ជាតិកម្ពុជា នៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋដទៃឬនៅក្នុងសមុទ្រអន្តរជាតិ រួមទាំងវិធានការត្រួតពិនិត្យនិងអធិការកិច្ចដ៏មានប្រសិទ្ធភាព | ១៥ ០០០ | ១៥ ០០០ | ១៥ ០០០ | ៤៥ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងទីស្ដីការគណៈរដ្ឋមន្ត្រី |
| ៣.៣ | **វិធានការត្រួតពិនិត្យនាវាពាក់ព័ន្ធនឹងការនេសាទ** | | | | | |
| ៣.៣.១ | បង្កើតប្រព័ន្ធចុះបញ្ជីនិងផ្ដល់លិខិតអនុញ្ញាតនិងកត់ត្រានាវានេសាទដឹកជញ្ជូននិងនាវាផ្គត់ផ្គង់កម្ពុជានៅក្នុងដែននេសាទសមុទ្ររដ្ឋដទៃនិងសមុទ្រអន្តរជាតិ | | ៥០ ០០០ | ៥០ ០០០ | ១០០ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងទីស្ដីការគណៈរដ្ឋមន្ត្រី |
| ៤ | **វិធានការរដ្ឋម្ចាស់កំពង់ផែ** | | | | | |
| ៤.១ | **ការប្រើវិធានការរដ្ឋម្ចាស់កំពង់ផែ** | | | | | |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណាយគ្រោងតាមឆ្នាំ (ដុល្លារអាមេរិក) | | | ចំណាយសរុប | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ៤.១.១ | កំណត់កំពង់ផែឬកន្លែងឡើងផលនេសាទផ្លូវការសម្រាប់នាវាបរទេស | ៣០ ០០០ | | | ៣០ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤.១.២ | បង្ហាញឬផ្សព្វផ្សាយកន្លែងឡើងផលនេសាទឬកំពង់ផែនេសាទ សម្រាប់ធ្វើអធិការកិច្ច ចំពោះនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតរបស់បរទេស | ២៥ ០០០ | ២៥ ០០០ | | ៥០ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងទីស្តីការគណៈរដ្ឋមន្ត្រី |
| **៤.២** | **នីតិវិធីចំពោះនាវាបរទេសដែលបានរកឃើញថា ជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត** | | | | | |
| ៤.២.១ | បង្កើតនិងអនុវត្តនីតិវិធីចំពោះនាវាបរទេសដែលរកឃើញថាជានាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | ២ ៥ ០០០ | ២៥ ០០០ | | ៥០ ០០០ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **៤.៣** | **កិច្ចសហប្រតិបត្តិការជាមួយរដ្ឋម្ចាស់កំពង់ផែឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ដែលពាក់ព័ន្ធ** | | | | | |
| ៤.៣.១ | សហការជាមួយរដ្ឋម្ចាស់ផ្ទេរ រដ្ឋម្ចាស់កំពង់ផែនិងរដ្ឋពាក់ព័ន្ធនានា ព្រមទាំងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ស្តីពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណាយគ្រោងតាមឆ្នាំ (ដុល្លារអាមេរិក) | | | ចំណាយសរុប | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ៤.៣.២ | ចែករំលែកព័ត៌មានស្តីពីការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ និងការតាមដាន ត្រួតពិនិត្យ និងការអង្កេត | ១៥ ០០០ | ១៥ ០០០ | ១៥ ០០០ | ៤៥ ០០០ | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មាធិការជាតិសន្តិសុខលេមូសមុទ្រ និងដៃគូអភិវឌ្ឍន៍នានា |
| ៥ | **វិធានការទាក់ទងនឹងទីផ្សារដែលបានព្រមព្រៀងជាអន្តរជាតិ** | | | | | |
| ៥.១ | អនុម័តនិងសាកល្បងប្រើប្រព័ន្ធឯកសារផលនេសាទអាស៊ាន និងលេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ | | ៥០ ០០០ | ៥០ ០០០ | ១០០ ០០០ | រដ្ឋបាលជលផល និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៦ | **កិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងប្រទេសផ្សេងទៀតដើម្បីលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត** | | | | | |
| ៦.១ | បន្តផ្តល់ព័ត៌មានដល់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ អំពីនាវានេសាទដោតទង់ជាតិកម្ពុជានៅក្នុងសមុទ្រអន្តរជាតិ និងក្នុងតំបន់របស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ | | ១០ ០០០ | ១០ ០០០ | ២០ ០០០ | រដ្ឋបាលជលផល និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៧ | **លក្ខខណ្ឌតម្រូវពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍** | | | | | |
| ៧.១ | បន្តកិច្ចសហការជាមួយអាស៊ាន លេខាធិការដ្ឋាន-អភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ | រដ្ឋបាលជលផល កងទ័ពជើងទឹក ប៉ូលីសលមូសមុទ្រ លេខាធិការដ្ឋានអាស៊ាន លេខាធិការដ្ឋានអភិវឌ្ឍន៍ជលផលនៃតំបន់អាស៊ីអាគ្នេយ៍ និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |

| លេខរៀងសកម្មភាព | សកម្មភាព | ចំណាយគ្រោងតាមឆ្នាំ (ដុល្លារអាមេរិក) | | | ចំណាយសរុប | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | | |
| ៨ | ការរាយការណ៍ | | | | | |
| ៨.១ | រៀបចំផែនការអនុវត្តនិងអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងថវិកាសម្រាប់អនុវត្តប្រចាំឆ្នាំ | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ១៥ ០០០ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៨.២ | រាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ១៥ ០០០ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៨.៣ | រាយការណ៍ទៅកាន់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិរៀងរាល់ពីរឆ្នាំម្តង | | ១០ ០០០ | | ១០ ០០០ | រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| សរុប | | | | | ៥ ៩៣០ ០០០ | |

# សន្ទានុក្រម

**កន្លែងនេសាទតាមឆ្នេរ** សំដៅដល់ដែននេសាទសមុទ្រដែលលាតសន្ធឹងពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតរហូតដល់ខ្សែបន្ទាត់ខាងក្រៅនៃសមុទ្រដែនដីដែលមានចម្ងាយ១២ម៉ៃល៍ឬ ២២,២០គីឡូម៉ែត្រពីខ្សែបន្ទាត់មូលដ្ឋាន។

**កន្លែងនេសាទសមុទ្រក្រៅ** សំដៅដល់ដែននេសាទសមុទ្រដែលលាតសន្ធឹងពីខ្សែបន្ទាត់ខាងក្រៅនៃសមុទ្រដែនដីរហូតដល់ព្រំប្រទល់ខាងក្រៅតំបន់សេដ្ឋកិច្ចផ្ដាច់មុខ(មានចម្ងាយ២០០ម៉ៃល៍ដក១២ម៉ៃល៍ស្មើនឹង៣៤៨,២០គីឡូម៉ែត្រ)។

**កន្លែងនេសាទសមុទ្រអន្តរជាតិ** សំដៅដល់តំបន់ផ្ទៃទឹកសមុទ្រចាប់ពីខ្សែបន្ទាត់ខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខមានចម្ងាយហួសពី២០០ម៉ៃល៍ឬ៣៧០,៤០គីឡូម៉ែត្រពីខ្សែបន្ទាត់មូលដ្ឋាន។

**ការនេសាទគ្រួសារ** សំដៅដល់ការនេសាទដោយដៃឬប្រើប្រាស់ឧបករណ៍នេសាទមានលក្ខណៈគ្រួសារឬប្រពៃណី ឬការនេសាទរួមផ្សំដោយនាវានេសាទគ្មានម៉ាស៊ីន។

**ការនេសាទខ្នាតតូច** សំដៅដល់ការនេសាទដែលប្រើប្រាស់ឧបករណ៍នេសាទទោលខ្នាតតូចឬការធ្វើនេសាទរួមផ្សំដោយនាវានេសាទមានម៉ាស៊ីនដែលមានកម្លាំងតូចជាង១០សេះសម្រាប់ដែននេសាទទឹកសាបឬនាវានេសាទដែលមានប្រវែងខ្លីជាង១២ម៉ែត្រលើកលែងតែនាវានេសាទអួនអូសសម្រាប់ដែននេសាទសមុទ្រ។

**ការនេសាទខ្នាតមធ្យម** សំដៅដល់ការនេសាទដែលប្រើប្រាស់ឧបករណ៍នេសាទទោលខ្នាតមធ្យមឬការធ្វើនេសាទរួមផ្សំដោយនាវានេសាទដែលមានម៉ាស៊ីនកម្លាំងចាប់ពី១០សេះដល់ ៥០សេះសម្រាប់ដែននេសាទទឹកសាបឬនាវានេសាទដែលមានប្រវែងចាប់ពី ១២ម៉ែត្រ ដល់២៤ម៉ែត្រសម្រាប់ដែននេសាទសមុទ្រ។

**ការនេសាទខ្នាតធំ** សំដៅដល់ការនេសាទដែលប្រើប្រាស់ឧបករណ៍នេសាទទោលខ្នាតធំឬការធ្វើនេសាទរួមផ្សំដោយនាវានេសាទដែលមានម៉ាស៊ីនកម្លាំងលើសពី៥០សេះសម្រាប់ដែននេសាទទឹកសាបឬនាវានេសាទដែលមានប្រវែងចាប់ពី២៤ម៉ែត្រឡើងសម្រាប់ដែននេសាទសមុទ្រ។

**ការនេសាទខុសច្បាប់** សំដៅដល់សកម្មភាពដែលៈ

(១) ប្រព្រឹត្តដោយនាវានៃរដ្ឋមួយឬបរទេស នៅក្នុងដែនទឹកដែលស្ថិតក្រោមយុត្តាធិការនៃរដ្ឋនោះដោយគ្មានការអនុញ្ញាតឬជាការបំពានច្បាប់និងបទប្បញ្ញត្តិរបស់រដ្ឋនានា។

(២) ប្រព្រឹត្តដោយនាវាដែលប្រើទង់ជាតិនៃរដ្ឋនានាដែលជាភាគីនៃអង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ពាក់ព័ន្ធណាមួយ ប៉ុន្តែអនុវត្តដោយបំពានលើវិធានការគ្រប់គ្រងនិងអភិរក្សដែលត្រូវបានអនុម័តដោយអង្គការនោះនិងដោយរដ្ឋនានាដែលទទួលខុសត្រូវឬបទប្បញ្ញត្តិពាក់ព័ន្ធនានានៃច្បាប់អន្តរជាតិជាធរមាន។

(៣) ជាការរំលោភលើច្បាប់ជាតិឬកាតព្វកិច្ចអន្តរជាតិ រួមទាំងច្បាប់នានានិងកាតព្វកិច្ចដែលត្រូវអនុវត្តដោយបណ្តារដ្ឋសហការនានាជាមួយនឹងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ។

**ការនេសាទគ្មានរបាយការណ៍** សំដៅដល់សកម្មភាពនេសាទដែលៈ

(១) មិនបានរាយការណ៍ឬរាយការណ៍ភូតកុហកទៅអាជ្ញាធរជាតិពាក់ព័ន្ធដោយបំពានច្បាប់ឬបទប្បញ្ញត្តិជាតិនានា

(២) ប្រព្រឹត្តនៅក្នុងតំបន់នៃដែនសមត្ថកិច្ចរបស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធដែលមិនត្រូវបានរាយការណ៍ឬរាយការណ៍ភូតកុហក ដោយផ្ទុយពីនីតិវិធីនៃការរាយការណ៍របស់ស្ថាប័ននោះ។

**ការនេសាទដោយគ្មានការអនុញ្ញាត** សំដៅដល់សកម្មភាពនេសាទៈ

(១) នៅក្នុងតំបន់ដែលមានការអនុវត្តតាមបទប្បញ្ញត្តិរបស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ ដែលប្រព្រឹត្តឡើងដោយនាវាគ្មានអត្តសញ្ញាណឬនាវាដែលបានប្រើទង់ជាតិនៃរដ្ឋមិនមែនជាភាគីនៃស្ថាប័ននោះ ឬដោយអង្គភាពនេសាទណាមួយ ដែលមិនអនុលោមតាមឬបំពានលើវិធានការគ្រប់គ្រងនិងអភិរក្សរបស់អង្គការនោះ។

(២) នៅក្នុងតំបន់ផលស្តុកត្រីដែលកំពុងស្នើសុំធ្វើជាកន្លែងអភិរក្ស ដោយការធ្វើនេសាទមិនអនុលោមតាមរដ្ឋដែលកំពុងទទួលខុសត្រូវ សម្រាប់ការអភិរក្សធនធានសមុទ្រដែលមានជីវិតស្ថិតក្រោមច្បាប់អន្តរជាតិ។

**ការតាមដាន ត្រួតពិនិត្យ** សំដៅដល់ប្រព័ន្ធវិធានការប្រើសម្រាប់តាមដាននិងត្រួតពិនិត្យសកម្មភាពជលផល និងការអង្កេត។

**ការផ្ទេរផលនេសាទ** ជាសកម្មភាពនៃការផ្ទេរផលនេសាទចេញពីនាវានេសាទមួយទៅនាវាមួយទៀតបើទោះបីជានៅក្នុងសមុទ្រឬកំពង់ផែនិងកន្លែងឡើងផលនេសាទ។

**ក្រុមស្វ័យការពារ** វិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និងអង្កេត តាមបែបវិមជ្ឈការ ដែលប្រជាពលរដ្ឋចូលរួមដោយស្ម័គ្រចិត្តជាទូទៅធ្វើឡើងតាមរយៈការរាយការណ៍ពីម្នាក់ទៅម្នាក់។

**ដែននេសាទសមុទ្រ** គឺសំដៅដល់ទឹកភ្លាវឬទឹកសមុទ្រដែលលាតសន្ធឹងនៅពេលទឹកជោរដល់នៅតាមបណ្តោយឆ្នេររហូតដល់ដែនខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ រួមបញ្ចូលទាំងដែនទឹកខាងក្នុងនិងដែនទឹកបូរណភាពដែនដី (នៅក្នុងឯកសារនេះគឺជាដែនសមុទ្រកម្ពុជាឬដែនទឹកកម្ពុជា)។

**រដ្ឋទាំងអស់** សំដៅដល់ជាតិសាសន៍នានាឬទឹកដីនានាដែលបង្កើតបានជាសហគមន៍នយោបាយស្ថិតនៅក្រោមរដ្ឋាភិបាលមួយ។

**រដ្ឋម្ចាស់ឆ្នេរ** — សំដៅដល់រដ្ឋដែលមានសិទ្ធិអធិបតេយ្យភាព នៅក្នុងតំបន់ឆ្នេរសម្រាប់ការរុករក និងការធ្វើអាជីវកម្ម ការគ្រប់គ្រង និងការអភិរក្សធនធានសមុទ្រដែលមាន ឬគ្មានជីវិតក្នុងដែនយុត្តាធិការរបស់ខ្លួន។

**រដ្ឋម្ចាស់ទង់ជាតិ** — សំដៅដល់រដ្ឋដែលមានសិទ្ធិអធិបតេយ្យភាពក្នុងការផ្តល់សិទ្ធិធ្វើអាជីវកម្មដល់នាវាបរទេសនៅក្នុងដែនសមុទ្រអន្តរជាតិ។

**រដ្ឋម្ចាស់កំពង់ផែ** — សំដៅដល់រដ្ឋដែលផ្តល់កន្លែងសម្រាប់នាវាឡើងផលនេសាទឬផ្តល់សេវាផ្គត់ផ្គង់។

**អធិការកិច្ច** — សំដៅដល់សកម្មភាពនៃការត្រួតពិនិត្យមើលនាវា ឧបករណ៍ និងឯកសារផ្សេងៗ សម្រាប់ការធ្វើនេសាទនៅក្នុងសមុទ្រ កំពង់ផែឬកន្លែងឡើងផលនេសាទឬនៅកន្លែងណាមួយនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ផលនេសាទ។

**អង្គការគ្រប់គ្រងជលផលឬក្រុមការងារជលផលថ្នាក់តំបន់** — សំដៅលើស្ថាប័នអន្តរជាតិឬការរៀបចំសន្ធិសញ្ញារវាងរដ្ឋពីរឬច្រើនដែលទទួលខុសត្រូវលើការគ្រប់គ្រងជលផល រួមទាំងការបង្កើតវិធានការដែលគ្រប់គ្រងសកម្មភាពនេសាទ។ អង្គការនិងក្រុមការងារពាក់ព័ន្ធនេះទទួលខុសត្រូវវាល់សេវាកម្មបច្ចេកទេសដូចជាការប្រមូលព័ត៌មាន ការវិភាគ ការវាយតម្លៃផលស្តុក ការតាមដាន ត្រួតពិនិត្យ និងអង្កេតការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធកម្មវិធីការអនុវត្ត និងការកំណត់វិធានការនៃការទទួលបានការនេសាទ និងការបែងចែកធនធាន។

## ឯកសារយោង


1. Agnew D J, Pearce J, Pramod G, Peatman T, Watson R, Beddington J R, Pitcher T J (2009): Estimating the worldwide extent of illegal fishing. *PLoS ONE. 2009; 4(2): e4570. Published online 2009 Feb 25. doi: 10.1371/journal.pone.0004570 PMCID: PMC2646833.*
2. Funge-Smith (per comm): Based on an APFIC study "Regional review of illegal, unregulated and unreported (IUU) fishing by foreign vessels". *Asia-Pacific Fisheries Commission.*
3. UNIDO/MAFF 2015: Value Chain Assessment of Marine Fisheries Sector and Roadmap for Development. *United Nations Industrial Development Organization/ Ministry of Agriculture, Forestry and Fisheries.*
4. MAFF (2015): The Strategic Planning Framework for Fisheries: Update for 2015-2024. *Ministry of Agriculture, Forestry and Fisheries* and FIA Fisheries Statistics for 2017.
5. Teh, L, Shon D, Zylich K and Zeller D (2014): Reconstructing Cambodia's marine fisheries catch 1950 – 2010. *The University of British Columbia Working Paper #2014-18.*
6. FiA (2016) Assessment report of fishing capacity and IUU in Cambodia's EEZ and high seas.
7. Fisheries Administration: Report on Marine fishing vessel census 2018 (in Khmer).
8. Fisheries Administration: Annual report 2019.
9. DOF Fisheries Statistics for 2015. *Department of Fisheries, Thailand.*